BIDC

Be your side, by your hand







# របាយការណ៍

## ប្រចាំឆ្នាំ ២០១៤

# មាតិកា

ទំព័រ


ទិដ្ឋភាពទូទៅ ............ I

ការទទួលខុសត្រូវសង្គមរបស់ក្រុមហ៊ុន ............ II

ការអនុវត្តទស្សនវិស័យឆ្នាំ២០១៤ ............ III

រចនាសម្ព័ន្ធចាត់តាំង ............ IV

សារពីប្រធាន ............ V-IV

សារពីអគ្គនាយកប្រតិបត្តិ ............ VII-VIII

ការសហការគ្រប់គ្រង ............ IX-XII

របាយការណ៍របស់គណៈគ្រប់គ្រង ............ ១ - ៥

របាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្ម

របាយការណ៍របស់សវនករឯករាជ្យ ............ ៦ - ៧

តារាងតុល្យការ ............ ៨

របាយការណ៍លទ្ធផល ............ ៩

របាយការណ៍បំរែបំរួលមូលធន ............ ១០

របាយការណ៍លំហូរសាច់ប្រាក់ ............ ១១

កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ ............ ១២ - ៦៩

សេចក្តីប្រកាសរបស់គណៈគ្រប់គ្រង ............ ៧០

វិសាលភាព ............ ៧១

មូលនិធិផ្ទាល់សុទ្ធ ............ ៧២

អនុបាតសាច់ប្រាក់ងាយស្រួល ............ ៧៣-៧៤

អនុបាតសាធនភាព ............ ៧៥

ចំណាត់ថ្នាក់ឥណទាន និងសំវិធានធនសំរាប់ឥណទានបាត់បង់ ............ ៧៦

រូបិយប័ណ្ណបរទេសបើកចំហសុទ្ធ ............ ៧៧-៧៨

ព័ត៌មាន និងបទបញ្ញត្តិប្រុងប្រយ័ត្នផ្សេងៗទៀតដែលតំរូវតាមច្បាប់ស្តីពីស្ថាប័នធនាគារ

និងហិរញ្ញវត្ថុ ............ ៧៩-៨១

សូចនាករណ៍ហិរញ្ញវត្ថុសំខាន់ៗ ............ ៨២-៩០

# ទិដ្ឋភាពទូទៅ

ដោយមានការណែនាំ និងការគាំទ្រពីរដ្ឋាភិបាលវៀតណាម-កម្ពុជា ធនាគារវិនិយោគ និងអភិវឌ្ឍន៍វៀតណាម (BIDV) និងក្រុមហ៊ុន Phuong Nam បានសហការបង្កើតក្រុមហ៊ុនវិនិយោគ និងអភិវឌ្ឍន៍កម្ពុជា (IDCC) សម្រាប់ប្រតិបត្តិការវិនិយោគហិរញ្ញវត្ថុក្នុងវិស័យនានានៅកម្ពុជាដូចជា វិស័យធនាគារធានារ៉ាប់រង និងវិស័យកសិកម្ម ហើយគម្រោងទី១ គឺទិញយកធនាគារអភិវឌ្ឍន៍រុងរឿង (PIB) បន្ទាប់មករៀបចំរចនាសម្ព័ន្ធ និងប្តូរឈ្មោះទៅជាធនាគារវិនិយោគ និងអភិវឌ្ឍន៍កម្ពុជា ភីអិលស៊ី (BIDC)។ ធនាគារ BIDC បានបើកប្រតិបត្តិការរបស់ខ្លួនជាផ្លូវការចាប់តាំងពីថ្ងៃទី ០១ ខែកញ្ញា ឆ្នាំ ២០០៩ បន្ទាប់ពីធនាគារជាតិនៃកម្ពុជា(NBC) អនុម័តសេចក្តីសម្រេចលេខ B7.09. 148 ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០០៩។

ប្រតិបត្តិការធនាគារ BIDC ដោយផ្ទាល់ និងទាំងស្រុងពីធនាគារ BIDV ដែលជាធនាគារមួយក្នុងចំណោមធនាគារពាណិជ្ជធំៗទាំងបួននៅវៀតណាម ដែលមានបទពិសោធន៍ជាង៥៧ឆ្នាំក្នុងការធ្វើអាជីវកម្មនៅវៀតណាម។ ដោយមូលហេតុនេះ ធនាគារ BIDC អាចបើកដំណើរការប្រតិបត្តិការធនាគាររបស់ខ្លួននៅក្នុងប្រទេសកម្ពុជា ដោយអនុវត្តបច្ចេកវិទ្យាផ្នែកធនាគារដ៏ទំនើប ធានាបាននូវសាច់ប្រាក់ ហើយជាពិសេសដើម្បីប្រកួតប្រជែងក្នុងវិស័យធនាគារនៅកម្ពុជា។

ដោយប្រតិបត្តិការរយៈពេលជាង៥ឆ្នាំនៅកម្ពុជា ធនាគារ BIDC បានក្លាយខ្លួនជាធនាគារមួយក្នុងចំណោមធនាគារពាណិជ្ជធំៗបំផុតនៅក្នុងប្រទេស ដោយមានទ្រព្យសកម្មសរុបចំនួន ៥៨៩.៨៣៧.២៥៣ ដុល្លារអាមេរិក គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤។ ជាមួយសាខាបម្រើអតិថិជនរបស់ខ្លួនទាំង៧កន្លែងទាំងនៅក្នុងប្រទេសកម្ពុជា និងប្រទេសវៀតណាម បុគ្គលិករបស់យើងប្រមាណ៤០០នាក់ បម្រើសេវាកម្មដល់បុគ្គល ក្រុមហ៊ុនសហគ្រាស និងក្រុមហ៊ុនសាជីវកម្មចម្រុះដែលជាអតិថិជនរបស់យើងនៅក្នុងប្រទេសទាំងពីរ គឺប្រទេសកម្ពុជា និងប្រទេសវៀតណាម។

ដោយមានបំណងក្លាយជាធនាគារមួយក្នុងចំណោមធនាគារពាណិជ្ជធំៗបំផុតនៅកម្ពុជា ធនាគារ BIDC បានពង្រីកប្រតិបត្តិការរបស់ខ្លួនទៅតាមបណ្តាខេត្តដើម្បីប្រកួតប្រជែងជាមួយស្ថាប័នហិរញ្ញវត្ថុក្នុងស្រុក និងបម្រើអតិថិជនបច្ចុប្បន្ន និងអ្នកដែលនឹងក្លាយជាអតិថិជននៅពេលអនាគត។ ដោយមានការគាំទ្រពេញទំហឹងពីធនាគារ BIDV និងការគាំទ្រពីរដ្ឋាភិបាលកម្ពុជា-វៀតណាម យើងមានជំនឿយ៉ាងមុតមាំថា ធនាគារ BIDC នឹងអាចសម្រេចគោលដៅរយៈពេលវែងរបស់ខ្លួនបាន ដើម្បីក្លាយជាធនាគារមួយក្នុងចំណោមធនាគារពាណិជ្ជទាំងបួននិងដៃគូអាជីវកម្មនិងអតិថិជនដ៏មានតម្លៃនៅក្នុងប្រទេសកម្ពុជា
នាពេលឆាប់ៗខាងមុខនេះ។

## វត្ថុបំណង និងគុណតម្លៃរបស់ក្រុមហ៊ុន

គោលបំណងរបស់ធនាគារ BIDC គឺចង់ក្លាយជាស្ថាប័នឈានមុខគេនៅកម្ពុជាសម្រាប់អតិថិជនរបស់យើង។ យុទ្ធសាស្ត្រផ្តោតលើអតិថិជនរបស់យើង ជួយបង្កើតគុណតម្លៃម្ចាស់ភាគហ៊ុនរបស់យើង។ វត្ថុបំណងរបស់ក្រុមហ៊ុន៖

- ទំនាក់ទំនងអតិថិជនយូរអង្វែង
- ការគ្រប់គ្រងហានិភ័យបានល្អ
- ចំណូលប្រកបដោយនិរន្តរភាពនិងទៀងទាត់
- ការរីកចម្រើនតាមបែបយុទ្ធសាស្ត្រដែលយើងមានផលប្រយោជន៍ប្រកួតប្រជែង

វប្បធម៌អង្គភាពរបស់យើងផ្អែកលើគុណតម្លៃនៃសាមគ្គីភាព សេវាកម្ម ការទទួលខុសត្រូវ ភាពសម្បូរបែប និងសុចរិតភាពជាកម្លាំងចលករនៃទស្សនវិស័យ និងបេសកកម្មរបស់យើង។

គុណតម្លៃរបស់យើងកំណត់ថាយើងជានរណា៖

- សាមគ្គីភាព៖ យើងធ្វើក្នុងនាមក្រុមហ៊ុនតែមួយ និងធ្វើការរួមគ្នាដើម្បីទទួលបានជោគជ័យ
- សេវាកម្ម៖ ផ្តល់សេវាកម្មល្អឥតខ្ចោះជូនអតិថិជន
- ភាពសម្បូរបែប៖ មានភាពសម្បូរបែបសម្រាប់កំណើន និងនវានុវត្តន៍
- សុចរិតភាព៖ ការជឿទុកចិត្តតាមរយៈសុចរិតភាពក្នុងការធ្វើអាជីវកម្ម

# ការទទួលខុសត្រូវសង្គមរបស់ក្រុមហ៊ុន

ជារៀងរាល់ឆ្នាំ យើងតែងតែបរិច្ចាគដល់អង្គការសប្បុរសធម៌ទូទាំងប្រទេស និងដល់បុព្វហេតុផ្សេងៗទៀតដែលនឹងនាំមកផលល្អដល់បរិស្ថាននិងសង្គមរយៈពេលវែងសម្រាប់មនុស្សជំនាន់ក្រោយ។ អង្គការទាំងនោះដែលរួមមានទាំងកាកបាទក្រហមកម្ពុជា និងអង្គការជនពិការកម្ពុជាផង គឺជាអង្គការចុះបញ្ជីដោយស្ម័គ្រចិត្តមិនស្វែងរកប្រាក់កម្រៃដែលប្តេជ្ញាចិត្តអភិវឌ្ឍ និងស្តារនីតិសម្បទារបស់ជនពិការ និងជនរងទុក្ខលំបាក និងការអភិវឌ្ឍសង្គមទាំងមូល។

## យើងជួយកាកបាទក្រហមកម្ពុជា ដើម្បីលើកកម្ពស់ការកាត់បន្ថយភាពក្រីក្រ



ការបរិច្ចាគដល់កាកបាទក្រហមកម្ពុជា នៅខែឧសភា ឆ្នាំ២០១៤

ដោយមានគោលបំណងសំខាន់ដើម្បីកាត់បន្ថយភាពក្រីក្រក្នុងប្រទេស ជារៀងរាល់ឆ្នាំ ធនាគារ BIDC តែងតែឧបត្ថម្ភគាំទ្រកាកបាទក្រហមកម្ពុជាតាមរយៈការរួមចំណែកផ្តល់មូលនិធិ ដើម្បីជួយឱ្យកុមារដែលរស់នៅតាម តំបន់ដាច់ស្រយាលទទួល បានការអប់រំប្រកបដោយគុណភាពខ្ពស់ ចំណេះដឹង និងបំណិន ជីវិតដែលពួកគេត្រូវការដើម្បីសម្រេច បាន សក្តានុពលពេញលេញ ដើម្បីធានាថាពួកគេ ទទួលបានការថែទាំសុខភាព និងដើម្បីផ្តល់ជូនទឹកស្អាតសម្រាប់បរិភោគតាម រយៈការផ្តល់អណ្តូងទឹកនៅក្នុងសហគមន៍ជា ដើម។

## យើងមានបំណងលើកកម្ពស់កីឡាទាំងថ្នាក់ជាតិ និងអន្តរជាតិ



រូបភាពថតជាមួយក្រុម U21 ក្នុងខែសីហា ឆ្នាំ២០១៤

ធនាគារ BIDC បានចាប់ដៃគូជាមួយសហព័ន្ធបាល់ទាត់កម្ពុជា អស់រយៈពេលជាង ៦ឆ្នាំ ដើម្បីឧបត្ថម្ភ និងរៀបចំការប្រកួតបាល់ទាត់លក្ខណៈអន្តរជាតិ ដណ្តើមពានរង្វាន់ធនាគារ BIDC Cup ក្នុងព្រះរាជាណាចក្រកម្ពុជា ហើយក្នុងរយៈពេល៦ឆ្នាំមកនេះ យើងក៏បានរៀបចំការប្រកួតពានរង្វាន់ជើងឯកបែបនេះចំនួន ៣ដងមកហើយដែរ។ យើងក៏បានឧបត្ថម្ភគាំទ្រក្នុងការនាំក្រុមយុវជន U21 ទៅលេងក្នុងឆាកអន្តរជាតិ ដោយចូលរួមប្រកួតដណ្តើមពានរង្វាន់ Hassanal-Bolkiah ឆ្នាំ២០១៤ នៅប្រទេសព្រុយណេដារូសាឡឹម ចាប់ពីថ្ងៃទី៨ ដល់ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៤។

# ការអនុវត្តនស្សនវិស័យឆ្នាំ២០១៤

ក្នុងឆ្នាំ២០១៤ យើងបានអនុវត្តយុទ្ធសាស្រ្តផ្តោតលើអតិថិជន បង្កើតតម្លៃសម្រាប់ម្ចាស់ភាគហ៊ុន និង បានផ្តល់ប្រាក់ចំណេញដ៏ច្រើន

## របាយការណ៍សង្ខេបស្តីពីហិរញ្ញវត្ថុ

| សម្រាប់ថ្ងៃទី៣១ខែធ្នូ ចុងឆ្នាំ | ២០១៤ | ២០១៣ |
|---|---|---|
| **លទ្ធផលហិរញ្ញវត្ថុ (ជាប្រាក់ដុល្លារ)** | | |
| ប្រាក់ចំណូល | 21,218,453 | 22,246,718 |
| ការចំណាយលើការខាតបង់ឥណទាន | 2,862,380 | 5,394,995 |
| ចំណាយ | 12,277,699 | 11,404,214 |
| ចំណេញសុទ្ធ | 4,216,495 | 4,051,238 |
| **ការវាស់ស្ទង់ហិរញ្ញវត្ថុ (%)** | | |
| ចំណេញលើទ្រព្យសកម្ម | 0.71 | 0.82 |
| ចំណេញលើហ៊ុន | 4.90 | 4.93 |
| អាត្រាការប្រាក់លើប្រាក់ចំណូល | 87.82 | 87.02 |
| កម្រៃសុទ្ធ និងចំណូលជើងសាលើប្រាក់ចំណូល | 11.72 | 12.65 |

### ចំណូលសរុប (ដុល្លារ)

- ប្រភពចំណូលសំខាន់របស់ធនាគារ BIDC គឺការប្រាក់ និង ចំណូលស្រដៀងគ្នាដែលស្មើនឹង៨៧,៨២% នៃចំណូលសរុប។
- ប្រភពចំណូលបន្ទាប់បន្សំរបស់ធនាគារកម្រៃ និងចំណូលពីជើងសាដែលស្មើនឹង១១,៧២%នៃចំណូលសរុបដែលរកបាន។




### ចំណេញសុទ្ធ (ដុល្លារ)

- បើទោះជាចំណូលសរុបរបស់ធនាគារ BIDC បានធ្លាក់ចុះដល់ ៣,៩២%ក្នុងឆ្នាំ ២០០៤ក៏ដោយ ក៏ចំណេញសុទ្ធរបស់ធនាគារ បានកើតឡើងពី ៤.០៥១.២៣៨ដុល្លារក្នុងឆ្នាំ២០១៣ ដល់ ៤.២១៦.៤៩៥ ដុល្លារក្នុងឆ្នាំ២០១៤ ស្មើនឹង៤,០៨%កើនឡើង នៅក្នុងរយៈពេលពីរឆ្នាំដែរ។ កំណើននៃប្រាក់ចំណេញសុទ្ធនេះ ដោយសារតែការកាត់បន្ថយការចំណាយខាតបង់លើឥណទាន។




### ចំណេញលើហ៊ុន (%)

- កំណើនលើប្រាក់ចំណេញសុទ្ធក្នុងឆ្នាំ២០១៤ ដោយសារការ ប្រសើរឡើងបន្តិចបន្តួចស្តីពីប្រាក់ចំណេញលើហ៊ុន ៤,៩% ក្នុងឆ្នាំ២០១៣ ដល់ ៤,៩៣%ក្នុងឆ្នាំ២០១៤។



# រចនាសម្ព័ន្ធចាត់តាំង





# សារពីប្រធាន

បរិយាកាសធុរកិច្ចនៅប្រទេសកម្ពុជា ក្នុងឆ្នាំ២០១៤ មានអំណោយផលគួរសមជាពិសេស ក្នុងរយៈពេលប្រាំមួយខែដំបូង ដោយសារអស្ថិរភាពសេដ្ឋកិច្ចសង្គមកើតឡើងបន្ទាប់ពីការបោះឆ្នោតឆ្នាំ២០១៣។ ដូចធនាគារផ្សេងៗទៀតនៅក្នុងប្រទេសកម្ពុជា ដៃរអាជីវកម្មរបស់ធនាគារ BIDC ក៏បានរងការប៉ះពាល់ដែរ ហើយវត្ថុបំណងអាជីវកម្មមួយចំនួនដែលធនាគារ BIDC បានផ្តល់ឱ្យនៅដើមឆ្នាំ បានប្រឈមនឹងឧបសគ្គជាច្រើន។

ក្នុងកាលៈទេសៈនេះ ក្រុមប្រឹក្សាភិបាលរបស់ធនាគារ BIDC បានពិភាក្សាគ្នាជាទៀងទាត់ដើម្បីដាក់ចេញវិធានការសម្របទៅនឹងភាពមិនប្រក្រតី ការប្រែប្រួលក្នុងបរិយាកាសធុរកិច្ច។ ជាមួយនឹងគោលដៅសុវត្ថិភាព ស្ថិរភាព អាជីវកម្មរយៈពេលវែងនៅក្នុងទីផ្សារកម្ពុជា ក្រុមប្រឹក្សាភិបាលបានដឹកនាំគណៈគ្រប់គ្រងដើម្បីឱ្យធនាគារ BIDC ចាត់វិធានការអនុវត្តត្រឹមត្រូវគ្រប់ពេលវេលា។ ជាមួយគ្នានេះដែរ ប្រតិបត្តិការរបស់ធនាគារ BIDC ក្នុងឆ្នាំ២០១៤ សម្រេចបានតាមគោលដៅជាមូលដ្ឋាន ដូចដែលបានលើកឡើងដោយក្រុមប្រឹក្សាភិបាលដែលមានលទ្ធផលដូចខាងក្រោម៖

- សូចនាករស្តីពីទំហំនៃកំណើនបន្តបន្ទាប់នេះគឺ៖ ទ្រព្យសកម្មសរុបបានកើនឡើង២០,៥% ទុនប្រមូលផ្តុំបានកើនឡើង ២៤,៦% ឥណទានមិនទាន់សងបានកើនឡើង ១៦,៨% នៅដំណាច់ឆ្នាំ២០១៣។
- រចនាសម្ព័ន្ធទ្រព្យសកម្មរបស់ធនាគារ BIDC មានលំនឹង ដោយអនុវត្តតាមបទប្បញ្ញត្តិរបស់ធានាគារជាតិនៃកម្ពុជា ស្តីពីអាត្រាទូទាត់ ទ្រព្យសកម្មជាសាច់ប្រាក់ គុណភាពឥណទានក្រោមការគ្រប់គ្រង។
- ផលិតផល និងសេវាកម្មដែលបានអនុវត្តនៅទីផ្សារកាន់តែមានច្រើនឡើងៗ ដោយឆ្លើយ

តបទៅនឹងតម្រូវការរបស់អតិថិជនជាច្រើននៅក្នុងប្រទេសកម្ពុជា។

- កម្លាំងពលកម្មកាន់តែមានភាពប្រសើរឡើង ដោយសារមានកំណើនខ្ពស់ទាំងបរិមាណ និងគុណភាពរបស់មន្ត្រីមូលដ្ឋាន។ ធនាគារបានយកចិត្តទុកដាក់បន្ថែមទៀតចំពោះការបណ្តុះបណ្តាលដើម្បីបង្កើតបរិយាកាសការងារប្រកបដោយភាពរាក់ទាក់ ជាមួយនឹងការប្រកួតប្រជែងត្រឹមត្រូវដើម្បីលើកទឹកចិត្តបុគ្គលិកឱ្យប្រឹងប្រែងបន្ថែមទៀត។

នៅក្នុងដំណើរការអនុវត្តសកម្មភាពអាជីវកម្ម ក្រុមប្រឹក្សាភិបាល គណៈគ្រប់គ្រងរបស់ធនាគារ BIDC តែងតែដឹងច្បាស់ពីការវិវឌ្ឍ និងស្តាប់មតិយោបល់របស់អតិថិជន និងការរួមចំណែកផ្សេងៗ ការត្រៀមខ្លួនប្រឈមនឹងបញ្ហា ការកំណត់ដើម្បីប្រឹងប្រែងស្តារឡើងវិញ និងភាពឥតខ្ចោះជាបន្តបន្ទាប់។

ឆ្នាំ២០១៥ បន្ទាប់ពីភាពជោគជ័យនៅឆ្នាំ២០១៤ និងដើមឆ្នាំមក ធនាគារ BIDC បន្តកសាងយុទ្ធសាស្ត្រ ផ្តោះទៅរកស្ថិរភាព សុវត្ថិភាព ការឆ្លើយតបពេញលេញតាមបទដ្ឋានដែលដាក់ចេញដោយ NBC ការធ្វើសមាហរណកម្មចូលក្នុងសេដ្ឋកិច្ចកម្ពុជាដ៏ស៊ីជម្រៅ ការពង្រីកមូលដ្ឋានអតិថិជនក្នុងស្រុក ការស្រាវជ្រាវ និងបន្តពង្រីកបណ្តាញនៅតាមកន្លែងជាច្រើនទៀត។ ធនាគារ BIDC បន្តវិនិយោគខាងបច្ចេកវិទ្យាព័ត៌មាន ហេដ្ឋារចនាសម្ព័ន្ធដើម្បីបញ្ជាក់ពីយុទ្ធសាស្ត្រវិនិយោគអាជីវកម្មរយៈពេលវែងនៅក្នុងប្រទេសកម្ពុជា ព្រមទាំងដើម្បីក្លាយជាធនាគារពាណិជ្ជឈានមុខគេនៅក្នុងប្រទេសកម្ពុជា។ ធនាគារ BIDC នឹងបន្តលើកកម្ពស់តួនាទីនៃការទំនាក់ទំនងសម្រាប់ការវិនិយោគ និងកិច្ចសហប្រតិបត្តិការពាណិជ្ជកម្មរវាងប្រទេសកម្ពុជានិងវៀតណាមផងដែរ។ យើងជឿជាក់ថា ដោយមានការគាំទ្រ និងការគ្រប់គ្រងតឹងរឹងរបស់ NBC ប្រតិបត្តិការរបស់ធនាគារ BIDC នៅក្នុងប្រទេសកម្ពុជាមានការកើនឡើងឥតឈប់ឈរ ទទួលបានភាពជោគជ័យក្នុងរយៈពេលប៉ុន្មានឆ្នាំខាងមុខ ជាពិសេសចំពោះបុព្វហេតុនៃការអភិវឌ្ឍសេដ្ឋកិច្ចនាពេលខាងមុខនៃប្រទេសកម្ពុជា។

តំណាងក្រុមប្រឹក្សាភិបាលរបស់ធនាគារ BIDC ខ្ញុំសូមសម្តែងការដឹងគុណចំពោះអតិថិជនទាំងអស់របស់ ធនាគារ BIDC ដែលតែងតែសហការជាមួយយើងក្នុងពេលកន្លងមក។ ធនាគារ BIDC ប្តេជ្ញានៅជាមួយអតិថិជនដ៏ស្មោះស្ម័គ្រទាំងនេះដែលបានរួមចំណែកចំពោះការលំបាករបស់យើង និងផ្តល់ការពិគ្រោះយោបល់ស្តីពីការរកដំណោះស្រាយជូនអតិថិជនដើម្បីជំរុញអាជីវកម្មរបស់យើង។ ជាមួយគ្នានេះផងដែរ ខ្ញុំសូមថ្លែងអំណរគុណដល់បុគ្គលិក មន្ត្រី គណៈគ្រប់គ្រងទាំងអស់ចំពោះការលះបង់ ការអភិវឌ្ឍសម្រាប់គោលបំណងរួមរបស់ធនាគារ BIDC ។

ខ្ញុំមានជំនឿជឿជាក់ និងសង្ឃឹមថា ធនាគារ BIDC នឹងតែងតែជាផ្ទះរួមសម្រាប់បុគ្គលិក និងមន្ត្រីរបស់ធនាគារ BIDC ដែលបានលះបង់ និងប្រឹងប្រែងអស់ពីកម្លាំងកាយចិត្តដើម្បីកសាងសមត្ថភាពរបស់ខ្លួនឱ្យកាន់តែខ្លាំងក្លា និងរឹងមាំថែមទៀត។

លោក Le Dao Nguyen

ប្រធានក្រុមប្រឹក្សាភិបាល



# សារពីអគ្គនាយកប្រតិបត្តិ

សូមក្រឡេកមើលការអភិវឌ្ឍរបស់ធនាគារ BIDC ក្នុងរយៈពេល៦ឆ្នាំមុន ធនាគារ BIDC សម្រេចបានសមិទ្ធផលជាច្រើនគួរឱ្យកត់សម្គាល់។ ចេញពីធនាគារមួយដែលមានឈ្មោះថា ធនាគារអភិវឌ្ឍន៍រុងរឿង (PBI) ដែលមានទុនរួមគ្នាតិចតួចក្រោម១៥លានដុល្លារអាមេរិកនៃទ្រព្យសកម្ម បន្ទាប់ពីសកម្មភាពរៀបចំហេដ្ឋារចនាសម្ព័ន្ធឡើងវិញក្នុងចុងឆ្នាំ២០០៩ នោះធនាគារ BIDC មានការកើនឡើងឆាប់រហ័សជាមួយនឹងអាត្រាកំណើនមធ្យមសរុប៣០,៦% ក្នុងមួយឆ្នាំ។ ធនាគារបានពង្រីកខ្លួនយ៉ាងឆាប់រហ័សរហូតដល់៧ សាខានៅក្នុងប្រទេសកម្ពុជា និងវៀតណាម។ ទោះយ៉ាងណា ដោយសារស្ថានភាពមិនអនុគ្រោះនៅក្នុងប្រទេសកម្ពុជាពីចុងឆ្នាំ២០១៣ ដល់ចុងឆ្នាំ២០១៤ ប្រតិបត្តិការរបស់ធនាគារ BIDC រងផលប៉ះពាល់អវិជ្ជមានដែលបណ្តាលឱ្យមានអត្រាកំណើនយឺតយ៉ាវ។ តាមសេចក្តីជូនដំណឹងរបស់គណៈគ្រប់គ្រងធនាគារ BIDC ស្របតាមគោលបំណងចុងក្រោយនៃកំណើនប្រកបដោយនិរន្តរភាពរយៈពេលវែងក្នុងឆ្នាំ២០១៤ យើងមានវិធានការប្រកបដោយប្រសិទ្ធភាពនិងស័ក្តិសិទ្ធិភាពក្នុងការអនុវត្ត និងធានាប្រតិបត្តិការប្រកបដោយភាពល្អរបស់ធនាគារ BIDC។

- ទី១ មានការផ្លាស់ប្តូរយ៉ាងខ្លាំងចំពោះសកម្មភាពលក់រាយ និងការផ្លាស់ប្តូររបស់អតិថិជនគោលដៅពីកម្រិតមធ្យមដល់កម្រិតប្រាក់ចំណូល។
- ទី២ មានការកើនឡើងនូវផលិតផលផ្សេងៗរបស់ធនាគារ BIDC ដូចជាការដាក់ចេញនូវផលិតផល Scratch and Win 2014 Fixed-Deposit Promotional Saving Product ដែលទទួលបានការកោតសរសើរយ៉ាងខ្លាំងពីអតិថិជនដ៏មានតម្លៃរបស់យើង។
- ទី៣ ធនធានមនុស្សត្រូវបានចាត់ទុកថាជាកត្តាសំខាន់បំផុតសម្រាប់ភាពជោគជ័យក្នុងអតីតកាល និងអនាគតរបស់ធនាគារ BIDC។ ហេតុដូចនេះហើយ យើងបន្តលើកកម្ពស់ការជ្រើសរើសបុគ្គលិកនិងការបណ្តុះបណ្តាលកម្លាំងពលកម្មក្នុងស្រុក និងផ្លាស់ប្តូរតួនាទីផ្ទៃក្នុង

សំខាន់ៗ គ្រប់កម្រិតទាំងអស់។

- ទី៤ យើងវាយតម្លៃអំពីចំនួននិងប្រភេទហានិភ័យដោយប្រុងប្រយ័ត្នដែលនឹងត្រូវទទួលយកដោយធនាគារ BIDC ស្របតាមវត្ថុបំណងអាជីវកម្មរបស់ខ្លួន ហើយឃ្លាំមើលឱ្យបានជិតដល់ពីប្រព័ន្ធធនាគារ និងដំណើរការក្នុងការគ្រប់គ្រងហានិភ័យទាំងនោះ។
- ទី៥ យើងបានកសាងវប្បធម៌រួមគ្នាជាបន្តបន្ទាប់ និងបានបង្កើតទំនាក់ទំនងរវាងបុគ្គលិកធនាគារ និងអ្នកគ្រប់គ្រង។

បើទោះជាមានបញ្ហាប្រឈម និងការប្រកួតប្រជែងកើនឡើងនៅក្នុងឧស្សាហកម្មធនាគារ និងអស្ថិរភាពនយោបាយនៅក្នុងប្រទេសកម្ពុជានៅក្នុងឆ្នាំ២០១៤ ក៏ដោយ ក៏ប្រតិបត្តិការរបស់ធនាគារ BIDC នៅតែអាចគ្រប់គ្រងបានជាមួយនឹងអត្រាកំណើនដែលមានស្ថិរភាព បើប្រៀបធៀបទៅនឹងឆ្នាំ២០១៣។ នៅដំណាច់ឆ្នាំ២០១៤ ទ្រព្យសកម្មសរុបរបស់ធនាគារ BIDC មាន៥៩០លានដុល្លារអាមេរិក គឺកើនឡើងដល់១៩%ក្នុងរយៈពេលមួយឆ្នាំ កម្ចីដែលមិនទាន់សងមាន៤៣៣លានដុល្លារអាមេរិក កើនឡើង១៥% បើប្រៀបធៀបនឹងឆ្នាំ២០១៣ ហើយចំនួនបុគ្គលិកបានកើនឡើងដល់៣៥៥នាក់។

ធនាគារ BIDC បានពង្រីកខ្លួនយ៉ាងឆាប់រហ័សក្នុងរយៈពេល៦ឆ្នាំនេះដោយមានសាខាសរុបទាំងអស់ចំនួន៧សាខាទាំងក្នុងប្រទេសកម្ពុជានិងវៀតណាម។ ក្នុងចំណោមសាខាទាំងប្រាំពីរ សាខាបីស្ថិតក្នុងរាជធានីភ្នំពេញ ប្រទេសកម្ពុជា ដែលត្រូវគេចាត់ទុកថា ជាមជ្ឈមណ្ឌលសេដ្ឋកិច្ចនិងនយោបាយសម្រាប់ប្រទេសនេះ ហើយធនាគារ BIDC រំពឹងថា នឹងបង្កើតសាខាបន្ថែមទៀតនៅឆ្នាំខាងមុខដើម្បីបម្រើអតិថិជនរបស់យើងឱ្យបានល្អ។ជាមួយអង្គភាពពាក់ព័ន្ធគឺក្រុមហ៊ុនធានារ៉ាប់រងកម្ពុជា - វៀតណាម ភីអិលស៊ី (CVI) ដែលប្រតិបត្តិការសំខាន់គឺក្នុងវិស័យធានារ៉ាប់រងក្រៅពីអាយុជីវិតនោះ ធនាគារ BIDC និង CVI បានបង្កើតសង្វាក់គ្រប់គ្រងដើម្បីឆ្លើយតបទៅនឹងតម្រូវការជាច្រើនរបស់អតិថិជនក្នុងវិស័យធនាគារនិងធានារ៉ាប់រងដែលទីបំផុតនឹងលើកកម្ពស់ប្រសិទ្ធភាពអនុវត្តសម្រាប់ធនាគារ BIDC ។

ក្នុងឆ្នាំ២០១៥ យើងជឿថា ធនាគារ BIDC នឹងបន្តបោះជំហានទៅមុខក្នុងប្រតិបត្តិការអាជីវកម្ម ដើរតួនាទីសំខាន់ក្នុងទីផ្សារធនាគារ និងហិរញ្ញវត្ថុក្នុងប្រទេសកម្ពុជា បន្តពង្រីកបណ្ដាញ និងពង្រីកផលិតផលធនាគារនិងសេវាកម្មលើទីផ្សារកាន់តែខ្លាំង។

តាងនាមគណៈគ្រប់គ្រង ខ្ញុំសូមថ្លែងអំណរគុណដល់អតិថិជនរបស់យើងទាំងអស់ដែលបានជឿទុកចិត្តលើធនាគារ BIDC តាំងពីពេលនោះមក។ យើងប្តេជ្ញាចិត្តនៅទីនោះ ចែករំលែកនិងគាំទ្រអតិថិជនរបស់យើងក្នុងគ្រាលំបាក ហើយយើងតែងតែគោរពតម្លៃនៃភាពស្មោះត្រង់របស់អតិថិជនយើងជានិច្ច។ ខ្ញុំក៏ទទួលស្គាល់និងកោតសរសើរផងដែរចំពោះការរួមចំណែករបស់បុគ្គលិកដែលបានប្រឹងប្រែងនិងជួយក្នុងការអភិវឌ្ឍធនាគារ BIDC ។ ខ្ញុំមានមោទនភាពយ៉ាងខ្លាំងចំពោះអ្វីដែលធនាគារ BIDC សម្រេចបាន និងពិតជារំភើបរីករាយអំពីកាលនុវត្តភាពដែលនឹងកើតឡើងនៅពេលអនាគត។

Nguyen Dinh Duong

អគ្គនាយកប្រតិបត្តិ

# ការសហការគ្រប់គ្រង

# សមាជិកក្រុមប្រឹក្សាភិបាល







### លោក LE DAO NGUYEN

ប្រធានក្រុមប្រឹក្សាភិបាល

- កើតឆ្នាំ ១៩៥៦
- កម្រិតវប្បធម៌៖ បរិញ្ញាបត្រវិស្វកម្មក្រោយឧត្តមសិក្សាផ្នែកសេដ្ឋកិច្ច អនុបណ្ឌិតគ្រប់គ្រងពាណិជ្ជកម្ម
- បទពិសោធន៍៖ ៣០ឆ្នាំក្នុងវិស័យធនាគារ និងហិរញ្ញវត្ថុ។ ជោគជ័យក្នុងការទទួលបន្ទុកមុខតំណែងសំខាន់ជាច្រើនក្នុងវិស័យធនាគាររួមមាន៖ សមាជិកក្រុមប្រឹក្សាភិបាលនៃធនាគារ BIDV អគ្គនាយករងនៃធនាគារ BIDV ប្រធានក្រុមហ៊ុនគ្រប់គ្រងទ្រព្យសកម្មធនាគារ BIDV (BAMC) ប្រធានក្រុមហ៊ុនវិនិយោគហិរញ្ញវត្ថុធានាគារ BIDV (BFI) ប្រធានធនាគារឡាវ - វៀតណាម សមាជិកក្រុមប្រឹក្សាភិបាលហិរញ្ញវត្ថុជាតិវៀតណាមដៃគូវិនិយោគការគ្រប់គ្រងក្រុមហ៊ុន BIDV-Vietnam (BVIM) និងជាប្រធានក្រុមប្រឹក្សាភិបាលនៃធនាគារ BIDC នៅខែវិច្ឆិកា ឆ្នាំ២០១០

### លោក HOANG VAN VINH

អនុប្រធាន

កើតឆ្នាំ ១៩៦៤

- កម្រិតវប្បធម៌៖ បរិញ្ញាបត្រផ្នែកសេដ្ឋកិច្ច
- បទពិសោធន៍៖ មាជិកក្រុមប្រឹក្សាភិបាលធនាគារ BIDC ចាប់តាំងពីខែកក្កដា ឆ្នាំ២០១០

### លោក TRAN DINH DINH

សមាជិកឯករាជ្យនៃក្រុមប្រឹក្សាភិបាល

- កើតឆ្នាំ ១៩៤៥
- កម្រិតវប្បធម៌៖ បរិញ្ញាបត្រធានាគារ និងហរិញ្ញវត្ថុ
- បទពិសោធន៍៖ ៣៦ឆ្នាំក្នុងវិស័យធនាគារ និងហិរញ្ញវត្ថុ។ ជោគជ័យក្នុងវិស័យធនាគារ និងហិរញ្ញវត្ថុបាន:ជាអគ្គនាយករងនៃធនាគារកសិកម្ម និងអភិវឌ្ឍន៍ជនបទវៀតណាម និងជាសមាជិកក្រុមប្រឹក្សាភិបាលធនាគារ BIDC ចាប់ពីខែសីហា ឆ្នាំ២០០៩។



**លោក** PHAM VAN DUONG

**សមាជិកឯករាជ្យនៃក្រុមប្រឹក្សាភិបាល**

- កើតឆ្នាំ ១៩៧២
- កម្រិតវប្បធម៌៖ បរិញ្ញាបត្រគ្រប់គ្រងពាណិជ្ជកម្ម
- បទពិសោធន៍៖ សមាជិកក្រុមប្រឹក្សាភិបាល នៃធនាគារ BIDC ចាប់ពីខែសីហា ឆ្នាំ២០០៩



**លោកស្រី** TRAN THI OANH

**សមាជិកឯករាជ្យនៃក្រុមប្រឹក្សាភិបាល**

- កើតឆ្នាំ ១៩៦៤
- កម្រិតវប្បធម៌៖ បរិញ្ញាបត្រផ្នែកសេដ្ឋកិច្ច
- បទពិសោធន៍៖ មាជិកក្រុមប្រឹក្សាភិបាលធនាគារ BIDC ចាប់តាំងពីខែកក្កដា ឆ្នាំ២០១០



**លោក** NGUYEN VAN HIEN

**សមាជិកក្រុមប្រឹក្សាភិបាល**

- កើតឆ្នាំ ១៩៦១
- កម្រិតវប្បធម៌៖ អនុបណ្ឌិតផ្នែកវិទ្យាសាស្រ្តធនាគារ និងហិរញ្ញវត្ថុ
- បទពិសោធន៍៖ ជាង ២៥ ឆ្នាំក្នុងវិស័យធនាគារ និងជាសមាជិកក្រុមប្រឹក្សាភិបាល នៃធនា គា រ BIDC ចាប់ពីខែសីហា ឆ្នាំ២០០៩។



**លោក** DOAN ANH SANG

**សមាជិកក្រុមប្រឹក្សាភិបាល**

- កើតឆ្នាំ ១៩៦១
- កម្រិតវប្បធម៌៖ ជំនាញធនាគារ
- បទពិសោធន៍៖ ជាង ២៥ ឆ្នាំក្នុងវិស័យធនាគារ និងហិរញ្ញវត្ថុ សមាជិកក្រុមប្រឹក្សាភិបាលឆ្នាំ ២០១៤



**លោក** PHAN THANH HAI

**សមាជិកក្រុមប្រឹក្សាភិបាល**

- កើតឆ្នាំ១៩៧៧
- កម្រិតវប្បធម៌៖ អនុបណ្ឌិតផ្នែកធនាគារ និងហិរញ្ញវត្ថុ
- បទពិសោធន៍៖ ជាង ១៥ ឆ្នាំក្នុងវិស័យធនាគារ
ជាសមាជិកក្រុមប្រឹក្សាភិបាលក្នុងឆ្នាំ២០១៤



**លោក** NGUYEN DINH DUONG

**សមាជិកក្រុមប្រឹក្សាភិបាល**

- កើតឆ្នាំ ១៩៧៦
- កម្រិតវប្បធម៌៖ អនុបណ្ឌិតផ្នែកគ្រប់គ្រងពាណិជ្ជកម្ម នៅ CFVG Hanoi ក្នុងឆ្នាំ២០០០។ អនុបណ្ឌិតផ្នែកគ្រប់គ្រងពាណិជ្ជកម្មក្នុងការគ្រប់គ្រងបច្ចេកវិទ្យា AIT Thailand ក្នុងឆ្នាំ២០០១។
- បទពិសោធន៍៖ ប្រហែល ២០ ឆ្នាំក្នុងវិស័យធនាគា និងហិរញ្ញវត្ថុ។ សមាជិកក្រុមប្រឹក្សាភិបាល នៃធនាគារ BIDC ក្នុងឆ្នាំ២០១៤

# ការសហការគ្រប់គ្រង

## សេចក្តីសង្ខេបអំពីការសហការ



**លោក NGUYEN DINH DUONG**

**អគ្គនាយកប្រតិបត្តិ**

- កើតឆ្នាំ ១៩៧៦
- កម្រិតវប្បធម៌៖ អនុបណ្ឌិតផ្នែកគ្រប់គ្រងពាណិជ្ជកម្ម នៅ CFVG Hanoi ក្នុងឆ្នាំ២០០០។ អនុបណ្ឌិតផ្នែកគ្រប់គ្រងពាណិជ្ជកម្មក្នុងការគ្រប់គ្រងបច្ចេកវិទ្យា AIT Thailand ក្នុងឆ្នាំ២០០១។
- បទពិសោធន៍៖ ប្រហែល ២០ ឆ្នាំក្នុងវិស័យធនាគា និងហិរញ្ញវត្ថុ។ បានក្លាយសមាជិកក្រុមប្រឹក្សាភិបាល នៃធនាគារ BIDC ក្នុងឆ្នាំ២០១៣



**លោក PHAM HONG NHIEN**

**អគ្គនាយករង**

- កើតឆ្នាំ ១៩៧០
- កម្រិតវប្បធម៌៖ បរិញ្ញាបត្រផ្នែកធនាគារ និងហិរញ្ញវត្ថុ បរិញ្ញាបត្រផ្នែកគណិតវិទ្យា
- បទពិសោធន៍៖ បទពិសោធន៍ ២០ ឆ្នាំក្នុងវិស័យធនាគារ កាន់មុខតំណែងជាន់ខ្ពស់ជាច្រើនមុនពេលក្លាយជាអគ្គនាយករងនៃធនាគារB I D C នៅខែកញ្ញា ឆ្នាំ២០១២



**លោក ម៉ី គី**

**អគ្គនាយករង**

- កើតឆ្នាំ ១៩៥៩
- កម្រិតវប្បធម៌៖ អនុបណ្ឌិតផ្នែកច្បាប់
- បទពិសោធន៍៖ ជាង ២០ ឆ្នាំក្នុងវិស័យធនាគារ បានក្លាយជាអគ្គនាយករង នៃធនាគារ BIDC នៅខែសីហា ឆ្នាំ២០០៩



**លោកស្រី MAI THI NGOC HA**

**អគ្គនាយករង**

- កើតឆ្នាំ ១៩៦៣
- កម្រិតវប្បធម៌៖ បរិញ្ញាបត្រផ្នែកធនាគារ និងហិរញ្ញវត្ថុ បរិញ្ញាបត្រផ្នែកវិស្វកម្ម
- បទពិសោធន៍៖ ប្រហែល ២៥ ឆ្នាំក្នុងវិស័យធនាគារ បានក្លាយជាអគ្គនាយករង នៃធនាគារ BIDC នៅខែសីហា ឆ្នាំ២០០៩



**លោក DO VIET HUNG**

**អគ្គនាយករង**

- កើតឆ្នាំ ១៩៧៣
- កម្រិតវប្បធម៌៖ អនុបណ្ឌិតផ្នែកគ្រប់គ្រងពាណិជ្ជកម្ម
- បទពិសោធន៍៖ ជាង ២០ ឆ្នាំក្នុងវិស័យធនាគារបានក្លាយជាអគ្គនាយករង នៃធនាគារ BIDC នៅខែតុលា ឆ្នាំ២០១៤



**លោក Le Nam Trung**

- កើតឆ្នាំ ១៩៧៣
- កម្រិតវប្បធម៌៖ បរិញ្ញាបត្រផ្នែកសេដ្ឋកិច្ច
- បទពិសោធន៍៖ ជាង ១៥ ឆ្នាំក្នុងឧស្សាហកម្មផ្តល់សេវាហិរញ្ញវត្ថុ។ បានក្លាយជាអគ្គនាយករង នៃធនាគារ BIDCនៅឆ្នាំ២០១០-២០១៣និងត្រូវបានតែងតាំងឡើងវិញជាអគ្គនាយករងនៅខែធ្នូ ឆ្នាំ២០១៤

Be your side, by your hand



# របាយការណ៍របស់គណៈគ្រប់គ្រង

គណៈគ្រប់គ្រង ធនាគារវិនិយោគ និង អភិវឌ្ឍន៍ កម្ពុជា ភីអិលស៊ី (តទៅនេះហៅកាត់ថា"ធនាគារ" ឬ "BIDC") សូមបង្ហាញរបាយការណ៍របស់គណៈគ្រប់គ្រងនិងរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មសំរាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤។

## ព័ត៌មានអំពីធនាគារ

នៅថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៩ ធនាគារ Prosperity Investment Bank ហៅកាត់ថា ("PIB") ត្រូវបានទិញដោយ ក្រុមហ៊ុនវិនិយោគនិងអភិវឌ្ឍន៍កម្ពុជា លីមីតធីត ហៅកាត់ថា ("IDCC") ដែលជាក្រុមហ៊ុនមួយចុះបញ្ជីនៅ ប្រទេសកម្ពុជា និងដែលមានម្ចាស់ភាគហ៊ុនរួមគ្នា ២ គឺធនាគារវិនិយោគ និងអភិវឌ្ឍន៍វៀតណាម ("BIDV") (កាន់កាប់ភាគហ៊ុន ៨០%) និងក្រុមហ៊ុន Phuong Nam (កាន់កាប់ ភាគហ៊ុន ២០%)។ PIB បានកែទំរង់ និង ប្តូរឈ្មោះមកជា ធនាគារវិនិយោគនិងអភិវឌ្ឍន៍កម្ពុជា ភីអិលស៊ី ស្របតាមសេចក្តីសម្រេចលេខ ធ១-០៩-៥៥៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៩ ដោយអគ្គទេសាភិបាល នៃធនាគារជាតិនៃកម្ពុជា ("NBC") និងមានសុពលភាពចាប់ពីថ្ងៃទី១ ខែសីហា ឆ្នាំ២០០៩ តទៅ។

## ប្រតិបត្តិការចំបងរបស់ធនាគារ

ធនាគារផ្តល់សេវាគ្រប់ប្រភេទនៃអាជីវកម្មធនាគារនិងការផ្តល់សេវាកម្មហិរញ្ញវត្ថុពាក់ព័ន្ធផ្សេងៗទៀត។

ក្នុងអំឡុងឆ្នាំនេះ ពុំមានការប្រែប្រួលគួរឱ្យកត់សំគាល់ដែលទាក់ទងនឹងប្រតិបត្តិការជាចំបង របស់ធនាគារនោះទេ។

## លទ្ធផលហិរញ្ញវត្ថុ

លទ្ធផលហិរញ្ញវត្ថុរបស់ធនាគារ មានដូចខាងក្រោម៖

| | *២០១៤* | *២០១៣* |
|---|---|---|
| | *ដុល្លារអាមេរិក* | *ដុល្លារអាមេរិក* |
| **ប្រាក់ចំណេញ មុនបង់ពន្ធ** | **៦.០៧៤.៣៧៤** | **៥.៤៤៧.៥០៩** |
| ចំណាយពន្ធលើប្រាក់ចំណេញ | (១.៨៦១.៨៧៩) | (១.៣៩៦.២៧១) |
| **ប្រាក់ចំណេញក្រោយបង់ពន្ធ** | **៤.២១៦.៤៩៥** | **៤.០៥១.២៣៨** |
| **សមមូលពាន់រៀល** | **១៧.១៤២.២១៧** | **១៦.១៨៤.៦៩៣** |

## ដើមទុន

ធនាគារមានដើមទុនសរុប ៧០.០០០.០០០ ដុល្លារអាមេរិកគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ និងឆ្នាំ ២០១៣។

## ទុនបំរុង និង សំវិធានធន

ពុំមានការប្រែប្រួលជាសារវន្តទៅលើទុនបំរុង និងសំវិធានធននៅក្នុងការិយបរិច្ឆេទដែលបានបញ្ចប់នេះទេ ក្រៅពីអ្វីដែលបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុនេះ។

## របាយការណ៍របស់គណៈគ្រប់គ្រង (តពីទំព័រមុន)

### ឥណទាន និងបុរេប្រទានអាក្រក់ និងជាប់សង្ស័យ

មុនពេលដែលរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារត្រូវបានរៀបចំឡើង គណៈគ្រប់គ្រងធនាគារបានចាត់វិធានការសមស្របនានាដើម្បីអះអាងថាពួកគេបានចាត់វិធានការទាក់ទងទៅនឹងការលុបចោល ឥណទាន និងបុរេប្រទានអាក្រក់ និង ការធ្វើសំវិធានធនលើឥណទាននិងបុរេប្រទានអាក្រក់និងជាប់សង្ស័យ និង មានការជឿជាក់ថា រាល់ឥណទាន និងបុរេប្រទានអាក្រក់ត្រូវបានលុបចោល និងសំវិធានធនគ្រប់គ្រាន់ត្រូវកំណត់ឡើងសំរាប់ឥណទានអាក្រក់និងជាប់សង្ស័យ។

នៅកាលបរិច្ឆេទនៃរបាយកាណ៍នេះ គណៈគ្រប់គ្រងពុំបានដឹងពីហេតុការណ៍ណាមួយដែលនឹងបណ្តាលឲ្យចំនួនទឹកប្រាក់នៃឥណទាននិងបុរេប្រទានអាក្រក់ដែលបានលុបចោល ឬ ចំនួនទឹកប្រាក់សំវិធានធន លើឥណទាន និងបុរេប្រទានអាក្រក់ និងជាប់សង្ស័យនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារមានចំនួនមិនគ្រប់គ្រាន់រហូតដល់កំរិតទឹកប្រាក់ជាសារវន្តណាមួយនោះទេ។

### ទ្រព្យសកម្មចរន្ត

មុនការរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ គណៈគ្រប់គ្រងបានចាត់វិធានការសមស្របនានាដើម្បីធានាថា រាល់ទ្រព្យសកម្មក្រៅពីឥណទានដែលទំនងមិនអាចលក់បាន នៅក្នុងប្រតិបត្តិការអាជីវកម្មធម្មតាក្នុងតម្លៃដូចដែលបានកត់ត្រានៅក្នុងបញ្ជីគណនេយ្យរបស់ធនាគារនោះ ត្រូវបានកាត់បន្ថយឲ្យនៅស្មើនឹងតម្លៃដែលគិតថានឹងអាចលក់បានលើទីផ្សារ។

នាកាលបរិច្ឆេទនៃរបាយកាណ៍នេះ គណៈគ្រប់គ្រងធនាគារពុំបានដឹងពីហេតុការណ៍ណាមួយ ដែលនឹងបណ្តាលឲ្យប៉ះពាល់ដល់ការកំណត់តម្លៃនៃទ្រព្យសកម្មនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ មិនត្រឹមត្រូវជាសារវន្តនោះទេ។

### វិធីសាស្ត្រវាយតម្លៃ

នាកាលបរិច្ឆេទនៃរបាយកាណ៍ គណៈគ្រប់គ្រងធនាគារពុំបានដឹងពីព្រឹត្តិការណ៍ដែលបានកើតឡើងធ្វើឱ្យការអនុវត្តវិធីសាស្ត្រក្នុងការវាយតម្លៃទ្រព្យសកម្ម និងទ្រព្យអកម្មកន្លងមកនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារមានកំហុសឆ្គង ឬ មិនសមស្របជាសារវន្តនោះទេ។

### ទ្រព្យអកម្មយថាភាព និងទ្រព្យអកម្មផ្សេងៗ

នាកាលបរិច្ឆេទនៃរបាយការណ៍នេះ៖

- ពុំមានការដាក់បន្ទុកលើទ្រព្យសកម្មរបស់ធនាគារ ដែលកើតចេញពីការធានាបំណុលរបស់បុគ្គលដទៃគិតចាប់ពីកាលបរិច្ឆេទបញ្ចប់ឆ្នាំហិរញ្ញវត្ថុ។
- ពុំមានទ្រព្យអកម្មយថាភាពទាក់ទងនឹងធនាគារដែលបានកើតឡើង ចាប់ពីកាលបរិច្ឆេទបញ្ចប់ឆ្នាំហិរញ្ញវត្ថុ ក្រៅពីប្រតិបត្តិការអាជីវកម្មធម្មតារបស់ធនាគារ។

តាមមតិយោបល់របស់គណៈគ្រប់គ្រង ពុំមានទ្រព្យអកម្មយថាភាព ឬទ្រព្យអកម្មផ្សេងទៀតរបស់ធនាគារដែលបាន ឬទំនងនឹងក្លាយជាកាតព្វកិច្ចបំណុលក្នុងអំឡុង ១២ខែខាងមុខ បន្ទាប់ពីកាលបរិច្ឆេទបញ្ចប់ឆ្នាំហិរញ្ញវត្ថុនេះដែលនឹងមាន ឬអាចជះឥទ្ធិពលជាសារវន្តទៅលើលទ្ធភាពរបស់ធនាគារក្នុងការបំពេញកាតព្វកិច្ចបំណុលរបស់ខ្លួននៅពេលបំណុលទាំងនោះដល់ការកំណត់នោះទេ។

## របាយការណ៍របស់គណៈគ្រប់គ្រង (តពីទំព័រមុន)

### ព្រឹត្តិការណ៍ក្រោយកាលបរិច្ឆេទនៃរបាយការណ៍ស្តីពីស្ថានភាពហិរញ្ញវត្ថុ

ពុំមានព្រឹត្តិការណ៍ គួរឱ្យកត់សំគាល់ណាមួយបានកើតឡើង បន្ទាប់ពីកាលបរិច្ឆេទនៃរបាយកាណ៍ ហិរញ្ញវត្ថុ ដែលតម្រូវឱ្យមានការបង្ហាញ ឬនិយ័តកម្មក្រៅពីការបង្ហាញនៅក្នុងកំណត់សំគាល់ដែលភ្ជាប់មក ជាមួយ របាយការណ៍ហិរញ្ញវត្ថុនេះទេ។

### ក្រុមប្រឹក្សាភិបាល

សមាជិកក្រុមប្រឹក្សាភិបាល គិតចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០១៤ រហូតដល់កាលបរិច្ឆេទរបាយការណ៍នេះ រួមមាន៖

| *ឈ្មោះ* | *មុខតំណែង* | *កាលបរិច្ឆេទនៃការតែងតាំង ឬ លាឈប់* |
|---|---|---|
| លោក Le Dao Nguyen | ប្រធានក្រុមប្រឹក្សាភិបាល | តែងតាំងនៅថ្ងៃទី៦ ខែវិច្ឆិកា ឆ្នាំ២០១០ |
| លោក Hoang Van Vinh | អនុប្រធានក្រុមប្រឹក្សាភិបាល | តែងតាំងនៅថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០១០ |
| លោក Pham Van Duong | សមាជិកក្រុមប្រឹក្សាភិបាល | តែងតាំងនៅថ្ងៃទី១ ខែសីហា ឆ្នាំ២០០៩ |
| លោក Nguyen Van Hien | សមាជិកក្រុមប្រឹក្សាភិបាល | តែងតាំងនៅថ្ងៃទី១ ខែសីហា ឆ្នាំ២០០៩ |
| លោក Tran Dinh Dinh | សមាជិកក្រុមប្រឹក្សាភិបាល | តែងតាំងនៅថ្ងៃទី១ ខែសីហា ឆ្នាំ២០០៩ |
| លោកស្រី Tran Thi Oanh | សមាជិកក្រុមប្រឹក្សាភិបាល | តែងតាំងនៅថ្ងៃទី១ ខែសីហា ឆ្នាំ២០០៩ |
| លោក Doan Anh Sang | សមាជិកក្រុមប្រឹក្សាភិបាល | តែងតាំងនៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១២ |
| លោក Nguyen Dinh Duong | សមាជិកក្រុមប្រឹក្សាភិបាល | តែងតាំងនៅថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៣ |
| លោក Phan Thanh Hai | សមាជិកក្រុមប្រឹក្សាភិបាល | លាឈប់នៅថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៤ |
| លោក Tran Long | សមាជិកក្រុមប្រឹក្សាភិបាល | លាឈប់នៅថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៤ |

### គណៈគ្រប់គ្រង

សមាជិកគណៈគ្រប់គ្រង គិតចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០១៤ រហូតដល់កាលបរិច្ឆេទនៃរបាយការណ៍នេះ រួមមាន៖

| *ឈ្មោះ* | *មុខតំណែង* | *កាលបរិច្ឆេទនៃការតែងតាំង ឬ លាឈប់* |
|---|---|---|
| លោក Nguyen Dinh Duong | នាយកប្រតិបត្តិ | តែងតាំងនៅថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៣ |
| លោកស្រី Mai Thi Ngoc Ha | អនុប្រធានប្រតិបត្តិជាន់ខ្ពស់ | តែងតាំងនៅថ្ងៃទី១ ខែសីហា ឆ្នាំ២០០៩ |
| លោក Mey Phy | អនុប្រធានប្រតិបត្តិជាន់ខ្ពស់ | តែងតាំងនៅថ្ងៃទី១ ខែសីហា ឆ្នាំ២០០៩ |
| លោក Duong Van Co | អនុប្រធានប្រតិបត្តិជាន់ខ្ពស់ | តែងតាំងនៅថ្ងៃទី១ ខែឧសភា ឆ្នាំ២០១១ |
| លោក Pham Hong Nhien | អនុប្រធានប្រតិបត្តិជាន់ខ្ពស់ | តែងតាំងនៅថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១២ |
| លោក Do Viet Hung | អនុប្រធានប្រតិបត្តិជាន់ខ្ពស់ | តែងតាំងនៅថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១៤ |
| លោក Le Nam Trung | អនុប្រធានប្រតិបត្តិជាន់ខ្ពស់ | តែងតាំងនៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៤ |
| លោក Do Van Quyet | អនុប្រធានប្រតិបត្តិជាន់ខ្ពស់ | លាឈប់នៅថ្ងៃទី១ ខែមករា ឆ្នាំ២០១៥ |

## របាយការណ៍របស់គណៈគ្រប់គ្រង (តពីទំព័រមុន)

### សវនករ

ក្រុមហ៊ុនសវនករ Ernst & Young (Cambodia) Ltd. ជាសវនកររបស់ធនាគារ។

### អត្ថប្រយោជន៍របស់គណៈគ្រប់គ្រង

នៅក្នុង និងរហូតដល់ចុងការិយបរិច្ឆេទ នេះពុំមានការព្រមព្រៀងណាមួយ ដែលមានធនាគារចូលរួមជាគូភាគីក្នុងគោលបំណងជួយដល់គណៈគ្រប់គ្រងរបស់ធនាគារ ដើម្បីទទួលបាននូវអត្ថប្រយោជន៍ដោយការទិញយកភាគហ៊ុន ឬ លិខិត បំណុល ពីសាមីធនាគារ ឬ ពីក្រុមហ៊ុនដទៃទៀតទេ។

ពុំមានសមាជិកគណៈគ្រប់គ្រងណាមួយបានទទួល ឬ មានសិទ្ធិនឹងទទួលបាននូវអត្ថប្រយោជន៍ណាមួយ (ក្រៅពីអត្ថប្រយោជន៍ដែលបញ្ចូលជាតំលៃសរុបនៃលាភការបានទទួល ឬ នឹងត្រូវទទួលដោយគណៈគ្រប់គ្រង ឬ ប្រាក់បៀវត្សរ៍ថេរនៃការបំពេញមុខងារពេញម៉ោងដូចដែលបង្ហាញក្នុងកំណត់សំគាល់ ២៤(គ) នៃរបាយការណ៍ហិរញ្ញវត្ថុ) តាមរយៈការចុះកិច្ចសន្យាដែលបានធ្វើឡើងដោយធនាគារ ឬ ជាមួយនឹងក្រុមហ៊ុនដែលគណៈគ្រប់គ្រងជាសមាជិក ឬក៏ជាមួយក្រុមហ៊ុនដែលគណៈគ្រប់គ្រងនោះមានផលប្រយោជន៍ផ្នែកហិរញ្ញវត្ថុជាសារវន្ត។

### របាយការណ៍ស្តីពីការទទួលខុសត្រូវរបស់គណៈគ្រប់គ្រងលើរបាយការណ៍ហិរញ្ញវត្ថុ

គណៈគ្រប់គ្រងទទួលខុសត្រូវដើម្បីធានាអះអាងថា របាយការណ៍ហិរញ្ញវត្ថុពិតជាផ្តល់នូវទិដ្ឋភាពពិត និងត្រឹមត្រូវអំពីស្ថានភាពហិរញ្ញវត្ថុរបស់ធនាគារនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ និងលទ្ធផលនៃប្រតិបត្តិការហិរញ្ញវត្ថុ ហើយនិងលំហូរសាច់ប្រាក់សំរាប់ការិយបរិច្ឆេទដែលបានបញ្ចប់។ ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ គណៈគ្រប់គ្រងត្រូវបានតម្រូវឲ្យ៖

- ទទួលយកនូវគោលនយោបាយគណនេយ្យសមស្រប ដែលគាំទ្រដោយការវិនិច្ឆ័យ និងការប៉ាន់ស្មានដ៏សមហេតុផលនិងប្រុងប្រយ័ត្ន ហើយអនុវត្តគោលនយោបាយទាំងនោះយ៉ាងជាប់លាប់។
- អនុវត្តតាមស្តង់ដារគណនេយ្យកម្ពុជា និងគោលការណ៍ណែនាំ និងបទបញ្ញត្តិចេញដោយធានាគារជាតិនៃកម្ពុជា ឬ ប្រសិនបើមានការងាកចេញពីស្តង់ដារដើម្បីជាប្រយោជន៍ដល់ការបង្ហាញទិដ្ឋភាពពិត និងត្រឹមត្រូវរបស់របាយការណ៍ហិរញ្ញវត្ថុ ធានាថាលំងាកចេញពីស្តង់ដារទាំងនេះត្រូវបានបង្ហាញ ពន្យល់និងកំណត់ជាចំនួនទឹកប្រាក់ក្នុងរបាយការណ៍ហិរញ្ញវត្ថុ។
- រក្សាទុកបញ្ជីគណនេយ្យឲ្យបានគ្រប់គ្រាន់និងប្រព័ន្ធនៃការត្រួតពិនិត្យផ្ទៃក្នុងឲ្យមានប្រសិទ្ធិភាពនិង
- រៀបចំរបាយការណ៍ហិរញ្ញវត្ថុ ដោយឈរលើមូលដ្ឋាននិរន្តរភាពនៃដំណើរការអាជីវកម្មលុះត្រាតែមានភាពមិនសមស្របថាធនាគារអាចបន្តអាជីវកម្មនាពេលអនាគតដែលអាចគិតទុកជាមុនបាន។

គណៈគ្រប់គ្រងទទួលខុសត្រូវរក្សាទុកកំណត់ត្រាគណនេយ្យសមស្របគ្រប់ពេលវេលា ដែលបង្ហាញពីភាពត្រឹមត្រូវសមហេតុផលនៃស្ថានភាពហិរញ្ញវត្ថុរបស់ធនាគារ និងធានាថាកំណត់ត្រាទាំងនោះ អនុលោមតាមប្រព័ន្ធគណនេយ្យដែលចុះបញ្ជី។ គណៈគ្រប់គ្រង ក៏ទទួលខុសត្រូវផងដែរចំពោះការថែរក្សាទ្រព្យសកម្មរបស់ធនាគារ ដូច្នេះគណៈគ្រប់គ្រងបានចាត់វិធានការសមស្របក្នុងការទប់ស្កាត់ និងស្វែងរកកំហុសចេតនា ការក្លែងបន្លំ និងភាពមិនប្រក្រតីផ្សេងៗ។

គណៈគ្រប់គ្រងសូមបញ្ជាក់ថា ធនាគារបានអនុវត្តស្របតាមតម្រូវដូចបានរៀបរាប់ខាងលើក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ។

# ធនាគារវិនិយោគ និងអភិវឌ្ឍន៍កម្ពុជា ភីអិលស៊ី

## របាយការណ៍របស់គណៈគ្រប់គ្រង (តពីទំព័រមុន)

## សេចក្តីប្រកាសដោយគណៈគ្រប់គ្រង

យោងតាមមតិយោបល់ យើងខ្ញុំជាគណៈគ្រប់គ្រងសូមធ្វើការអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុ ថាពិតជាបានផ្តល់នូវទិដ្ឋភាពពិត និងត្រឹមត្រូវនៃស្ថានភាពហិរញ្ញវត្ថុរបស់ធនាគារនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ និងលទ្ធផលនៃប្រតិបត្តិការហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់សំរាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ដោយអនុលោមទៅតាមស្តង់ដារគណនេយ្យកម្ពុជា និង បទបញ្ញត្តិដែលពាក់ព័ន្ធនិងគោលការណ៍ណែនាំចេញផ្សាយដោយធនាគារជាតិនៃកម្ពុជា។

តំណាងគណៈគ្រប់គ្រង

លោក Nguyen Dinh Duong

នាយកប្រតិបត្តិ

ធ្វើនៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៥

EY
Building a better working world

Ernst & Young (Cambodia) Ltd.
3rd Floor, SSN Center
#66 Norodom Boulevard
Sangkat Chey Chumneas, Khan Daun Penh
12206 Phnom Penh, Kingdom of Cambodia

Tel: +855 23 217 824/ 825
Fax: +855 23 217 805
ey.com

យោង: ៦១០៥០១០៥/១៧៨៧៣៨១៨

# របាយការណ៍របស់សវនករឯករាជ្យ

## ជូនចំពោះ ភាគទុនិកនៃធនាគារវិនិយោគ និងអភិវឌ្ឍន៍កម្ពុជា ភីអិលស៊ី

យើងខ្ញុំបានធ្វើសវនកម្មទៅលើរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារវិនិយោគ និងអភិវឌ្ឍន៍កម្ពុជា ភីអិលស៊ី (ធនាគារ) ដែលរួមមានតារាងតុល្យការនៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ និងរបាយការណ៍លទ្ធផល របាយការណ៍បំរែបំរួលមូលធន របាយការណ៍លំហូរសាច់ប្រាក់សំរាប់ការិយបរិច្ឆេទបញ្ចប់ និងគោលនយោបាយគណនេយ្យសំខាន់ៗ និងកំណត់សំគាល់ផ្សេងៗទៀត។

### ***ការទទួលខុសត្រូវរបស់គណៈគ្រប់គ្រងចំពោះរបាយការណ៍ហិរញ្ញវត្ថុ***

គណៈគ្រប់គ្រងរបស់ធនាគារជាអ្នកទទួលខុសត្រូវចំពោះការរៀបចំ និងការបង្ហាញទិដ្ឋភាពពិតប្រាកដនៃរបាយការណ៍ហិរញ្ញវត្ថុ ដោយអនុលោមទៅតាមស្តង់ដារគណនេយ្យកម្ពុជា ហើយនិងបទបញ្ញត្តិ និង គោលការណ៍ណែនាំដែលចេញដោយធនាគារជាតិនៃកម្ពុជា ហើយនិងទទួលខុសត្រូវដូចគ្នាផងដែរចំពោះ ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងដែលគណៈគ្រប់គ្រងគិតថា មានសារៈប្រយោជន៍ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ដែលពុំមានកំហុសឆ្គងជាសារវន្តដែលបណ្តាលមកពីការក្លែងបន្លំ ឬ ការភាន់ច្រឡំ។

### ***ការទទួលខុសត្រូវរបស់សវនករ***

ការទទួលខុសត្រូវរបស់យើងខ្ញុំគឺបញ្ចេញមតិយោបល់លើរបាយការណ៍ហិរញ្ញវត្ថុនេះដោយផ្អែកលើមូលដ្ឋាននៃការងារសវនកម្ម។ យើងខ្ញុំបានធ្វើការងារសវនកម្ម ដោយអនុលោមទៅតាមស្តង់ដារអន្តរជាតិស្តីពីសវនកម្មនៃកម្ពុជា។ ស្តង់ដារទាំងនេះតំរូវឲ្យយើងខ្ញុំ អនុវត្តតាមតំរូវការនៃក្រមសីលធម៌ និងរៀបចំផែនការ និងបំពេញការងារសវនកម្មដើម្បីទទួលបានការធានាសមហេតុផលដើម្បីអះអាងថារបាយការណ៍ហិរញ្ញវត្ថុពុំមានកំហុសឆ្គងជាសារវន្តឡើយ។

ការងារសវនកម្មយើងខ្ញុំរួមមាន ការអនុវត្តនីតិវិធីទាំងឡាយដើម្បីទទួលបាននូវភស្តុតាងដែលទាក់ទងទៅនឹងបរិមាណទឹកប្រាក់និងការបង្ហាញទាំងឡាយនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។ រាល់នីតិវិធីដែលយើងខ្ញុំបាន ជ្រើសរើសនាងលើគឺពឹងផ្អែកទៅលើការវិនិច្ឆ័យរបស់សវនករ ដោយរាប់បញ្ចូលនូវការវាយតំលៃលើហានិភ័យនៃភាពខុសឆ្គងជាសារវន្តនៃរបាយការណ៍ហិរញ្ញវត្ថុដែលបណ្តាល មកពីការក្លែងបន្លំ ឬ ការភាន់ច្រឡំ។ ក្នុងការវាយតំលៃលើហានិភ័យទាំងនោះ យើងខ្ញុំបានពិនិត្យលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងដែលពាក់ព័ន្ធនឹងការ រៀបចំនិងការបង្ហាញពីទិដ្ឋភាពពិតប្រាកដនៃរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារដើម្បីរៀបចំនីតិវិធីសវនកម្ម ដែលសមស្របទៅតាមកាលៈទេសៈ ប៉ុន្តែការវាយតំលៃទាំងនេះមិនមែនសំរាប់គោលបំណងបញ្ចេញមតិ យោបល់លើប្រសិទ្ធិភាពនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងរបស់ធនាគារទេ។ ការងារសវនកម្មរបស់យើងខ្ញុំ ក៏រួមបញ្ចូល ផងដែរនូវការវាយតំលៃភាពសមស្របនៃ គោលនយោបាយគណនេយ្យដែលបានប្រើប្រាស់ និងភាពសមហេតុ សមផលនៃការប៉ាន់ស្មានគណនេយ្យសំខាន់ៗដែលធ្វើឡើងដោយគណៈគ្រប់គ្រង ព្រមទាំង ការវាយតំលៃលើការ បង្ហាញនៃរបាយការណ៍ហិរញ្ញវត្ថុទាំងមូល។

យើងខ្ញុំជឿជាក់ថាភស្តុតាងសវនកម្មដែលយើងខ្ញុំបានទទួលមានលក្ខណៈគ្រប់គ្រាន់និងសមហេតុផល ដើម្បីជាមូលដ្ឋានក្នុងការបញ្ចេញមតិយោបល់របស់យើងខ្ញុំ។

EY
Building a better
working world

***មតិយោបល់របស់សវនករ***

តាមមតិយោបល់របស់យើងខ្ញុំ របាយការណ៍ហិរញ្ញវត្ថុនេះបង្ហាញនូវទិដ្ឋភាពពិតប្រាកដ និងត្រឹមត្រូវពីស្ថានភាពហិរញ្ញវត្ថុរបស់ធនាគារនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់របស់ធនាគារ សំរាប់ការិយបរិច្ឆេទបញ្ចប់ ដោយអនុលោមទៅតាមស្តង់ដារគណនេយ្យកម្ពុជា ហើយនិងបទបញ្ញត្តិ និងគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជា។

Maria Cristina M. Calimbas
Partner

**Ernst & Young (Cambodia) Ltd.**
ក្រុមហ៊ុនគណនេយ្យករជំនាញនិងសវនករប្រតិស្រុត

ធ្វើនៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៥

## តារាងតុល្យការ

នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤

| | កំណត់សំគាល់ | ២០១៤ ដុល្លារអាមេរិក | ២០១៤ សមមូលពាន់រៀល (កំណត់សំគាល់ ២.១.៥) | ២០១៣ ដុល្លារអាមេរិក (បង្ហាញឡើងវិញ) | ២០១៣ សមមូលពាន់រៀល (កំណត់សំគាល់ ២.១.៥) (បង្ហាញឡើងវិញ) |
|---|---|---|---|---|---|
| **ទ្រព្យសកម្ម** | | | | | |
| សាច់ប្រាក់ក្នុងដៃ | ៣ | ៥.៦៣១.៥៨០ | ២២.៩៤៨.៦៨៩ | ៣.៦៩៩.២៤៥ | ១៤.៧៧៨.៤៨៤ |
| សមតុល្យនៅធនាគារកណ្តាល | ៤ | ៦០.៨៤៧.២៤៧ | ២៤៧.៩៥២.៥៣២ | ៥២.៧៥៣.១៨១ | ២១០.៧៤៨.៩៥៨ |
| សមតុល្យនៅស្ថាប័នហិរញ្ញវត្ថុផ្សេងៗ | ៥ | ៥០.៦៧១.២៤០ | ២០៦.៤៨៥.៣០៣ | ៤៨.២១៩.២៧៣ | ១៩២.៦៣៥.៩៩៦ |
| ឥណទាន និង បុរេប្រទានទៅអតិថិជន | ៦ | ៤៣២.៥១៥.០៧៦ | ១.៧៦២.៤៩៨.៩៣៥ | ៣៦៧.៦២៥.៥៣២ | ១.៤៦៨.៦៦៤.០០២ |
| ការវិនិយោគលើមូលបត្រ | ៧ | ១០.៩១៥.០០២ | ៤៤.៤៧៨.៦៣៣ | ១១.៥០៧.៤០២ | ៤៥.៩៧២.០៧១ |
| ទ្រព្យ និងបរិក្ខារ | ៨ | ៤.៤១៥.២៩៦ | ១៧.៩៩២.៣៣១ | ៤.១៩០.៧៨២ | ១៦.៧៤២.១៧៤ |
| ទ្រព្យអរូបិយ | ៩ | ២.១៦២.០៧៨ | ៨.៨១០.៤៦៨ | ២.៤៥២.៥៩៦ | ៩.៧៩៨.១២១ |
| ទ្រព្យសកម្មផ្សេងៗ | ១០ | ២២.៦៧៩.៧៣៤ | ៩២.៤១៩.៩១៦ | ៥.៦៨៤.១៣៤ | ២២.៧០៨.១១៥ |
| **ទ្រព្យសកម្មសរុប** | | **៥៨៩.៨៣៧.២៥៣** | **២.៤០៣.៥៨៦.៨០៧** | **៤៩៦.១៣២.១៤៥** | **១.៩៨២.០៤៧.៩២០** |
| **ទ្រព្យអកម្ម** | | | | | |
| ប្រាក់បញ្ញើរបស់ស្ថាប័នហិរញ្ញវត្ថុផ្សេងៗ | ១១ | ៣០០.៧៨៨.៥៥៨ | ១.២២៥.៧១៣.៣៧៤ | ២៦០.៩៣៣.៩៧១ | ១.០៤២.៤៣១.២១៤ |
| ប្រាក់បញ្ញើរបស់អតិថិជន | ១២ | ១៩៦.៥៩៦.៨៥៨ | ៨០១.១៣២.១៩៦ | ១៤៨.៤៨១.២៤៥ | ៥៩៣.១៨២.៥៧៤ |
| បំណុលពន្ធលើប្រាក់ចំណេញ | ១៣ | ១.១២៨.៧១៤ | ៤.៥៩៩.៥១០ | ៥១៨.៥២៦ | ២.០៧១.៥១២ |
| ទ្រព្យអកម្មផ្សេងៗ | ១៤ | ៥.២២៣.១៤៦ | ២១.២៨៤.៣២១ | ៤.១០៣.១២៣ | ១៦.៣៩១.៩៧៦ |
| **ទ្រព្យអកម្មសរុប** | | **៥០៣.៧៣៧.២៧៦** | **២.០៥២.៧២៩.៤០១** | **៤១៤.០៣៦.៨៦៥** | **១.៦៥៤.០៧៧.២៧៦** |
| **មូលធនម្ចាស់ភាគហ៊ុន** | | | | | |
| ដើមទុនបានបង់ | ១៥ | ៧០.០០០.០០០ | ២៨៥.២៥០.០០០ | ៧០.០០០.០០០ | ២៧៩.៦៥០.០០០ |
| ការបំរុងទុកពីការប្រែសំរួលអត្រាប្តូរប្រាក់បរទេស | | (១៩.៤៣៦) | (៧៩.២០២) | (៧.៦៣៨) | (៣០.៥១៤) |
| ទុនបំរុងទូទៅ | ១៥ | ២.៥៤៩.៧២៣ | ១០.៣៩០.១២១ | ១.៩៦២.២៩០ | ៧.៨៣៩.៣៤៩ |
| ប្រាក់ចំណេញរក្សាទុក | | ១៣.៥៦៩.៦៩០ | ៥៥.២៩៦.៤៨៧ | ១០.១៤០.៦២៨ | ៤០.៥១១.៨០៩ |
| **មូលធនម្ចាស់ភាគហ៊ុនសរុប** | | **៨៦.០៩៩.៩៧៧** | **៣៥០.៨៥៧.៤០៦** | **៨២.០៩៥.២៨០** | **៣២៧.៩៧០.៦៤៤** |
| **ទ្រព្យអកម្ម និង មូលធន ម្ចាស់ភាគហ៊ុនសរុប** | | **៥៨៩.៨៣៧.២៥៣** | **២.៤០៣.៥៨៦.៨០៧** | **៤៩៦.១៣២.១៤៥** | **១.៩៨២.០៤៧.៩២០** |

## របាយការណ៍លទ្ធផល

សំរាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤

| | កំណត់សំគាល់ | ២០១៤<br>ដុល្លារអាមេរិក | ២០១៤<br>សមមូលពាន់រៀល (កំណត់សំគាល់ ២.១.៥) | ២០១៣<br>ដុល្លារអាមេរិក (បង្ហាញឡើងវិញ) | ២០១៣<br>សមមូលពាន់រៀល (កំណត់សំគាល់ ២.១.៥) (បង្ហាញឡើងវិញ) |
|---|---|---|---|---|---|
| ចំណូលការប្រាក់ និង ចំណូលប្រហាក់ប្រហែល | ១៦ | ៣៣.៩៦៧.៥១៦ | ១៣៨.៤១៧.៦២៨ | ៣៥.៧០០.៧០២ | ១៤២.៦២៤.៣០៤ |
| ចំណាយការប្រាក់ និង ចំណាយប្រហាក់ប្រហែល | ១៧ | (១៥.៣៣៣.៣៦៤) | (៦២.៤៨៣.៤៧៥) | (១៦.៣៤២.៣៦១) | (៦៥.២៨៧.៧៣៣) |
| **ចំណូលការប្រាក់ និង ចំណូលប្រហាក់ប្រហែល សុទ្ធ** | | **១៨.៦៣៤.១៥២** | **៧៥.៩៣៤.១៥៣** | **១៩.៣៥៨.៣៤១** | **៧៧.៣៣៦.៥៧១** |
| ចំណូលពីកំរៃជើងសារ និងកំរៃជើងសារ | ១៨ | ២.៧៦៣.៣៥៦ | ១១.២៦០.៦៧៦ | ៣.១០១.៨៤៤ | ១២.៣៩១.៨៦៧ |
| ចំណាយពីកំរៃឈ្នួល និងកំរៃជើងសារ | | (២៧៧.៣៥៨) | (១.១៣០.២៣៤) | (២៨៨.៤៩១) | (១.១៥២.៥២២) |
| **ចំណូលពីកំរៃឈ្នួល និង កំរៃជើងសារ សុទ្ធ** | | **២.៤៨៥.៩៩៨** | **១០.១៣០.៤៤២** | **២.៨១៣.៣៥៣** | **១១.២៣៩.៣៤៥** |
| **ខាតសុទ្ធពីការប្តូរប្រាក់បរទេស** | | (៧០.៦០២) | (២៨៧.៧០៣) | - | - |
| **ចំណូលពីសកម្មភាពផ្សេងៗ** | ១៩ | ១៦៨.៩០៩ | ៦៨៨.៣០៤ | ៧៥.០២៤ | ២៩៩.៧២១ |
| **ចំណូលប្រតិបត្តិការសរុប** | | **២១.២១៨.៤៥៧** | **៨៦.៤៦៥.១៩៦** | **២២.២៤៦.៧១៨** | **៨៨.៨៧៥.៦៣៧** |
| ចំណាយទូទៅ និង រដ្ឋបាល | ២០ | (១២.២៧៧.៦៩៩) | (៥០.០៣១.៦២៣) | (១១.៤០៤.២១៤) | (៤៥.៥៥៩.៨៣៥) |
| សំវិធានធនសំរាប់ការខាតបង់លើឥណទាន - សុទ្ធ | ២១ | (២.៨៦២.៣៨០) | (១១.៦៦៤.១៩៩) | (៥.៣៩៤.៩៩៥) | (២១.៥៥៣.០០៥) |
| **ចំណេញមុនបង់ពន្ធ** | | **៦.០៧៨.៣៧៨** | **២៤.៧៦៩.៣៧៤** | **៥.៤៤៧.៥០៩** | **២១.៧៦២.៧៩៧** |
| ពន្ធលើប្រាក់ចំណេញ | ១៣ | (១.៨៦១.៨៧៩) | (៧.៥៨៧.១៥៧) | (១.៣៩៦.២៧១) | (៥.៥៧៨.១០៨) |
| **ចំណេញសុទ្ធសំរាប់ការិយបរិច្ឆេទ** | | **៤.២១៦.៤៩៩** | **១៧.១៨២.២១៧** | **៤.០៥១.២៣៨** | **១៦.១៨៤.៦៨៩** |

## របាយការណ៍បំរែបំរួលមូលធន

### សំរាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤

| | ដើមទុនបានបង់<br>*ដុល្លារអាមេរិក* | ទុនបំរុងសំរាប់ការប្រែប្រួលអត្រាប្តូរប្រាក់បរទេស<br>*ដុល្លារអាមេរិក* | ទុនបំរុងទូទៅ<br>*ដុល្លារអាមេរិក*<br>*(បង្ហាញឡើងវិញ)* | ប្រាក់ចំណេញរក្សាទុក<br>*ដុល្លារអាមេរិក* | សរុប<br>*ដុល្លារអាមេរិក* |
|---|---|---|---|---|---|
| **សមតុល្យត្រឹមថ្ងៃទី១ ខែមករា ឆ្នាំ២០១៣** | ៧០.០០០.០០០ | - | ៨៥៤.៥៩៥ | ១១.៥២៣.៦៤០ | ៨២.៣៧៨.២៣៥ |
| ប្រាក់បំរុងទុកសំរាប់ទុនបំរុង | - | - | ១.១០៧.៦៩៥ | (១.១០៧.៦៩៥) | - |
| ប្រាក់បំរុងទុកសំរាប់មូលនិធិប្រាក់រង្វាន់ និងសុខុមាលភាពបុគ្គលិក | - | - | - | (៣២៦.៥៥៥) | (៣២៦.៥៥៥) |
| ការផ្ទេរប្រាក់ចំណេញទៅក្រុមហ៊ុនមេ | - | - | - | (៤.០០០.០០០) | (៤.០០០.០០០) |
| ប្រាក់ចំណេញសុទ្ធសំរាប់ការិយបរិច្ឆេទ | - | - | - | ៤.០៥១.២៣៨ | ៤.០៥១.២៣៨ |
| លំអៀងពីការប្រែប្រួលអត្រាប្តូរប្រាក់ | - | (៧.៦៣៨) | - | - | (៧.៦៣៨) |
| **សមតុល្យត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣** | **៧០.០០០.០០០** | **(៧.៦៣៨)** | **១.៩៦២.២៩០** | **១០.១៤០.៦២៨** | **៨២.០៩៥.២៨០** |
| **សមមូលពាន់រៀល** (កំណត់សំគាល់លេខ២.១.៥) | **២៧៩.៦៥០.០០០** | **(៣០.៥១៤)** | **៧.៨៣៩.៣៤៩** | **៤០.៥១១.៨០៩** | **៣២៧.៩៧០.៦៤៤** |
| ប្រាក់បំរុងទុកសំរាប់ទុនបំរុង | - | - | ៥៤៧.៤៣៣ | (៥៤៧.៤៣៣) | - |
| ប្រាក់បំរុងទុកសំរាប់មូលនិធិប្រាក់រង្វាន់ និងសុខុមាលភាពបុគ្គលិក | - | - | - | (២០០.០០០) | (២០០.០០០) |
| ប្រាក់ចំណេញសុទ្ធសំរាប់ការិយបរិច្ឆេទ | - | - | - | ៤.២១៦.៤៥៥ | ៤.២១៦.៤៥៥ |
| លំអៀងពីការប្រែប្រួលអត្រាប្តូរប្រាក់ | - | (១១.៧៩៨) | - | - | (១១.៧៩៨) |
| **សមតុល្យត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤** | **៧០.០០០.០០០** | **(១៩.៤៣៦)** | **២.៥០៩.៧២៣** | **១៣.៦០៩.៦៥០** | **៨៦.០៩៩.៩៣៧** |
| **សមមូលពាន់រៀល** *(កំណត់សំគាល់២.១.៥)* | **២៨៥.២៥០.០០០** | **(៧៩.២០២)** | **១០.៣៩០.១២១** | **៥៥.២៩៦.៨៨៧** | **៣៥០.៨៥៧.៨០៦** |

# របាយការណ៍លំហូរសាច់ប្រាក់

## សំរាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤

| | កំណត់សំគាល់ | ២០១៤ *ថ្លៃរំលស់* | ២០១៤ *សមមូលការប្រាក់រៀល (កំណត់សំគាល់ ២.១.៥)* | ២០១៣ *ថ្លៃរំលស់ (បង្ហាញឡើងវិញ)* | ២០១៣ *សមមូលការប្រាក់រៀល (កំណត់សំគាល់ ២.១.៥) (បង្ហាញឡើងវិញ)* |
|---|---|---|---|---|---|
| **សាច់ប្រាក់សុទ្ធបានពីសកម្មភាពប្រតិបត្តិការ** | ២២ | **២៥៤.០៨១** | **១.០៣៥.៣៨០** | **១៣.៥៧២.៣៤៤** | **៥៤.២២១.៥១១** |
| **លំហូរសាច់ប្រាក់ពីសកម្មភាពវិនិយោគ** | | | | | |
| ការទិញបន្ថែមទ្រព្យ និងបរិក្ខារ | ៨.១ | (៣៨៧.៣០៦) | (១.៥៧៨.២៧២) | (១៧៤.៧០៥) | (៦៩៧.៨៨៦) |
| ការទិញបន្ថែមទ្រព្យអរូបិយ | | - | - | (៣៧.៧២០) | (១៥០.៦៨១) |
| ការលក់ទ្រព្យ និងបរិក្ខារ | | - | - | ២៦.៤០០ | ១០៥.៨៦៨ |
| ការទូទាត់លើសំណង់កំពុងសាងសង់ | ៨.២ | (៨៧៤.៨៧១) | (៣.៥៦៥.០៩៩) | (១.៥៤៣.៩២៩) | (៦.៣២៧.៧៦៦) |
| **សាច់ប្រាក់សុទ្ធប្រើប្រាស់ក្នុងសកម្មភាពវិនិយោគ** | | **(១.២៦២.១៧៧)** | **(៥.១៤៣.៣៧១)** | **(១.៧២៩.៩៥៤)** | **(៧.០៧០.៤៦៥)** |
| (ការថយចុះ)ការកើនឡើងសុទ្ធនៃសាច់ ប្រាក់ និងសាច់ប្រាក់សមមូល | | (១.០០៨.០៩៦) | (៤.១០៧.៩៩១) | ១១.៨៤២.៣៩០ | ៤៧.១៥០.៥៨៦ |
| សមតុល្យសាច់ប្រាក់នៅដើមការិយបរិច្ឆេទ | ៣ | ៤២.៩៥២.១១៧ | ៣៣១.៣៩៣.៧០៨ | ៣១.០៤៥.៣៧២ | ២៨៣.៩៨៦.០៦១ |
| លំអៀងអត្រាប្តូរប្រាក់បរទេស | | ១០៤.០១០ | ៧.០៦០.០១០ | ៦៤.៣៥៥ | ២៥៧.១០១ |
| **សាច់ប្រាក់និងសាច់ប្រាក់សមមូលនៅចុងការិយបរិច្ឆេទ** | ៣ | **៤២.០៤៨.០៣១** | **៣៣៤.៣៤៥.៧២៧** | **៤២.៩៥២.១១៧** | **៣៣១.៣៩៣.៧០៨** |

## កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ

សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤

### ១. ព័ត៌មានអំពីធនាគារ

ធនាគារវិនិយោគ និងអភិវឌ្ឍន៍កម្ពុជា ភីអិលស៊ី (តទៅនេះហៅកាត់ថា"ធនាគារ" ឬ "BIDC") បានចុះបញ្ជីអាជីវកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

***ការបង្កើតឡើង និងប្រតិបត្តិការ***

នៅថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ២០០៩ ធនាគារ Prosperity Invesment Bank ហៅកាត់ថា ("PIB") ត្រូវបានទិញ ដោយក្រុមហ៊ុនវិនិយោគ និងអភិវឌ្ឍន៍កម្ពុជា លីមីតធីត ហៅកាត់ថា ("IDCC") ដែលជាក្រុមហ៊ុនមួយបានចុះបញ្ជីនៅប្រទេសកម្ពុជា និងដែលមានម្ចាស់ភាគហ៊ុនរួមគ្នា២ គឺ ធនាគារវិនិយោគ និងអភិវឌ្ឍន៍ វៀតណាម ("BIDV") (កាន់កាប់ភាគហ៊ុន ៨០%) និងក្រុមហ៊ុន Phuong Nam (កាន់កាប់ភាគហ៊ុន ២០%)។ PIB បានកែទំរង់និងប្តូរឈ្មោះមកជា ធនាគារវិនិយោគ និងអភិវឌ្ឍន៍កម្ពុជា ភីអិលស៊ី ស្របតាមសេចក្តីសម្រេចលេខ ធ១-០៩-៥៥៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៩ ចេញដោយអគ្គទេសាភិបាលនៃធនាគារជាតិនៃកម្ពុជា ("NBC")។ ប្រតិបត្តិការមាន សុពលភាពចាប់ពីថ្ងៃទី១ ខែសីហា ឆ្នាំ២០០៩ តទៅ។

ធនាគារវិនិយោគ និងអភិវឌ្ឍន៍កម្ពុជា ភីអិលស៊ី គឺជាស្ថាប័នហិរញ្ញវត្ថុមួយដែលធ្វើប្រតិបត្តិការស្របតាមច្បាប់ និងបទបញ្ញត្តិរបស់ធនាគារជាតិនៃកម្ពុជា។ ប្រតិបត្តិការរបស់ធនាគារ មានការគាំទ្រដោយផ្ទាល់ពីធនាគារវិនិយោគ និងអភិវឌ្ឍន៍វៀតណាម ("BIDV") ដែលជាធនាគារធំមួយនៅក្នុងប្រទេសវៀតណាមដែលផ្តល់សេវាកម្មផ្នែកធនាគារច្រើនជាង ៥០ឆ្នាំមកហើយ។ ធនាគារវិនិយោគ និងអភិវឌ្ឍន៍វៀតណាម ជួយគាំទ្រធនាគារវិនិយោគ និងអភិវឌ្ឍន៍កម្ពុជា ភីអិលស៊ី ក្នុងការអភិវឌ្ឍ និងធ្វើឱ្យប្រសើរឡើងផ្នែកប្រព័ន្ធបច្ចេកវិទ្យា ដំណើរការ និងប្រព័ន្ធទាំងឡាយ ព្រមទាំងផ្តល់នូវផលិតផល និងសេវាកម្មធនាគារឱ្យមានគុណភាពកាន់តែល្អ។

សកម្មភាពចំបងរបស់ធនាគារ គឺបំរើសេវាកម្មធនាគារគ្រប់ប្រភេទ និងសេវាកម្មហិរញ្ញវត្ថុពាក់ព័ន្ធផ្សេងៗក្នុងព្រះរាជាណាចក្រកម្ពុជា និង ប្រទេសវៀតណាម។

***ដើមទុនបានបង់***

ដើមទុនបានបង់របស់ធនាគារនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ មានចំនួន ៧០លានដុល្លារអាមេរិក ឬស្មើនឹង ២៨៥,២៥ ពាន់លានរៀល (២០១៣៖ ៧០លានដុល្លារអាមេរិក)។

***ទីតាំង***

ទីស្នាក់ការកណ្តាលរបស់ធនាគារមានអាសយដ្ឋាននៅអាគារលេខ ៣៧០ មហាវិថី ព្រះមុនីវង្ស សង្កាត់ បឹងកេងកងទីមួយ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។ ធនាគារមានសាខា ចំនួនប្រាំកន្លែងនៅព្រះរាជាណាចក្រកម្ពុជា (សាខាភ្នំពេញ សាខាសៀមរាប សាខាកំពង់ចាម សាខាដូនពេញ និង សាខាមានជ័យ) និងសាខាពីរទៀតនៅប្រទេសវៀតណាម (សាខាហូជីមិញ និង សាខាហាណូយ)។

***បុគ្គលិក***

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ធនាគារមានបុគ្គលិកសរុបចំនួន៣៣៥នាក់ (២០១៣៖ ៣១៦នាក់) ដែលក្នុងនោះ ៩៩នាក់បំរើការនៅទីស្នាក់ការកណ្តាល ២៩នាក់បំរើការនៅសាខាភ្នំពេញ ១៨នាក់បំរើការនៅសាខាខណ្ឌដូនពេញ ១៨នាក់បំរើការនៅសាខាខណ្ឌមានជ័យ ២៣នាក់បំរើការនៅសាខាសៀមរាប ២៣នាក់បំរើការនៅសាខាកំពង់ចាម ៧២នាក់បំរើការនៅសាខាទីក្រុងហូជីមិញ និង ៥៣នាក់ទៀតបំរើការនៅសាខាទីក្រុងហាណូយ។

## កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ (តពីទំព័រមុន)

សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤

### ២. គោលនយោបាយគណនេយ្យ

### *២.១. មូលដ្ឋាននៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ*

#### *២.១.១ ក្របខណ្ឌគណនេយ្យ*

របាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារត្រូវបានរៀបចំឡើងដោយអនុលោមតាមស្តង់ដារគណនេយ្យនៃកម្ពុជា (CAS) និង សេចក្តីណែនាំរបស់ធនាគារជាតិនៃកម្ពុជាទៅលើការរៀបចំ និងបង្ហាញរបាយការណ៍ហិរញ្ញវត្ថុ។

របាយការណ៍ហិរញ្ញវត្ថុដែលមានភ្ជាប់ជាមួយរួមទាំងការប្រើប្រាស់របាយការណ៍ទាំងនេះ មិនត្រូវបានរៀបចំឡើងសំរាប់អ្នកប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុដែលពុំបានដឹងពីគោលការណ៍ គណនេយ្យ នីតិវិធី និងការអនុវត្តគណនេយ្យនៃព្រះរាជាណាចក្រកម្ពុជា និងពុំមានគោលបំណងធ្វើការបង្ហាញពីស្ថានភាពហិរញ្ញវត្ថុ និងលទ្ធផលនៃប្រតិបត្តិការ និងស្ថានភាពលំហូរសាច់ប្រាក់ ដោយអនុលោមទៅតាមគោលការណ៍គណនេយ្យ និងការអនុវត្តគណនេយ្យដែលទទួលស្គាល់ជាទូទៅនៅបណ្តាប្រទេសដោយឡែកពីប្រទេសកម្ពុជាទេ។

គោលនយោបាយគណនេយ្យបង្ហាញខាងក្រោមត្រូវបានធនាគារអនុវត្តយ៉ាងជាប់លាប់។

#### *២.១.២ មូលដ្ឋាននៃការវាស់វែង*

របាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារត្រូវបានរៀបចំដោយយោងលើថ្លៃដើមប្រវត្តិសាស្ត្រ។

#### *២.១.៣. ឆ្នាំសារពើពន្ធ*

ឆ្នាំសារពើពន្ធចាប់ផ្តើមពីថ្ងៃទី១ ខែមករា និង បញ្ចប់ថ្ងៃទី៣១ ខែធ្នូ។

#### *២.១.៤ រូបិយប័ណ្ណសម្រាប់ការវាស់វែងនិងការបង្ហាញ*

ធនាគារធ្វើប្រតិបត្តិការនៅក្នុងទីផ្សារភូមិសាស្ត្រពីរគឺ ព្រះរាជាណាចក្រកម្ពុជា និង សាធារណរដ្ឋសង្គមនិយមវៀតណាម។ រូបិយប័ណ្ណជាតិរបស់ព្រះរាជាណាចក្រកម្ពុជា គឺ ខ្មែររៀល (KHR) រីឯរូបិយប័ណ្ណជាតិរបស់សាធារណរដ្ឋសង្គមនិយមវៀតណាម គឺ វៀតណាមដុង (VND)។ ដោយសារធនាគារ ធ្វើប្រតិបត្តិការ និងកត់ត្រារាល់បញ្ជីគណនេយ្យរបស់ខ្លួន ផ្អែកលើមូលដ្ឋានប្រាក់ដុល្លារអាមេរិក គណៈគ្រប់គ្រងបានកំណត់ប្រាក់ដុល្លារអាមេរិកជារូបិយប័ណ្ណសម្រាប់ការវាស់វែង និងការកំណត់បង្ហាញរបស់ធនាគារ ព្រោះវាបានឆ្លុះបញ្ចាំងពីស្ថានភាពសេដ្ឋកិច្ចនៃព្រឹត្តិការណ៍ទាក់ទង និងកាលៈទេសៈរបស់ធនាគារ។ ការបង្ហាញនេះ គឺស្របតាមប្រកាសរបស់ធនាគារជាតិនៃកម្ពុជាលេខ ធ៧-០៧-១៦៤ ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០០៧។

ប្រតិបត្តិការដែលធ្វើឡើងក្នុងរូបិយប័ណ្ណមិនមែន ដុល្លារអាមេរិកនឹងត្រូវប្រែសម្រួលទៅជារូបិយប័ណ្ណដុល្លារអាមេរិក ដោយយោងតាមអត្រាប្តូរប្រាក់នៃកាលបរិច្ឆេទរបស់ប្រតិបត្តិការនោះ។ ទ្រព្យសកម្ម និងទ្រព្យអកម្មជារូបិយប័ណ្ណដែលស្ថិតនៅក្នុងរូបិយប័ណ្ណមិនមែនដុល្លារអាមេរិក នឹងត្រូវបានប្រែសម្រួលទៅជារូបិយប័ណ្ណដុល្លារអាមេរិក ដោយយោងតាមអត្រាប្តូរប្រាក់នៅកាលបរិច្ឆេទនៃតារាងតុល្យការ។ ភាពខុសគ្នាលើអត្រាប្តូរប្រាក់នឹងត្រូវបានបង្ហាញនៅក្នុងរបាយការណ៍លទ្ធផល។

## កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ (តពីទំព័រមុន)

សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤

### ២. គោលនយោបាយគណនេយ្យ (តពីទំព័រមុន)

#### ២.១. មូលដ្ឋាននៃការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុ (តពីទំព័រមុន)

*២.១.៥ ការប្រែសម្រួលទឹកប្រាក់ដុល្លារអាមេរិកទៅជាប្រាក់រៀល*

ការប្រែសម្រួលទឹកប្រាក់ដុល្លារអាមេរិកទៅជាប្រាក់រៀល ត្រូវបានបង្ហាញក្នុងរបាយការណ៍ហិរញ្ញវត្ថុ ដោយអនុលោមទៅតាមច្បាប់ស្តីពីគណនេយ្យសហគ្រាស សវនកម្មគណនេយ្យសហគ្រាស និង វិជ្ជាជីវៈគណនេយ្យ ចុះថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០០២ និងប្រកាសពាក់ព័ន្ធនានារបស់ធនាគារជាតិ នៃកម្ពុជា ដោយប្រើអត្រាប្តូរប្រាក់ចុងការិយបរិច្ឆេទ ៤.០៧៥ រៀលក្នុង ១ ដុល្លារអាមេរិកសម្រាប់ការិយបរិច្ឆេទនៃរបាយការណ៍ (២០១៣៖ ៣.៩៩៥រៀល ក្នុង ១ដុល្លារអាមេរិក) ដូចដែលបាន ប្រកាសឲ្យប្រើដោយធនាគារជាតិនៃកម្ពុជា។ ទឹកប្រាក់ ប្រែសម្រួលទាំងនេះនឹងមិនត្រូវយកមកបកស្រាយថា ដែលអាចត្រូវបាន ឬនឹងត្រូវបាន ឬនាពេលអនាគតនឹងត្រូវបានប្តូរទៅជាទឹកប្រាក់ដុល្លារអាមេរិក តាមអត្រាប្តូរប្រាក់នេះ ឬអត្រាប្តូរប្រាក់ផ្សេងទៀតបានទេ។

#### ២.២. ការវិនិច្ឆ័យនិងការប៉ាន់ស្មានគណនេយ្យសំខាន់ៗ

ក្នុងការអនុវត្តគោលនយោបាយគណនេយ្យ គណៈគ្រប់គ្រងបានប្រើប្រាស់ការវិនិច្ឆ័យរបស់ខ្លួន និងធ្វើការប៉ាន់ស្មានក្នុងការកំណត់បរិមាណ ដែលត្រូវបានទទួលស្គាល់ក្នុងរបាយការណ៍ហិរញ្ញវត្ថុ មានដូចខាងក្រោម៖

*២.២.១ ភតិសន្យាប្រតិបត្តិការ*

ធនាគារ បានចុះកិច្ចសន្យាជួលអាគារ ដែលត្រូវបានប្រើប្រាស់សម្រាប់ប្រតិបត្តិការរបស់ខ្លួន។ ដោយផ្អែកលើមូលដ្ឋានក្នុងការវាស់វែងលើរយៈពេល និងលក្ខខណ្ឌនៃកិច្ចសន្យាជួល (ដូចជាភាពជាម្ចាស់កម្មសិទ្ធនៃទ្រព្យសកម្ម មិនត្រូវបានផ្ទេរទៅអ្នកជួលនៅចុងការិយបរិច្ឆេទនៃកិច្ចសន្យាជួល ហើយកិច្ចសន្យាជួលមានរយៈពេលតិចជាងអាយុកាលប្រើប្រាស់របស់ទ្រព្យសកម្ម) ធនាគារបានកំណត់ថា ភតិបតីជាអ្នកទទួលហានិភ័យ និងផលប្រយោជន៍សំខាន់ៗទាំងអស់ក្នុងនាមជាម្ចាស់កម្មសិទ្ធិលើទ្រព្យសម្បត្តិទាំងនេះ។

*២.២.២. រូបិយប័ណ្ណសម្រាប់ការវាស់វែង*

ស្តង់ដារគណនេយ្យកម្ពុជាលេខ ២១ តម្រូវឲ្យគណៈគ្រប់គ្រងប្រើប្រាស់ការវិនិច្ឆ័យរបស់ខ្លួនក្នុង ការកំណត់រូបិយប័ណ្ណសម្រាប់ការវាស់វែង ព្រោះវាបានឆ្លុះបញ្ចាំងពីឥទ្ធិពលសេដ្ឋកិច្ច នៃប្រភពប្រតិបត្តិការ និងកាលៈទេសៈរបស់ធនាគារ។ ក្នុងការវិនិច្ឆ័យនេះ ធនាគារត្រូវពិចារណាលើចំណុចដូចខាងក្រោម៖

ក. រូបិយប័ណ្ណដែលមានឥទ្ធិពលលើតម្លៃឧបករណ៍ និងសេវាហិរញ្ញវត្ថុ (តម្លៃឧបករណ៍ និងសេវាហិរញ្ញវត្ថុ នឹងត្រូវបានកំណត់ និងធ្វើការលក់ចេញដោយប្រើប្រាស់រូបិយប័ណ្ណនេះ)

ខ. រូបិយប័ណ្ណដែលទទួលបានពីសកម្មភាពហិរញ្ញប្បទាន និង

គ. រូបិយប័ណ្ណដែលទទួលបានពីសកម្មភាពប្រតិបត្តិការ ហើយតែងតែធ្វើការរក្សាទុក។

## កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ (តពីទំព័រមុន)

សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤

## ២. គោលនយោបាយគណនេយ្យ (តពីទំព័រមុន)

### ២.២. ការវិនិច្ឆ័យនិងការប៉ាន់ស្មានគណនេយ្យសំខាន់ៗ (តពីទំព័រមុន)

#### *២.២.៣ សំវិធានធនលើឥណទានដែលបាត់បង់*

នៅពេលរៀបចំរបាយការណ៍ហិរញ្ញវត្ថុ គុណភាពនៃឥណទាន និងបុរេប្រទានត្រូវបានត្រួតពិនិត្យ និងវាយតម្លៃ ដើម្បីកំណត់ចំណាត់ថ្នាក់ និងកម្រិតនៃសំវិធានធនលើឥណទាន បាត់បង់ដែលនឹងបង្ហាញពេញលេញក្នុងកំណត់សម្គាល់លេខ ២.៣.៦។

#### *២.២.៤ ការថយចុះនៃទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ*

ការថយចុះនៃទ្រព្យសកម្ម មិនមែនហិរញ្ញវត្ថុកើតមាននៅពេលដែលតម្លៃចុះបញ្ជីនៃទ្រព្យសកម្ម ឬទ្រព្យសកម្មប្រមូលផ្តុំមានតម្លៃលើសពីទឹកប្រាក់ ដែលអាចប្រមូលមកវិញបាន ហើយតម្លៃចុះបញ្ជីនៃទ្រព្យសកម្ម គឺយកតម្លៃខ្ពស់ជាងរវាងតម្លៃទីផ្សារដកចេញថ្លៃដើមពាក់ព័ន្ធការលក់ និងតម្លៃប្រើប្រាស់។ ការគណនាតម្លៃទីផ្សារដកថ្លៃដើមពាក់ព័ន្ធការលក់ គឺផ្អែកលើទិន្នន័យដែលទទួលបានពីប្រតិបត្តិការលក់ដោយប្រតិបត្តិការបើកចំហនៃទ្រព្យសកម្មដែលស្រដៀងគ្នា ឬតម្លៃអង្កេតនៅលើទីផ្សារដកថ្លៃដើមដែលកើតមានដើម្បីលក់ទ្រព្យសកម្ម។ ការគណនាតម្លៃប្រើប្រាស់ គឺផ្អែកលើគំរូសាច់ប្រាក់អប្បហារ។ ធនាគារវាយតម្លៃការថយចុះនៃទ្រព្យសកម្ម នៅពេលដែលមានព្រឹត្តិការណ៍ ឬការផ្លាស់ប្តូរ ដែលបង្ហាញថាតម្លៃពិតគណនេយ្យនៃទ្រព្យសកម្មមិនអាចប្រមូលមកវិញបាន។ កត្តាសំខាន់នានា ដែលធនាគារពិចារណាថាតម្រូវឲ្យមានការពិនិត្យលើការថយចុះតម្លៃរួមមាន៖

- លទ្ធផលប្រតិបត្តិការមានកម្រិតទាបជាងខ្លាំង ធៀបទៅនឹងលទ្ធផលប្រតិបត្តិការរំពឹងទុកនាពេលកន្លងមក ឬនាពេលអនាគត
- ការផ្លាស់ប្តូរសំខាន់ៗនៃរបៀបប្រើប្រាស់ទ្រព្យសកម្មដែលបានទិញ ឬយុទ្ធសាស្ត្រអាជីវកម្មទាំងមូល
- និន្នាការសេដ្ឋកិច្ច ឬក្នុងវិស័យអវិជ្ជមានសំខាន់ៗ

#### *២.២.៥ ការប៉ាន់ស្មានអាយុកាលប្រើប្រាស់នៃទ្រព្យ និងបរិក្ខារ និងកម្មវិធីកុំព្យូទ័រ*

ធនាគារ ធ្វើការប៉ាន់ស្មានអាយុកាលប្រើប្រាស់នៃទ្រព្យ និងបរិក្ខារ និងកម្មវិធីកុំព្យូទ័ររបស់ខ្លួន ហើយការប៉ាន់ស្មាននេះត្រូវបានត្រួតពិនិត្យឡើងវិញតាមកាលកំណត់ ដើម្បីធានាថារយៈពេលរំលស់មានភាពសមស្របជាមួយនឹងអត្ថប្រយោជន៍សេដ្ឋកិច្ចនៃទ្រព្យ និងបរិក្ខារ និងកម្មវិធីកុំព្យូទ័រនីមួយៗ។

**កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ** (តពីទំព័រមុន)
**សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤**

## ២. គោលនយោបាយគណនេយ្យ (តពីទំព័រមុន)

### ២.២. *ការវិនិច្ឆ័យនិងការប៉ាន់ស្មានគណនេយ្យសំខាន់ៗ* (តពីទំព័រមុន)

#### ២.៣.១ *ព័ត៌មានវិនិយោគកម្ម*

ធនាគារធ្វើប្រតិបត្តិការអាជីវកម្មរបស់ខ្លួននៅក្នុងភូមិសាស្រ្តចំនួន២ គឺព្រះរាជាណាចក្រកម្ពុជា និង សាធារណរដ្ឋសង្គមនិយមវៀតណាម។

ព័ត៌មានវិនិយោគកម្ម ត្រូវបានធ្វើឡើងក្នុងបំណងដើម្បីបង្ហាញពីវិយោគកម្មអាជីវកម្មរបស់ធនាគារតែប៉ុណ្ណោះ។ ទម្រង់បែបបទ និងការធ្វើវិយោគកម្មអាជីវកម្មរបស់ក្រុមហ៊ុនត្រូវបានធ្វើឡើង ដោយអនុលោមទៅតាម របាយការណ៍របស់គណៈគ្រប់គ្រងដែលរបាយការណ៍នេះត្រូវបានប្រើប្រាស់ដោយគណៈគ្រប់គ្រងជាន់ខ្ពស់ ដើម្បីធ្វើការសម្រេចចិត្ត និងការគ្រប់គ្រងការងារ។ ប្រតិបត្តិការដែលកើតឡើងនៅក្នុងភូមសាស្រ្តផ្សេងគ្នា ត្រូវបានកត់ត្រានៅក្នុងភូមិសាស្រ្តនីមួយៗ ហាក់ដូចជាប្រតិបត្តិការនោះកើតឡើងជាមួយភាគីទី៣ និងលុបបំបាត់ពេលរួមបញ្ចូលគ្នា។ អន្តរប្រតិបត្តិការ ត្រូវបានធ្វើឡើងដោយផ្អែកលើ មូលដ្ឋានធម្មតាទៅលើលក្ខណៈអាជីវកម្មសាមញ្ញ ដែលមិនផ្តល់លក្ខណៈល្អជាង ដល់ភាគីណាមួយជាងបុគ្គលសាធារណៈ។

លទ្ធផលវិយោគកម្មរួមមានទ្រព្យសកម្ម និងទ្រព្យអកម្មដែលរួមបញ្ចូលនូវធាតុទាក់ទងផ្ទាល់ទៅនឹងវិយោគកម្ម និងធាតុអាចបែងចែកទៅវិយោគកម្មតាមមូលដ្ឋានសមរម្យ។

#### ២.៣.២ *សាច់ប្រាក់ និងសាច់ប្រាក់សមមូល*

សម្រាប់គោលបំណងរៀបចំរបាយការណ៍លំហូរសាច់ប្រាក់ សាច់ប្រាក់ និងសាច់ប្រាក់សមមូលរួមមានសាច់ប្រាក់ និងសមតុល្យធនាគារ ប្រាក់បញ្ញើគ្មានកាលកំណត់ និងការវិនិយោគរយៈពេលខ្លីដែលអាចប្តូរជាសាច់ប្រាក់បានក្នុងរយៈពេលបីខែ ឬតិចជាងនេះនាពេលដាក់តម្កល់ និងដែលអាចប្តូរជាសាច់ប្រាក់ ដែលកំណត់បាន និងមានហានិភ័យតិចតួចលើការផ្លាស់ប្តូរតម្លៃ។

#### ២.៣.៣. *សមតុល្យនៅធនាគារផ្សេងៗ*

សមតុល្យនៅធនាគារផ្សេង ត្រូវបានកត់ត្រាជាទឹកប្រាក់ដើម។

#### ២.៣.៤. *ប្រាក់បញ្ញើកាតព្វកិច្ច*

ប្រាក់បញ្ញើកាតព្វកិច្ចសំរាប់ប្រើប្រាស់ក្នុងប្រតិបត្តិការធនាគារត្រូវបានតំកល់នៅ ធនាគារជាតិនៃកម្ពុជា អនុលោមតាមច្បាប់ស្តីពីធនាគារនិងស្ថាប័នហិរញ្ញវត្ថុ ដែលកំណត់អត្រាភាគរយអប្បរមានៃដើមទុន និងប្រាក់បញ្ញើរបស់អតិថិជនដែលកំណត់ដោយធនាគារជាតិនៃកម្ពុជា។

#### ២.៣.៥. *ឥណទាន និង បុរេប្រទាន*

ឥណទាន និងប្រាក់បុរេប្រទានទៅអតិថិជនត្រូវបានបង្ហាញក្នុងតារាងតុល្យការជាទឹកប្រាក់ដើមដោយដកចេញនូវឥណទានដែលត្រូវបានលុបចោល និងសំវិធានធនដែលមានលើឥណទាន និងបុរេប្រទាន ទាំងនោះ។ ឥណទានរយៈពេលខ្លីគឺជាឥណទានដែលនឹងត្រូវទូទាត់សងវិញនៅក្នុងរយៈពេលមួយឆ្នាំ ដោយគិតចាប់ពីកាលបរិច្ឆេទដែលឥណទាននោះត្រូវបានផ្តល់ឲ្យអតិថិជន។ ឥណទានរយៈពេលវែង គឺជាឥណទានដែលនឹងត្រូវទូទាត់សងមកវិញ នៅក្នុងរយៈពេលលើសពីមួយឆ្នាំដោយគិតចាប់ពីកាលបរិច្ឆេទដែលឥណទានត្រូវបានផ្តល់ឲ្យអតិថិជន។

## កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ (តពីទំព័រមុន)

សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤

## ២. គោលនយោបាយគណនេយ្យ (តពីទំព័រមុន)

### ២.៣ សេចក្តីសង្ខេបនៃគោលនយោបាយគណនេយ្យសំខាន់ៗ (តពីទំព័រមុន)

#### ២.៣.៥. ឥណទាន និង បុរេប្រទាន (តពីទំព័រមុន)

ឥណទានត្រូវបានលុបចោល នៅពេលធនាគារពុំមានសង្ឃឹមយ៉ាងប្រាកដនិយមណាមួយ ដែលថាឥណទានអាចប្រមូលមកវិញបាន។ ការប្រមូលបានមកវិញនៃឥណទាន និងបុរេប្រទានដែលត្រូវបានលុបចោល ឬ បានធ្វើសំវិធានធននៅក្នុងការិយបរិច្ឆេទមុនៗនឹងបន្ថយទឹកប្រាក់នៃសំវិធានធនសំរាប់ឥណទានបាត់បង់នៅក្នុងរបាយការណ៍លទ្ធផល។

ឥណទានដែលត្រូវបានចាត់ថ្នាក់ជាឥណទានក្រោមស្តង់ដារ សង្ស័យ ឬ បាត់បង់គឺត្រូវចាត់ទុកជាឥណទានមិនដំណើរការ។

#### ២.៣.៦. សំវិធានធនសំរាប់ការបាត់បង់លើឥណទាន និងបុរេប្រទាន

សំវិធានធនសំរាប់ការបាត់បង់លើឥណទាន និងបុរេប្រទានត្រូវធ្វើឡើងដោយអាស្រ័យទៅលើហានិភ័យជាក់លាក់នានាដែលទាក់ទងទៅនឹងឥណទាន និងបុរេប្រទានទាំងនោះដែលត្រូវបានពិនិត្យមើល និងកំណត់យ៉ាងជាក់លាក់ថាជាឥណទានឃ្លាំមើល ក្រោមស្តង់ដារ សង្ស័យ ឬ បាត់បង់។ លើសពីនេះសំវិធានធនទូទៅក៏ត្រូវបានធ្វើឡើងផងដែរ សំរាប់ឥណទានដែលត្រូវបានចាត់ថ្នាក់ជាឥណទានធម្មតា។

ធនាគារបានអនុវត្តតាមការធ្វើចំណាត់ថ្នាក់ និងសំវិធានធនឥណទាន ដូចដែលបានតំរូវដោយធនាគារជាតិនៃកម្ពុជា តាមប្រកាសលេខ ធ៧-០៩-០៧៤ ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០៩ ដែលប្រកាសនេះតំរូវ ឲ្យធនាគារពាណិជ្ជទាំងអស់ចាត់ថ្នាក់ឥណទានរបស់ខ្លួនជា៥ថ្នាក់។ ប្រកាសនេះក៏បានកំណត់ផងដែរនូវកម្រិតស្របច្បាប់ចាំបាច់នៃការធ្វើសំវិធានធនទូទៅ និងជាក់លាក់ត្រូវបានធ្វើឡើង ដោយផ្អែកលើចំណាត់ថ្នាក់ឥណទាន។

សំវិធាន ត្រូវបានធ្វើឡើងដោយផ្អែកលើភាគរយនៃឥណទាន និងបុរេប្រទានសរុបមានដូចខាងក្រោម៖

| *ចំណាត់ថ្នាក់* | *ចំនួនថ្ងៃហួសកាលកំណត់* | *កំរិតសំវិធានធន* |
|---|---|---|
| *សំវិធានទូទៅ* | | |
| ឥណទានធម្មតា | តិចជាង៣០ថ្ងៃ | ១% |
| *សំវិធានជាក់លាក់* | | |
| ឥណទានឃ្លាំមើល | ពី ៣០ ថ្ងៃ ឬ ច្រើនជាង ប៉ុន្តែ តិចជាង ៩០ ថ្ងៃ | ៣% |
| ឥណទានក្រោមស្តង់ដារ | ពី ៩០ ថ្ងៃ ឬ ច្រើនជាង ប៉ុន្តែ តិចជាង ១៨០ ថ្ងៃ | ២០% |
| ឥណទានជាប់សង្ស័យ | ពី ១៨០ ថ្ងៃ ឬ ច្រើនជាង ប៉ុន្តែ តិចជាង ៣៦០ ថ្ងៃ | ៥០% |
| ឥណទានបាត់បង់ | ៣៦០ ថ្ងៃ ឬ ច្រើនជាង | ១០០% |

**កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ** (តពីទំព័រមុន)

**សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤**

## ២. គោលនយោបាយគណនេយ្យ (តពីទំព័រមុន)

### ២.៣ *សេចក្តីសង្ខេបនៃគោលនយោបាយគណនេយ្យសំខាន់ៗ* (តពីទំព័រមុន)

*២.៣.៦. សំវិធានធនសំរាប់ការបាត់បង់លើឥណទាន និងបុរេប្រទាន* (តពីទំព័រមុន)

ឥណទានមិនអាចប្រមូលបាន ឬ ចំណែកឥណទានដែលចាត់ចំណាត់ថ្នាក់ ជាឥណទានមិនល្អ នឹងត្រូវលុបចោល បន្ទាប់ពីពិចារណាលើតំលៃទីផ្សារជាក់ស្តែងរបស់ទ្រព្យបញ្ចាំ (ប្រសិនបើមាន) នៅពេលដែលគណៈគ្រប់គ្រងវិនិច្ឆ័យថាគ្មានលទ្ធភាពជំប្រាកដនិយម ដើម្បីទារយកឥណទានមកវិញបាន។

*២.៣.៧.កិច្ចសន្យាដែលទាក់ទងនឹងឥណទានផ្សេងៗ*

ក្នុងដំណើរការនៃមុខជំនួញធម្មតារបស់ខ្លួន ធនាគារបានធ្វើកិច្ចសន្យាផ្សេងៗ រួមមានកិច្ចសន្យាឥណទាន លិខិតឥណទាននិងលិខិតធានា។ គោលនយោបាយគណនេយ្យនិងវិធីសាស្ត្រសំវិធានធន គឺប្រហាក់ប្រហែលគ្នាទៅនឹងការផ្តល់ឥណទានដូចកំណត់សំគាល់ខាងលើ។

*២.៣.៨. ការវិនិយោគលើមូលបត្រ*

*២.៣.៨.១ ការវិនិយោគហិរញ្ញវត្ថុសំរាប់លក់*

ការវិនិយោគហិរញ្ញវត្ថុសំរាប់លក់ គឺជាទ្រព្យសកម្មហិរញ្ញវត្ថុមិននិទស្សន៍ដែលធនាគារមានបំណងទិញ និងរក្សាទុកជារៀងរហូត ហើយដែលអាចលក់ដើម្បីឆ្លើយតបនឹងតំរូវការសាច់ប្រាក់ ឬ ការផ្លាស់ប្តូរលក្ខខណ្ឌទីផ្សារ។

*២.៣.៨.២ ការវិនិយោគហិរញ្ញវត្ថុមានកាលកំណត់*

ការវិនិយោគហិរញ្ញវត្ថុមានកាលកំណត់ គឺជាទ្រព្យសកម្មហិរញ្ញវត្ថុមិននិទស្សន៍ ដែលមានកាលកំណត់ជាក់លាក់ ឬ ការទូទាត់ថេរដែលធនាគារមានបំណងនិងលទ្ធភាពក្នុងការរក្សាទុករហូតដល់កាលកំណត់។

*២.៣.៩.ទ្រព្យសកម្មផ្សេងៗ*

ទ្រព្យសកម្មផ្សេងៗ ត្រូវបានរក្សាទុកត្រឹមតំលៃទទួលស្គាល់ដែលអាចស្មានទុកជាមុន។ ការប៉ាន់ស្មានត្រូវបានធ្វើឡើងចំពោះឥណទានសង្ស័យ ដោយយោងទៅតាមការពិនិត្យឡើងវិញលើឥណទានសរុបនៅកាលបរិច្ឆេទតារាងតុល្យការ។

*២.៣.១០. ទ្រព្យអរូបិយ*

កម្មវិធីកុំព្យូទ័រ ដែលធនាគារបានទិញត្រូវបានបង្ហាញតាមថ្លៃដើមដករំលស់បង្គរ។ កម្មវិធីកុំព្យូទ័រត្រូវបានរំលស់ដោយផ្អែកលើវិធីសាស្ត្ររំលស់ថេរ ដែលមានអត្រារំលស់ប្រចាំឆ្នាំ ១០ភាគរយ។

## កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ (តពីទំព័រមុន)

សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤

### ២. គោលនយោបាយគណនេយ្យ (តពីទំព័រមុន)

### *២.៣. សេចក្តីសង្ខេបគោលនយោបាយគណនេយ្យសំខាន់* (តពីទំព័រមុន)

*២.៣.១១ ទ្រព្យ និងបរិក្ខារ*

(ក) ទ្រព្យ និងបរិក្ខារត្រូវបានកត់ត្រាតាមតម្លៃដើមដោយ ដករំលស់បង្គរ និងការខាតបង់ នៃឱនភាពតម្លៃបង្គរ (ប្រសិនបើមាន)។ នៅពេលដែលធាតុនៃទ្រព្យ និងបរិក្ខារ រួមបញ្ចូលនូវ សមាសធាតុសំខាន់ៗ ដែលមានអាយុកាលកំណត់ប្រើប្រាស់ខុសៗគ្នា សមាសភាពទាំងនោះ ត្រូវបានចាត់ទុកជាធាតុផ្សេងគ្នានៃទ្រព្យ និងបរិក្ខារ។

(ខ) ដី និងការសាងសង់កំពុងដំណើរការមិនត្រូវបានធ្វើរំលស់ទេ។ អាគារ និងការកែលំអរអាគារត្រូវបានធ្វើរំលស់តាមវិធីសាស្ត្ររំលស់ថេរតាមអត្រា ៥%។ រំលស់ទ្រព្យ និងបរិក្ខារផ្សេងៗត្រូវបានកត់ត្រាក្នុងរបាយការណ៍លទ្ធផលតាមវិធីសាស្ត្រថយចុះតាមអត្រាដូចខាងក្រោម៖

| | |
|---|---|
| គ្រឿងសង្ហារឹម ឧបករណ៍បំពាក់ និងបរិក្ខារ | ២៥% |
| បរិក្ខារបច្ចេកវិទ្យាព័ត៌មាន | ៥០% |
| យានយន្ត | ២៥% |

(គ) ការចំណាយបន្តបន្ទាប់ដែលពាក់ព័ន្ធទៅនឹងផ្នែកមួយនៃទ្រព្យ និងបរិក្ខារដែលបានទទួលស្គាល់រួចមកហើយ ត្រូវបានបូកបញ្ចូលទៅក្នុងតម្លៃពិតគណនេយ្យនៃទ្រព្យសកម្មនៅពេលដែលអត្ថប្រយោជន៍សេដ្ឋកិច្ចនាពេលអនាគតនឹងហូរចូលមកធនាគារ លើសពីបទដ្ឋានដំណើរការដើមដែលបានវាយតំលៃសំរាប់ទ្រព្យសកម្មដែលមាន។ រាល់ចំណាយបន្តបន្ទាប់ផ្សេងទៀត ត្រូវទទួលស្គាល់ជាចំណាយនៅក្នុងការិយបរិច្ឆេទដែលកើតឡើង។

## កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ (តពីទំព័រមុន)

សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤

### ២. គោលនយោបាយគណនេយ្យ (តពីទំព័រមុន)

### ២.៣. *សេចក្តីសង្ខេបគោលនយោបាយគណនេយ្យសំខាន់* (តពីទំព័រមុន)

*២.៣.១២ ទ្រព្យ និងបរិក្ខារ* (តពីទំព័រមុន)

(ឃ) ដីនិងការសាងសង់កំពុងដំណើរការត្រូវបានកត់ត្រាតាមតម្លៃដើម។ តម្លៃនៃការសាងសង់រួមបញ្ចូលថ្លៃដើមនៃការសាងសង់ បរិក្ខារ និងថ្លៃដើមផ្ទាល់ផ្សេងៗ។ ការសាងសង់កំពុងដំណើរការមិនត្រូវបានគិតរំលស់ទេរហូតទាល់តែការសាងសង់នេះបានបញ្ចប់ ហើយទ្រព្យសកម្មដែលពាក់ព័ន្ធត្រូវបានដាក់ឱ្យប្រើប្រាស់នៅក្នុងប្រតិបត្តិការអាជីវកម្ម។

(ង) ចំណេញ ឬ ខាតពីការបោះបង់ ឬ ការលក់ចេញនៃទ្រព្យ និងបរិក្ខារណាមួយត្រូវបានកំណត់ដោយភាពខុសគ្នារវាងប្រាក់ចំណូលសុទ្ធពីការលក់ និង តម្លៃពិត គណនេយ្យនៃទ្រព្យសកម្មនោះ ហើយត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍លទ្ធផលនៅថ្ងៃបោះបង់ ឬលក់ចេញ។

(ច) ទ្រព្យ និងបរិក្ខារដែលបានរំលស់អស់ហើយ ត្រូវបានរក្សាទុកក្នុងរបាយការណ៍ហិរញ្ញវត្ថុរហូតដល់ថ្ងៃ ដែលទ្រព្យ និងបរិក្ខារទាំងនោះត្រូវបានលក់ ឬជំរុះចោល។

(ឆ) តម្លៃពិតគណនេយ្យនៃទ្រព្យ និងបរិក្ខារ ត្រូវបានធ្វើការត្រួតពិនិត្យឡើងវិញចំពោះឱនភាពនៃតម្លៃនៅពេលមានការគូសបញ្ជាក់ណាមួយឱ្យដឹងថាទ្រព្យសកម្មនោះ ចាំបាច់ត្រូវបន្ថយតម្លៃ។ ឱនភាពតម្លៃត្រូវបានវាស់វែងដោយ ប្រៀបធៀបតម្លៃពិតគណនេយ្យរបស់ទ្រព្យសកម្មជាមួយតម្លៃដែលអាចប្រមូលបានវិញ។ ការខាតបង់លើការថយចុះនៃតម្លៃ ត្រូវបានចាត់ចូលជាចំណាយក្នុងរបាយការណ៍លទ្ធផលភ្លាមៗ។

ការដាក់បញ្ចូលមកវិញនូវការខាតបង់លើឱនភាពនៃតម្លៃ ដែលបានទទួលស្គាល់ពីឆ្នាំមុនៗ ត្រូវបានកត់ត្រាឡើងវិញ នៅពេលដែលមានការគូសបញ្ជាក់ឲ្យដឹងថា ការខូចបង់លើឱនភាព នៃតម្លៃដែលបានទទួលស្គាល់សំរាប់ទ្រព្យសកម្មនោះលែងកើតមានទៀត ឬ ត្រូវបានថយចុះហើយ។ ការដាក់បញ្ចូលមកវិញនេះ ត្រូវបានទទួលស្គាល់ត្រឹមកំរិតតម្លៃពិតគណនេយ្យនៃទ្រព្យសកម្ម ដែលបានកំណត់ (តម្លៃសុទ្ធបន្ទាប់ពីដករំលស់) ប្រសិនបើពុំមានការខាតបង់លើឱនភាពនៃតម្លៃទេនោះ។ ការដាក់បញ្ចូលមកវិញនេះត្រូវបានទទួលស្គាល់ក្នុងរបាយការណ៍លទ្ធផលភ្លាមៗ។

*២.៣.១២ ប្រាក់បញ្ញើអតិថិជននិងពីស្ថាប័នហិរញ្ញវត្ថុផ្សេងៗ*

ប្រាក់បញ្ញើពីអតិថិជននិងពីស្ថាប័នផ្សេងៗ ត្រូវបានកត់ត្រាដោយយោងលើបរិមាណនៃប្រាក់បញ្ញើ។

*២.៣.១៣ ទ្រព្យអកម្មផ្សេងៗ*

ទ្រព្យអកម្មផ្សេងៗ ត្រូវបានកត់ត្រាដោយផ្អែកលើតម្លៃដើម ហើយក៏ត្រូវបានចាត់ទុកជាតម្លៃទីផ្សារមួយដែលរំពឹងថានឹងត្រូវសងនៅពេលអនាគតសំរាប់ទំនិញនិងសេវាកម្មដែលបានទទួល។

## កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ (តពីទំព័រមុន)

សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤

### ២. គោលនយោបាយគណនេយ្យ (តពីទំព័រមុន)

### *២.៣. សេចក្ដីសង្ខេបគោលនយោបាយគណនេយ្យសំខាន់* (តពីទំព័រមុន)

#### *២.៣.១៤ សំវិធានធនលើទ្រព្យអកម្ម*

សំវិធានធនលើទ្រព្យអកម្ម ត្រូវបានទទួលស្គាល់នៅពេលដែលធនាគារមានកាតព្វកិច្ចតាមផ្លូវច្បាប់បច្ចុប្បន្ន ដែលជាលទ្ធផលនៃព្រឹត្តិការណ៍ពីអតីតកាល ហើយវាទំនងជាមានលទ្ធភាពដែលតម្រូវឲ្យមានលំហូរចេញផលប្រយោជន៍សេដ្ឋកិច្ចក្នុងការបំពេញនូវកាតព្វកិច្ចនោះ ហើយការប៉ាន់ស្មានដែលអាចជឿជាក់បាននៃបរិមាណនោះត្រូវបានធ្វើឡើង។

សំវិធានធនត្រូវបានត្រួតពិនិត្យឡើងវិញ នាកាលបរិច្ឆេទនៃតារាងតុល្យការនីមួយៗ ហើយធ្វើការកែតម្រូវឲ្យស្របទៅនឹងការប៉ាន់ស្មានល្អបំផុតនាពេលបច្ចុប្បន្ន។ នៅពេលតម្លៃពេលវេលា នៃសាច់ប្រាក់ មានឥទ្ធិពលជាសារវន្ត បរិមាណសំវិធានធនគឺជាតម្លៃបច្ចុប្បន្ននៃការចំណាយដែលរំពឹងទុកដើម្បីទូទាត់បំណុល។

#### *២.៣.១៥ ពន្ធលើប្រាក់ចំណេញ*

*ពន្ធបច្ចុប្បន្ន*

ពន្ធបច្ចុប្បន្នទ្រព្យសកម្ម និងទ្រព្យអកម្មសំរាប់ការិយបច្ឆេទបច្ចុប្បន្ន និងមុនៗត្រូវបានវាស់វែងជាទឹកប្រាក់ដែលត្រូវបានរំពឹងទុកជាត្រូវបានប្រមូលមកវិញពី ឬត្រូវបង់ឲ្យអាជ្ញាធរពន្ធដារ។ អត្រាពន្ធដារ និងច្បាប់ពន្ធដារដែលត្រូវបានប្រើដើម្បីគណនាទឹកប្រាក់ទាំងនេះ គឺជាអត្រា និងច្បាប់ពន្ធដែលមានសុពលភាពនាការិយបរិច្ឆេទតារាងតុល្យការ។

*ពន្ធពន្យារ*

ពន្ធពន្យារត្រូវបានគណនាលើចំនួនខុសគ្នាបណ្ដោះអាសន្ន នាកាលបរិច្ឆេទនៃរបាយការណ៍ស្ដីពីស្ថានភាពហិរញ្ញវត្ថុរវាងមូលដ្ឋានពន្ធនៃទ្រព្យសកម្ម និងទ្រព្យអកម្ម ហើយនិងតម្លៃពិតគណនេយ្យរបស់ពួកវាក្នុង គោលបំណងរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ។

ពន្ធពន្យារ ជាទ្រព្យអកម្មត្រូវបានទទួលស្គាល់លើចំនួនខុសគ្នាបណ្ដោះអាសន្នជាប់ពន្ធទាំងអស់ លើកលែងតែនៅពេលពន្ធពន្យារលើទ្រព្យអកម្ម កើតឡើងពីការទទួលស្គាល់នៅគ្រាដំបូងនៃទ្រព្យសកម្ម ឬ ទ្រព្យអកម្មនៅក្នុងប្រតិបត្តិការដែលនៅពេលប្រតិបត្តិការនោះមិនជះឥទ្ធិពលដល់ប្រាក់ចំណេញ តាមវិធីសាស្ត្រគណនេយ្យ និង ប្រាក់ចំណេញ ឬខាតជាប់ពន្ធ។

ពន្ធពន្យារ ជាទ្រព្យសកម្មត្រូវបានទទួលស្គាល់សំរាប់ភាពខុសគ្នាបណ្ដោះអាសន្នទាំងអស់ដែលអាចកាត់កងបានត្រឹមទំហំមួយដែលទំនងជា ប្រាក់ចំណេញជាប់ពន្ធនឹងអាចមានដើម្បីកាត់កងជាមួយ ភាពខុសគ្នាបណ្ដោះអាសន្នដែលអាចប្រើប្រាស់បាន លើកលែងតែនៅពេលពន្ធពន្យារជាទ្រព្យ សកម្ម កើតឡើងពីការទទួលស្គាល់នាគ្រាដំបូងនៃ ទ្រព្យសកម្មឬទ្រព្យអកម្មក្នុងប្រតិបត្តិការនៅពេលប្រតិបត្តិការ នោះ មិនមានឥទ្ធិពលដល់ប្រាក់ចំណេញតាមវិធីសាស្ត្រគណនេយ្យ និងប្រាក់ចំណេញ ឬ ខាតជាប់ពន្ធ។

## កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ (តពីទំព័រមុន)

សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤

### ២. គោលនយោបាយគណនេយ្យ (តពីទំព័រមុន)

### *២.៣. សេចក្តីសង្ខេបគោលនយោបាយគណនេយ្យសំខាន់* (តពីទំព័រមុន)

#### *២.៣.១៥ ពន្ធលើប្រាក់ចំណេញ* (តពីទំព័រមុន)

*ពន្ធពន្យារ* (តពីទំព័រមុន)

តម្លៃពិតគណនេយ្យនៃពន្ធពន្យារលើទ្រព្យសកម្ម ត្រូវបានត្រួតពិនិត្យឡើងវិញនាកាលបរិច្ឆេទរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុនីមួយៗ និងត្រូវកាត់បន្ថយមកត្រឹមទំហំដែលមិនទំនងថា ប្រាក់ចំណេញជាប់ពន្ធគ្រប់គ្រាន់នឹងអាចផ្តល់ឲ្យពន្ធពន្យារទ្រព្យសកម្មទាំងអស់ ឬ មួយផ្នែកអាចយកមកប្រើប្រាស់បាននាពេលអនាគត។ ពន្ធលើប្រាក់ចំណូលពន្យារជាទ្រព្យសកម្ម ដែលមិនត្រូវបានទទួលស្គាល់នោះ គឺត្រូវបានវាយតម្លៃឡើងវិញ នាកាលបរិច្ឆេទនៃរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុនីមួយៗ ហើយត្រូវទទួលស្គាល់ តាមវិសាលភាពដែលវាទំនងថាប្រាក់ចំណេញជាប់ពន្ធនាពេលអនាគតនឹងធ្វើឲ្យពន្ធពន្យារជាទ្រព្យសកម្មនោះអាចត្រូវទទួលបានមកវិញ។

#### *២.៣.១៦ ការកាត់កងឧបករណ៍ហិរញ្ញវត្ថុ*

ទ្រព្យសកម្មហិរញ្ញវត្ថុ និងទ្រព្យអកម្មហិរញ្ញវត្ថុត្រូវបានកាត់កង ហើយចំនួនដែលនៅសល់ត្រូវរាយការណ៍ក្នុងតារាងតុល្យការ ប្រសិនបើនិងប្រសិនបើមានតែសិទ្ធិដែលបង្គាប់តាមផ្លូវច្បាប់ឲ្យធ្វើការកាត់កងតំលៃដែលទទួលស្គាល់ និង សុច្ឆន្ទៈក្នុងការទូទាត់លើមូលដ្ឋានតំលៃសុទ្ធ ឬក្នុងការទទួលស្គាល់លើទ្រព្យសកម្ម និងទូទាត់ទ្រព្យអកម្មនៅដំណាលគ្នា។ ករណីនេះមិនមែនជាករណីទូទៅ ដែលអាចអនុវត្តបានជាមួយកិច្ចព្រមព្រៀងទូទាត់មេ (Master Netting Agreement) និងទ្រព្យសកម្ម និងទ្រព្យអកម្មពាក់ព័ន្ធដែលត្រូវបានបង្ហាញជាចំនួនដុលក្នុងតារាងតុល្យការ។

#### *២.៣.១៧. ការទទួលស្គាល់ចំណូល និង ចំណាយ*

*(១) ចំណូលការប្រាក់*

ចំណូលត្រូវបានទទួលស្គាល់ នៅពេលដែលវាទំនងថាអត្ថប្រយោជន៍សេដ្ឋកិច្ច ដែលពាក់ព័ន្ធជាមួយប្រតិបត្តិការនឹងហូរចូលមកក្នុងក្រុមហ៊ុន ហើយចំនួនទឹកប្រាក់នៃចំណូលនោះអាចធ្វើការវាស់វែងគួរអោយជឿជាក់បាន។

ចំណូលការប្រាក់ពីឥណទានទៅកាន់អតិថិជន និង សមតុល្យជាមួយធនាគារជាតិនៃកម្ពុជា និង ធនាគារដទៃទៀត និងការវិនិយោគលើមូលបត្របំណុលត្រូវបានទទួលស្គាល់តាមមូលដ្ឋានបង្គរប្រចាំថ្ងៃ។ នៅពេលឥណទានទៅកាន់អតិថិជនដែលក្លាយជាឥណទានមិនដំណើរការ ការប្រាក់បង្គរសំរាប់ឥណទានទាំងនេះ នឹងត្រូវព្យួរទុករហូតដល់វាត្រូវបានទទួលស្គាល់វិញតាមមូលដ្ឋានសាច់ប្រាក់។ ឥណទានត្រូវបានចាត់ទុកថាមិនដំណើរការនៅពេលដែលការសងត្រលប់មានលក្ខណៈយឺត ៩០ថ្ងៃ ឬលើស។

**កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ** (តពីទំព័រមុន)
សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤

## ២. គោលនយោបាយគណនេយ្យ (តពីទំព័រមុន)

### ២.៣. សេចក្តីសង្ខេបគោលនយោបាយគណនេយ្យសំខាន់ (តពីទំព័រមុន)

#### ២.៣.១៧. ការទទួលស្គាល់ចំណូល និង ចំណាយ (តពីទំព័រមុន)

*(២) ចំណូលពីសកម្មភាពផ្សេងៗរបស់ធនាគារ*

ចំណូលពីប្រតិបត្តិការផ្សេងៗរបស់ធនាគារត្រូវបង្គរតាមមូលដ្ឋានដូចខាងក្រោម៖

(ក) កំរៃពីការរៀបចំឥណទាន និង កំរៃជើងសារដែលបានពីសេវាកម្មផ្សេងៗនិងការសំរួលនានាដែលផ្តល់ដល់អតិថិជនត្រូវទទួលស្គាល់ពេលប្រតិបត្តិការទាំងនេះកើតឡើង

(ខ) កំរៃលើសេវា និងកំរៃលើប្រតិបត្តិការត្រូវបានទទួលស្គាល់ពេលសេវាកម្មត្រូវបានបំពេញ។

(គ) ចំណូលភាគលាភត្រូវបានទទួលស្គាល់នៅពេលធនាគារ ត្រូវបានផ្តល់សិទ្ធិក្នុងការទទួលភាគលាភនោះ។

*(៣) ចំណាយការប្រាក់*

ចំណាយការប្រាក់លើប្រាក់បញ្ញើរបស់អតិថិជន និងស្ថាប័នហិរញ្ញវត្ថុផ្សេងៗ ត្រូវបានទទួលស្គាល់តាមមូលដ្ឋានគណនេយ្យបង្គរ។

*(៤) ចំណាយឈ្នួល និងជើងសារ*

ចំណាយឈ្នួល និងជើងសារត្រូវបានទទួលស្គាល់នៅពេលដែលកើតឡើង។

#### ២.៣.១៨. ភតិសន្យាប្រតិបត្តិការ

ការទូទាត់ភតិសន្យាប្រតិបត្តិការ ត្រូវទទួលស្គាល់ក្នុងរបាយការណ៍លទ្ធផល តាមមូលដ្ឋានថេរលើកាលកំណត់នៃភតិសន្យា។

#### ២.៣.១៩. សម្ព័ន្ធញាតិ

អនុលោមតាមស្តង់ដារគណនេយ្យកម្ពុជាលេខ ២៤ លើកំណត់បង្ហាញនៃសម្ព័ន្ធញាតិ ភាគីដែលចាត់ទុកថាជាសម្ព័ន្ធញាតិ លុះត្រាតែធនាគារមានលទ្ធភាពគ្រប់គ្រងដោយផ្ទាល់ ឬ ប្រយោលលើភាគីផ្សេងទៀត ឬមានឥទ្ធិពលយ៉ាងសំខាន់ក្នុងការសំរេចចិត្តផ្នែកហិរញ្ញវត្ថុ និង ប្រតិបត្តិការ ឬច្រាសមកវិញ ឬប្រសិនបើធនាគារ និងភាគីនោះស្ថិតក្រោមការគ្រប់គ្រងរួមមួយ ឬក៏មាន ឥទ្ធិពលជាសំខាន់។ សម្ព័ន្ធញាតិអាចជា រូបវន្តបុគ្គល ឬ នីតិបុគ្គលហើយក៏រាប់បញ្ចូលផង ដែរបុគ្គលជិតស្និទ្ធនៅក្នុងសមាជិកគ្រួសារ។

សម្ព័ន្ធញាតិត្រូវបានកំណត់ក្នុងមាត្រាទី៤៩ និង៥០នៃច្បាប់ស្តីពីធនាគារ និងស្ថាប័នហិរញ្ញវត្ថុដូចខាងក្រោម៖

(ក) បុគ្គលទាំងឡាយណា ដែលកាន់កាប់ដោយផ្ទាល់ឬដោយប្រយោលនូវយ៉ាងតិច ១០% នៃដើមទុន ឬសិទ្ធិបោះឆ្នោត

(ខ) ក្រុមហ៊ុនដែលត្រូវបានធនាគារកាន់កាប់នៅក្នុងដើមទុនដោយផ្ទាល់ ឬដោយប្រយោលនូវភាគកម្ម យ៉ាងតិចស្មើ នឹង១០% ឬតំណាងយ៉ាងតិច១០% នៃសិទ្ធិបោះឆ្នោត

(គ) បុគ្គលណាដែលចូលរួមក្នុងការអភិបាល ការដឹកនាំ ការគ្រប់គ្រង ឬការត្រួតពិនិត្យផ្ទៃក្នុង និង

(ឃ) សវនករឯករាជ្យ។

**កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ** (តពីទំព័រមុន)
សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤

## ២. **គោលនយោបាយគណនេយ្យ** (តពីទំព័រមុន)

### ***២.៣. សេចក្តីសង្ខេបគោលនយោបាយគណនេយ្យសំខាន់*** (តពីទំព័រមុន)

#### *២.៣.២០. ទ្រព្យសកម្មដែលនៅក្នុងបន្ទុកសំរាប់ជាការធានា*

ទ្រព្យសកម្ម ដែលត្រូវបានរក្សានៅក្នុងបន្ទុក ឬក្នុងសមាសភាពជារបស់ធានាគី មិនមានបង្ហាញក្នុងរបាយការណ៍ហិរញ្ញវត្ថុទេ ពីព្រោះទ្រព្យទាំងអស់នេះមិនមែនជាទ្រព្យសកម្មរបស់ធនាគារឡើយ។

#### *២.៣.២១. ការកាត់ខ្ទង់ចំនួនទឹកប្រាក់*

ចំនួនទឹកប្រាក់ក្នុងរបាយការណ៍ហិរញ្ញវត្ថុ ត្រូវបានកាត់ខ្ទង់តំឡើងយកចំនួនខ្ពស់បំផុតសំរាប់ខ្ទង់រាយ ចំពោះចំនួនទឹកប្រាក់ដុល្លារអាមេរិក និងខ្ពស់បំផុតសំរាប់ទឹកប្រាក់ខ្ទង់សមមូល ពាន់រៀល ចំពោះចំនួនទឹកប្រាក់ជាប្រាក់រៀល។

#### *២.៣.២២. តួលេខប្រៀបធៀប*

តួលេខប្រៀបធៀប ត្រូវបានចាត់ថ្នាក់សារឡើងវិញ ដើម្បីឲ្យស្របទៅតាមការបង្ហាញសំរាប់ឆ្នាំបច្ចុប្បន្ន។

## ៣. **សាច់ប្រាក់ក្នុងដៃ**

| | *២០១៤* *ដុល្លារអាមេរិក* | *២០១៤* *សមមូលពាន់រៀល (កំណត់សំគាល់ ២.១.៥)* | *២០១៣* *ដុល្លារអាមេរិក (បង្ហាញឡើងវិញ)* | *២០១៣* *សមមូលពាន់រៀល (កំណត់សំគាល់ ២.១.៥) (បង្ហាញឡើងវិញ)* |
|---|---|---|---|---|
| ដុល្លារអាមេរិក | ៥.២០១.១៣៩ | ២១.១៩៤.៦៤១ | ៣.២៩៧.៦៦៨ | ១៣.១៧៤.១៨៤ |
| ខ្មែររៀល | ១៦៨.៩៩៩ | ៦៨៨.៦៧១ | ៥៣.៦៧២ | ២១៤.៤២១ |
| រូបិយប័ណ្ណផ្សេងៗទៀត | ២៦១.៤៤២ | ១.០៦៥.៣៧៧ | ៣៤៧.៩០៥ | ១.៣៨៩.៨៧៩ |
| | **៥.៦៣១.៥៨០** | **២២.៩៤៨.៦៨៩** | **៣.៦៩៩.២៤៥** | **១៤.៧៧៨.៤៨៤** |

សំរាប់គោលបំណងនៃរបាយការណ៍លំហូរសាច់ប្រាក់ សាច់ប្រាក់ និងសាច់ប្រាក់សមមូលរួមមាន៖

| | *២០១៤* *ដុល្លារអាមេរិក* | *២០១៤* *សមមូលពាន់រៀល (កំណត់សំគាល់ ២.១.៥)* | *២០១៣* *ដុល្លារអាមេរិក (បង្ហាញឡើងវិញ)* | *២០១៣* *សមមូលពាន់រៀល (កំណត់សំគាល់ ២.១.៥) (បង្ហាញឡើងវិញ)* |
|---|---|---|---|---|
| សាច់ប្រាក់ក្នុងដៃ | ៥.៦៣១.៥៨០ | ២២.៩៤៨.៦៨៩ | ៣.៦៩៩.២៤៥ | ១៤.៧៧៨.៤៨៤ |
| សមតុល្យនៅធនាគារកណ្តាល | ៣៣.៧៤៥.២១១ | ១៣៧.៥១១.៧៣៥ | ៣០.៩២៧.៦១៩ | ១២៣.៥៥៥.៨៣៨ |
| សមតុល្យនៅធនាគារផ្សេងៗ - ប្រាក់បញ្ញើចរន្ត និង មានកាលកំណត់ (តិចជាង៣ខែ) | ៤២.៦៧១.២៤០ | ១៧៣.៨៨៥.៣០៣ | ៤៨.៣២៥.២៥៣ | ១៩៣.០៥៩.៣៨៦ |
| | **៨២.០៤៨.០៣១** | **៣៣៤.៣៤៥.៧២៧** | **៨២.៩៥២.១១៧** | **៣៣១.៣៩៣.៧០៨** |

## កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ (តពីទំព័រមុន)

សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤

### ៤. សមតុល្យនៅធនាគារកណ្តាល

| | ២០១៤<br>ដុល្លារអាមេរិក | ២០១៤<br>សមមូលពាន់រៀល (កំណត់សំគាល់ ២.១.៥) | ២០១៣<br>ដុល្លារអាមេរិក<br>(បង្ហាញឡើងវិញ) | ២០១៣<br>សមមូលពាន់រៀល (កំណត់សំគាល់ ២.១.៥)<br>(បង្ហាញឡើងវិញ) |
|---|---|---|---|---|
| **គណនីចរន្តនៅធនាគារជាតិនៃកម្ពុជា** | ២៧.២៦៤.១១៩ | ១១១.១០១.២៨៥ | ២៧.៦១០.០១៤ | ១១០.៣០២.០០៦ |
| ខ្មែររៀល | ២.៧៦៤.៦១០ | ១១.២៦៥.៧៨៦ | ១.១៨៨.១០៤ | ៤.៧៤៦.៤៧៦ |
| ដុល្លារអាមេរិក | ២៤.៤៩៩.៥០៩ | ៩៩.៨៣៥.៤៩៩ | ២៦.៤២១.៩១០ | ១០៥.៥៥៥.៥៣០ |
| ប្រាក់បញ្ញើមានកាលកំណត់នៅធនាគារជាតិនៃកម្ពុជា | ១.០០០.០០០ | ៤.០៧៥.០០០ | - | - |
| ដុល្លារអាមេរិក | ១.០០០.០០០ | ៤.០៧៥.០០០ | - | - |
| ប្រាក់បញ្ញើកាតព្វកិច្ច | ២៦.១០២.០៣៦ | ១០៦.៣៦៥.៧៩៧ | ២១.៨២៥.៥៦២ | ៨៧.១៩៣.១២០ |
| ប្រាក់តំកល់ធានាលើដើមទុន - ដុល្លារអាមេរិក (១) | ៧.០០០.០០០ | ២៨.៥២៥.០០០ | ៧.០០០.០០០ | ២៧.៩៦៥.០០០ |
| ប្រាក់បំរុងកាតព្វកិច្ច - ខ្មែររៀល (២) | ១៧៦.០៧៦ | ៧១៧.៥១០ | ១៧៩.៦០២ | ៧១៧.៥១០ |
| ប្រាក់បំរុងកាតព្វកិច្ច - ដុល្លារអាមេរិក (២) | ១៨.៩២៥.៩៦០ | ៧៧.១២៣.២៨៧ | ១៤.៦៤៥.៩៦០ | ៥៨.៥១០.៦១០ |
| សមតុល្យនៅធនាគាររដ្ឋនៃវៀតណាម (៣) | ៦.០៨១.០៩២ | ២៤.៧៨០.៤៥០ | ៣.៣១៧.៦០៥ | ១៣.២៥៣.៨៣២ |
| វៀតណាមដុង | ៤.៦៤៤.៩៩៩ | ១៨.៩២៨.៣៧១ | ១.៦១៨.៥៥៧ | ៦.៤៦៦.១៣៥ |
| ដុល្លារអាមេរិក | ១.៤៣៦.០៩៣ | ៥.៨៥២.០៧៩ | ១.៦៩៩.០៤៨ | ៦.៧៨៧.៦៩៧ |
| | **៦០.៤៤៧.២៤៧** | **២៤៦.៣២២.៥៣២** | **៥២.៧៥៣.១៨១** | **២១០.៧៤៨.៩៥៨** |

*(១) ប្រាក់តំកល់ធានាលើដើមទុននៅធនាគារជាតិនៃកម្ពុជា*

យោងតាមប្រកាសរបស់ធនាគារជាតិនៃកម្ពុជាលេខ ធ៧-០១-១៣៦ ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ ២០០១ គ្រប់ធនាគារត្រូវបានតំរូវឲ្យតំកល់ប្រាក់បញ្ញើដើមទុនកាតព្វកិច្ចចំនួន ១០ភាគរយនៃដើមទុនចុះបញ្ជីនៅធនាគារជាតិនៃកម្ពុជា។ ប្រាក់តំកល់ មិនអាចប្រើប្រាស់ក្នុងប្រតិបត្តិការប្រចាំថ្ងៃរបស់ធនាគារបានឡើយ ប៉ុន្តែធនាគារអាចដកវិញនៅពេលដែលធនាគារស្ម័គ្រចិត្តឈប់ធ្វើប្រតិបត្តការអាជីវកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ** (តពីទំព័រមុន)

សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤

## ៤. សមតុល្យនៅធនាគារកណ្តាល (តពីទំព័រមុន)

*(២) ប្រាក់បំរុងកាតព្វកិច្ចនៅធនាគារជាតិនៃកម្ពុជា*

យោងតាមប្រកាសរបស់ធនាគារជាតិនៃកម្ពុជាលេខ ធ៧-០១២-១៤០ ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១២ ធនាគារត្រូវបានតំរូវឲ្យរក្សាចំនួនសាច់ប្រាក់បំរុងជាក់លាក់នៅធនាគារជាតិ នៃកម្ពុជាក្នុងទំរង់ ជាប្រាក់ញើកាតព្វកិច្ចដោយគណនាស្មើនឹង ៨%នៃប្រាក់បញ្ញើរបស់ អតិថិជនជាប្រាក់រៀល និង ១២,៥% នៃប្រាក់បញ្ញើជារូបិយប័ណ្ណបរទេស។ ប្រាក់តំកល់ដែល តំរូវលើប្រាក់បញ្ញើរបស់អតិថិជន ប្រែប្រួលទៅតាមកំរិតនៃប្រាក់បញ្ញើរបស់អតិថិជន។

*(៣) សមតុល្យនៅធនាគាររដ្ឋនៃវៀតណាម*

សមតុល្យនៅធនាគាររដ្ឋនៃវៀតណាមរួមមាន ប្រាក់តំកល់សំរាប់ទូទាត់និងផាត់ទាត់ និង ប្រាក់តំកល់តំរូវដោយច្បាប់។ ក្នុងឆ្នាំ២០១៤ ប្រាក់តំកល់តំរូវដោយច្បាប់គិតជាវៀតណាមដុង និងប្រាក់តំកល់សំរាប់ទូទាត់ជារូបិយប័ណ្ណបរទេស ទទួលបានការប្រាក់ចំនួន ១,២០% និង ០,០៥% ក្នុងមួយឆ្នាំ រៀងគ្នា។

យោងតាមបទបញ្ញត្តិរបស់ធនាគាររដ្ឋនៃវៀតណាម នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ធនាគារត្រូវបានតំរូវអោយរក្សានូវប្រាក់បំរុងជាក់លាក់មួយចំនួន ជាមួយធនាគាររដ្ឋនៃវៀតណាមក្នុងទំរង់ជាប្រាក់បញ្ញើស្ម័គ្រចិត្ត ដែលត្រូវបានគណនាដោយប្រើអត្រាដូចខាងក្រោមៈ

- ៣,០០% និង ១,០០% នៃប្រាក់បញ្ញើអតិថិជនជាវៀតណាមដុង ដែលមានកាលកំណត់ដើមតិចជាង១២ខែ និងលើសពី១២ខែ រៀងគ្នា
- ៨,០០% និង ៦,០០% នៃប្រាក់បញ្ញើអតិថិជនជារូបិយប័ណ្ណបរទេសដែលមានកាលកំណត់ដើមតិចជាង និងលើសពី១២ខែ រៀងគ្នា និង
- ១,០០% នៃប្រាក់បញ្ញើពីស្ថាប័នឥណទានបរទេស។

អត្រាការប្រាក់ប្រចាំឆ្នាំសំរាប់ប្រាក់បញ្ញើ និងប្រាក់តម្កល់នៅធនាគារកណ្តាលត្រូវបានសង្ខេប ដូចតទៅៈ

| | ២០១៤ | ២០១៣ |
|---|---|---|
| ប្រាក់តំកល់ធានាលើដើមទុន (ដុល្លារអាមេរិក) | ០,០៨% | ០,១១% |
| ប្រាក់បំរុងកាតព្វកិច្ច (ដុល្លារអាមេរិក និងខ្មែររៀល) | ០,០៨% | ០,០៨% |
| គណនីចរន្ត | ០,០០% | ០,០០% |
| ប្រាក់បញ្ញើមានកាលកំណត់ (ដុល្លារអាមេរិក) | ០,១១% | គ្មាន |

## កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ (តពីទំព័រមុន)

សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤

### ៥. សមតុល្យនៅស្ថាប័នហិរញ្ញវត្ថុផ្សេងៗ

| | ២០១៤ ដុល្លារអាមេរិក | ២០១៤ សមមូលពាន់រៀល (កំណត់សំគាល់ ២.១.៥) | ២០១៣ ដុល្លារអាមេរិក (បង្ហាញឡើងវិញ) | ២០១៣ សមមូលពាន់រៀល (កំណត់សំគាល់ ២.១.៥ (បង្ហាញឡើងវិញ) |
|---|---|---|---|---|
| ស្ថាប័នហិរញ្ញវត្ថុក្នុងស្រុក | ២៥.៥១១.៦០៩ | ១០៣.៦៥៩.៨០៧ | ២.១៧៨.៨១០ | ៤.៧០២.៧៨៨ |
| ស្ថាប័នហិរញ្ញវត្ថុបរទេស | ២៥.១៥៩.៦៣១ | ១០២.៨២៥.៤៩៦ | ៤៦.១៤៦.៤៤៣ | ១៤៤.៣៥៦.៦៣៨ |
| ដកសំវិធានធនទូទៅនៃឥណទានទៅស្ថាប័នហិរញ្ញវត្ថុផ្សេងទៀត | - | - | (១០៥.៩៨០) | (៤២៣.៣៦០) |
| | **៥០.៦៧១.២៤០** | **២០៦.៤៨៥.៣០៣** | **៤៨.២១៩.២៧៣** | **១៤៨.៦៣៥.៩៦៦** |

ការប្រែប្រួលនៃសំវិធានធនទូទៅសំរាប់ឥណទានពីស្ថាប័នហិរញ្ញវត្ថុផ្សេងៗ ត្រូវសង្ខេបដូចតទៅ៖

| | ២០១៤ ដុល្លារអាមេរិក | ២០១៤ សមមូលពាន់រៀល (កំណត់សំគាល់ ២.១.៥) | ២០១៣ ដុល្លារអាមេរិក | ២០១៣ សមមូលពាន់រៀល (កំណត់សំគាល់ ២.១.៥) |
|---|---|---|---|---|
| សមតុល្យថ្ងៃទី១ ខែមករា | ១០៥.៩៨០ | ៤២៣.៣៦០ | ២៥៨.៣៥៥ | ១.០៣២.១២៨ |
| ការបង្វិលមកវិញនូវវិធានធន | (១០៤.៩៣២) | (៤២៧.៥៦៤) | (១៤៩.៨២១) | (៥៩៨.៥៦៥) |
| លំអៀងអត្រាប្តូរប្រាក់ | (១.០៤៨) | ៤.២០៤ | (២.៥៥៤) | (១០.២០៣) |
| **សមតុល្យថ្ងៃទី៣១ ខែធ្នូ** | - | - | ១០៥.៩៨០ | ៤២៣.៣៦០ |

យោងតាមសេចក្តីប្រកាសលេខ ០២/២០១៣/TT-NHNN ចេញដោយធនាគារជាតិនៃវៀតណាម ស្ថានប័នឥណទាន និងសាខារបស់ធនាគារបរទេស មិនត្រូវបានតំរូវអោយបង្កើតសំវិធានធនទូទៅសំរាប់ ឥណទានទៅស្ថាប័នឥណទានដទៃៗទេ។ ដូចនេះធនាគារបានបង្វិលមកវិញនូវសំវិធានធនទូទៅលើ ឥណទានទៅស្ថានប័នហិរញ្ញវត្ថុដទៃទាំងអស់ក្នុងការិយបរិច្ឆេទនេះ។

អត្រាការប្រាក់ប្រចាំឆ្នាំសំរាប់សមតុល្យនៅស្ថាប័នហិរញ្ញវត្ថុផ្សេងៗ មានដូចតទៅ៖

| | ២០១៤ | ២០១៣ |
|---|---|---|
| បញ្ញើតាមតម្រូវការ | ០,០០% - ៥,៣០% | ០,១០% - ០,៥០% |
| បញ្ញើមានកាលកំណត់ និងឥណទានទៅធនាគារដទៃ-វៀតណាមដុង (VND) | ៣,២០% - ៥,៨០% | ៣,២០% - ៥,៧០% |
| បញ្ញើមានកាលកំណត់និងឥណទានទៅធនាគារដទៃ-ដុល្លារអាមេរិក (USD) | ០,៥០% - ៣,៧៥% | គ្មាន |

## កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ (តពីទំព័រមុន)

សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤

### ៦. ឥណទាន និង បុរេប្រទានឲ្យអតិថិជន

| | ២០១៤ ដុល្លារអាមេរិក | ២០១៤ សមមូលពាន់រៀល (កំណត់សំគាល់ ២.១.៥) | ២០១៣ ដុល្លារអាមេរិក | ២០១៣ សមមូលពាន់រៀល (កំណត់សំគាល់ ២.១.៥) |
|---|---|---|---|---|
| **ឥណទាន** | | | | |
| ឥណទានមានកាលកំណត់ | ២៦៦.៧១១.៣១៧ | ១.០៨៦.៨៤៨.៦១៧ | ២២៨.៣៩៣.៣១៣ | ៩១២.៤៣១.២៨៥ |
| ឥណទានវិបារូបន៍ | ៩២.០៩១.៣២៣ | ៣៧៥.២៧២.១៤១ | ៨១.៦៦១.២២៣ | ៣២៦.២៣៦.៥៨៦ |
| ប័ណ្ណឥណទាន | ៨២.០៤៤.០០០ | ៣៣៤.៣២៩.៣០០ | ៦៧.៣០៦.៦៧០ | ២៦៨.៨៩០.១៤៧ |
| **ឥណទានសរុប - ដុល** | ៤៤០.៨៤៦.៦៤០ | ១.៧៩៦.៤៥០.០៥៨ | ៣៧៧.៣៦១.២០៦ | ១.៥០៧.៥៥៨.០១៨ |
| សំវិធានធនសំរាប់ការបាត់បង់លើឥណទាន និង បុរេប្រទាន | (៨.៣៣១.៥៦៤) | (៣៣.៩៥១.១២៣) | (៩.៧៣៥.៦៧៤) | (៣៨.៨៩៤.០១៦) |
| **ឥណទាន និង បុរេប្រទានទៅអតិថិជន - សុទ្ធ** | **៤៣២.៥១៥.០៧៦** | **១.៧៦២.៤៩៨.៩៣៥** | **៣៦៧.៦២៥.៥៣២** | **១.៤៦៨.៦៦៤.០០២** |

បម្រែបម្រួលនៃការធ្វើសំវិធានធនសម្រាប់ឥណទាន និងបុរេប្រទានមានដូចខាងក្រោម៖

| | ២០១៤ ដុល្លារអាមេរិក | ២០១៤ សមមូលពាន់រៀល | ២០១៣ ដុល្លារអាមេរិក | ២០១៣ សមមូលពាន់រៀល |
|---|---|---|---|---|
| សមតុល្យថ្ងៃទី១ ខែមករា | ៩.៧៣៥.៦៧៤ | ៣៨.៨៩៤.០១៦ | ៤.៣៦៧.៩១៩ | ១៧.៤៤៩.៤៣៦ |
| សំវិធានធនសម្រាប់ឆ្នាំ | ២.៩៣៩.១៦០ | ១១.៩៧៧.០៧៧ | ៥.៣៨១.៧៦៦ | ២១.៥០០.១៥៥ |
| សំវិធានធនប្រើសំរាប់លុបចោលឥណទានអាក្រក់ | (៤.៣២២.៥០៨) | (១៧.៦១៤.២២០) | - | - |
| លំអៀងអត្រាប្តូរប្រាក់ | (២០.៧៦២) | ៦៩៤.២៥០ | (១៤.០១១) | (៥៥.៥៧៥) |
| **សមតុល្យថ្ងៃទី៣១ ខែធ្នូ** | ៨.៣៣១.៥៦៤ | ៣៣.៩៥១.១២៣ | ៩.៧៣៥.៦៧៤ | ៣៨.៨៩៤.០១៦ |

## កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ (តពីទំព័រមុន)

សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤

### ៦. ឥណទាន និង បុរេប្រទានឲ្យអតិថិជន (តពីទំព័រមុន)

ការវិភាគបន្ថែមសំរាប់ឥណទាន និងបុរេប្រទាន មានដូចតទៅ៖

(ក) ការចាត់ថ្នាក់សំរៀតឥណទាន មានដូចតទៅ៖

| | ២០១៤ ដុល្លារអាមេរិក | ២០១៤ សមមូលពាន់រៀល (កំណត់សំគាល់ ២.១.៥) | ២០១៣ ដុល្លារអាមេរិក | ២០១៣ សមមូលពាន់រៀល (កំណត់សំគាល់ ២.១.៥) |
|---|---|---|---|---|
| **ឥណទានធម្មតា** | | | | |
| មានទ្រព្យធានា | ២៥៥.៦៦៥.៣៦៩ | ១.០៩១.៨៣៦.៣៧៩ | ២៤០.៦៩៧.៩១១ | ១.១២១.១៨៨.៨០៨ |
| គ្មានទ្រព្យធានា | ១៥៩.៦៥៧.៦៤៩ | ៦៥០.៦០៥.០៤៣ | ៧៥.៥៨៤.៨៣២ | ៣០១.៩៧៥.៧៨៥ |
| **ឥណទានឃ្លាំមើល** | | | | |
| មានទ្រព្យធានា | ៨.៨៤២.៨៦៥ | ៣៦.១៩៧.៦៧៤ | ២.២២១.៩៩៧ | ៨.៨៧៦.៦៤០ |
| គ្មានទ្រព្យធានា | - | - | - | - |
| **ឥណទានក្រោមស្តង់ដារ** | | | | |
| មានទ្រព្យធានា | ១៥.០០៤.៨៥៧ | ៦១.១៦១.០៩២ | ១៤.៥៩០.៥៨៩ | ៥៨.២៨៩.៤០២ |
| គ្មានទ្រព្យធានា | - | - | - | - |
| **ឥណទានសង្ស័យ** | | | | |
| មានទ្រព្យធានា | ១.៣៣៩.៥២៧ | ៥.៤៥៤.៥៧៣ | ១.៧៨២.២០០ | ៧.១១៩.៨៨៩ |
| គ្មានទ្រព្យធានា | ១០៤.០៤៣ | ៤២៣.៩៧៥ | - | - |
| **ឥណទានបាត់បង់** | | | | |
| មានទ្រព្យធានា | ១៨៨.២៤០ | ៧៦៧.២៤២ | ២.៥៣០.១២៧ | ១០.១០៧.៨៥៤ |
| គ្មានទ្រព្យធានា | - | - | - | - |
| សរុប | ៤៤០.៨៨៦.៦៤០ | ១.៧៩៦.៤៥០.០៥៤ | ៣៣៧.៣៦១.២០៦ | ១.៥០៧.៥៥៨.០១៤ |

(ខ) ការវិភាគឥណទាន និងបុរេប្រទានតាមអាយុកាលត្រូវបានបង្ហាញនៅកំណត់សំគាល់ ២៦ ស្តីអំពីការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ។

(គ) ការវិភាគឥណទាន និងបុរេប្រទានតាមរូបិយប័ណ្ណត្រូវបានបង្ហាញនៅកំណត់សំគាល់២៦ ស្តីអំពីការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ។

## កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ (តពីទំព័រមុន)

សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤

### ៦. ឥណទាន និង បុរេប្រទានឲ្យអតិថិជន (តពីទំព័រមុន)

(ឃ) ការវិភាគឥណទាន និងបុរេប្រទានតាមប្រភេទនៃឥណទានមានដូចតទៅ៖

| | ២០១៤ ដុល្លារអាមេរិក | ២០១៤ សមមូលជាប្រាក់រៀល (កំណត់សំគាល់ ២.១.៥) | ២០១៣ ដុល្លារអាមេរិក | ២០១៣ សមមូលជាប្រាក់រៀល (កំណត់សំគាល់ ២.១.៥) |
|---|---|---|---|---|
| ឥណទានពាណិជ្ជកម្ម | ៤១២.៥១៤.១៦៩ | ១.៦៨០.៩៩៥.២៣៩ | ៣៤១.៧១០.០៤៦ | ១.៣៦៥.១៣១.៦៣៥ |
| ឥណទានសំរាប់អ្នកប្រើប្រាស់ | ២៨.៣៣២.៤៧១ | ១១៥.៨៥៤.៨១៩ | ៣៥.៦៥១.១៦០ | ១៤២.៤២៦.៣៨៣ |
| **សរុបឥណទានដុល** | **៤៤០.៨៤៦.៦៤០** | **១.៧៩៦.៨៥០.០៥៨** | **៣៧៧.៣៦១.២០៦** | **១.៥០៧.៥៥៨.០១៨** |

(ង) ការវិភាគឥណទាននិងបុរេប្រទានតាមប្រភេទអាជីវកម្មមានដូចតទៅ៖

| | ២០១៤ ដុល្លារអាមេរិក | ២០១៤ សមមូលជាប្រាក់រៀល (កំណត់សំគាល់ ២.១.៥) | ២០១៣ ដុល្លារអាមេរិក | ២០១៣ សមមូលជាប្រាក់រៀល (កំណត់សំគាល់ ២.១.៥) |
|---|---|---|---|---|
| ការលក់ដុំ និងរាយ | ១៥៧.៣៦០.៧៤៥ | ៦៤១.៣៦៧.២៤៦ | ១២៤.៩២១.៣៦៩ | ៤៩៩.០៦០.៨៦៤ |
| ផលិតកម្ម | *៥៣.៣៨៤.៧២៣* | *២១៧.៣៩៦.០៤៦* | ៤៣.៣៦៩.៤៨៨ | ១៧៣.៣៤០.៩៥៥ |
| សំណង់ | ៥០.០៣២.៣៥៦ | ២០៣.៨៤១.៨៥១ | ៤១.៥៩៧.៤៩៥ | ១៦៦.១៤១.៩៥៣ |
| កសិកម្ម | ៤៤.៤០៣.៤១៥ | ១៩៩.២៨១.៤១៦ | ៤៦.៧៤៤.១៤២ | ១៤៦.៩១៤.៦២៧ |
| ទំនិញសំរាប់អ្នកប្រើប្រាស់ | ៣៩.៨៧៤.៤៤១ | ១៦២.៨៨៨.៣៨៧ | ៣៥.៦៥១.១៦០ | ១៤២.៤២៦.៣៨៨ |
| អចលនទ្រព្យ | ២០.៣៦០.៥៧៧ | ៤២.៩៦៩.៣៥១ | ៥.៧៩៧.២០៦ | ២៣.១៩៩.៨៣៨ |
| ដឹកជញ្ជូន ស្តុកទុក និងទំនាក់ទំនង | ២.៤០៧.៦៤៤ | ៩.៤១១.១៨៩ | ១.២២២.៤៧១ | ៥.៨៨៣.៧៧២ |
| ផ្សេងៗ | ៦៤.៥២៤.៧៣៩ | ២៧៩.២៥៤.៦១២ | ៧៧.៩៤៣.៤៧៥ | ៣១១.៥៥៥.៥៨១ |
| **សរុបឥណទានដុល** | **៤៤០.៨៤៦.៦៤០** | **១.៧៩៦.៨៥០.០៥៨** | **៣៧៧.៣៦១.២០៦** | **១.៥០៧.៥៥៨.០១៨** |

## កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ (តពីទំព័រមុន)

សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤

### ៦. ឥណទាន និង បុរេប្រទានឲ្យអតិថិជន (តពីទំព័រមុន)

(ច) វិភាគបន្ថែមឥណទាន និងបុរេប្រទានតាមនិវាសនភាព សម្ព័ន្ធភាព និងហានិភ័យ មានដូចទៅះ

| | ២០១៤ ដុល្លារអាមេរិក | ២០១៤ សមមូលពាន់រៀល (កំណត់សំគាល់ ២.១.៥) | ២០១៣ ដុល្លារអាមេរិក | ២០១៣ សមមូលពាន់រៀល (កំណត់សំគាល់ ២.១.៥) |
|---|---|---|---|---|
| **តាមនិវាសនភាព៖** | | | | |
| និវាសនជន | ២៧២.៧៨២.៨០៧ | ១.១២៧.៧២៦.៩៣៩ | ២៤៥.៣០០.៧២៧ | ៩៧៩.៩៧៦.៤០៤ |
| អនិវាសនជន | ១៦៨.១០៣.៨៣៣ | ៦៦៨.៧២៣.១១៩ | ១៣២.០៦០.៤៧៩ | ៥២៧.៥៨១.៦១៤ |
| | ៤៤០.៨៨៦.៦៤០ | ១.៧៩៦.៤៥០.០៥៨ | ៣៧៧.៣៦១.២០៦ | ១.៥០៧.៥៥៨.០១៨ |
| **តាមសម្ព័ន្ធភាព៖** | | | | |
| ភាគីសម្ព័ន្ធញាតិ | ៦.៧៩៥.២៣៤ | ២៧.៥២៧.៥៧៩ | ៤.៧៣៧.២៦១ | ១៨.៩២៥.៣៥៨ |
| ពុំមែនភាគីសម្ព័ន្ធញាតិ | ៤៣៤.០៩១.៤០៦ | ១.៧៦៨.៩២២.៤៧៩ | ៣៧២.៦២៣.៩៤៥ | ១.៤៨៨.៦៣២.៦៦០ |
| | ៤៤០.៨៨៦.៦៤០ | ១.៧៩៦.៤៥០.០៥៨ | ៣៧៧.៣៦១.២០៦ | ១.៥០៧.៥៥៨.០១៨ |
| **តាមហានិភ័យ៖** | | | | |
| ហានិភ័យធំ | ១៥៨.៩២៦.៤០៩ | ៦៤៧.៦២៥.១១៧ | ១៤៩.៥៣៨.៦០៥ | ៥៩៧.៤០៦.៧២៦ |
| ពុំមែនហានិភ័យធំ | ២៨១.៩៦០.២៣១ | ១.១៤៨.៨២៤.៩៤១ | ២២៧.៨២២.៦០១ | ៩១០.១៥១.២៩២ |
| | ៤៤០.៨៨៦.៦៤០ | ១.៧៩៦.៤៥០.០៥៨ | ៣៧៧.៣៦១.២០៦ | ១.៥០៧.៥៥៨.០១៨ |

អត្រាការប្រាក់ប្រចាំឆ្នាំសំរាប់ឥណទាន និង បុរេប្រទានទៅអតិថិជនមានដូចតទៅះ

| | ២០១៤ | ២០១៣ |
|---|---|---|
| ឥណទានមានកាលកំណត់ | ២,៥០% - ១៨,០០% | ៥,០៥% - ១២,០០% |
| ឥណទានវិបារូបន៍ | ០,៥០% - ១២,០០% | ០,៥០% - ៩,៥០% |
| ប័ណ្ណឥណទាន | ៦,៥០% - ១២,០០% | ៧,៥០% - ១២,០០% |

### ៧. ការវិនិយោគលើមូលបត្រ

| | ២០១៤ ដុល្លារអាមេរិក | ២០១៤ សមមូលពាន់រៀល (កំណត់សំគាល់ ២.១.៥) | ២០១៣ ដុល្លារអាមេរិក | ២០១៣ សមមូលពាន់រៀល (កំណត់សំគាល់ ២.១.៥) |
|---|---|---|---|---|
| ការវិនិយោគលើសញ្ញាប័ណ្ណ (កំណត់សំគាល់លេខ៧.១) | ៩.៣៩០.០០២ | ៣៨.២៦៤.២៥៨ | ៩.៩៨២.៤០២ | ៣៩.៤៧៩.៦៩៦ |
| ការវិនិយោគលើប័ណ្ណភាគហ៊ុន (កំណត់សំគាល់លេខ៧.២) | ១.៥២៥.០០០ | ៦.២១៤.៣៧៥ | ១.៥២៥.០០០ | ៦.០៩២.៣៧៥ |
| | ១០.៩១៥.០០២ | ៤៤.៤៧៨.៦៣៣ | ១១.៥០៧.៤០២ | ៤៥.៥៧២.០៧១ |

## កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ (តពីទំព័រមុន)
សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤

### ៧. ការវិនិយោគលើមូលបត្រ (តពីទំព័រមុន)

#### *៧.១ ការវិនិយោគលើសញ្ញាប័ណ្ណ*

| | *២០១៤ ដុល្លារអាមេរិក* | *២០១៤ សមមូលពាន់រៀល (កំណត់សំគាល់ ២.១.៥)* | *២០១៣ ដុល្លារអាមេរិក* | *២០១៣ សមមូលពាន់រៀល (កំណត់សំគាល់ ២.១.៥)* |
|---|---|---|---|---|
| សញ្ញាប័ណ្ណដែលបោះផ្សាយដោយក្រុមហ៊ុន Tai Nguyen Construction - Manufacture - Trade Co., Ltd | ៥.៩១៣.៥៣៦ | ៣៤.៣៦០.១៥៩ | ៥.៥០៧.៥១១ | ៣៧.៩៨២.៥០៦ |
| មូលបត្របំណុលរដ្ឋាភិបាល | ៤៧.០៦៨ | ១៩១.៨០២ | ៤៧៤.៨៩១ | ១.៤៩៧.១៩០ |
| | ៥.៩៦០.៦០៤ | ៣៤.៥៥១.៩៦១ | ៥.៩៨២.៤០២ | ៣៩.៤៧៩.៦៩៦ |
| សំវិធានធនទូទៅសំរាប់សញ្ញាប័ណ្ណសាជីវកម្ម | (៧០.៦០២) | (២៨៧.៧០៣) | - | - |
| | **៥.៨៩០.០០២** | **៣៤.២៦៤.២៥៨** | **៥.៩៨២.៤០២** | **៣៩.៤៧៩.៦៩៦** |

សញ្ញាប័ណ្ណត្រូវបានបោះផ្សាយដោយក្រុមហ៊ុន Tai Nguyen Construction - Manufacture - Trade Co. Ltd ដើម្បីផ្តល់ហិរញ្ញប្បទានគំរោង Phuoc Nguyen Hung Apartment (Kenton Residences) នៅ Phuoc Kien. ស្រុក Nha Be. ក្រុង Ho Chi Minh និង មជ្ឈមណ្ឌលពាណិជ្ជកម្មពហុមុខងារនៅ Phu My Ward. District ៧. ក្រុង Ho Chi Minh។ សញ្ញាប័ណ្ណទាំងនេះមានកាលកំណត់ ៣ឆ្នាំ និងផ្តល់ការប្រាក់១៦% ក្នុង១ឆ្នាំ សំរាប់ឆ្នាំដំបូង។ ការប្រាក់សំរាប់ឆ្នាំបន្តបន្ទាប់ ស្មើនឹងអត្រាការប្រាក់មធ្យម លើប្រាក់បញ្ញើសំចៃរយៈពេល១២ខែ ជាវៀតណាមដុង ដែលបង់ការប្រាក់តាមក្រោយនៃធនាគារ BIDV (មជ្ឈមណ្ឌលប្រតិបត្តិការទី ២) Agribank (សាខា Saigon). Vietinbank (សាខា HCM) និង VCB (សាខា HCM) បូកអត្រាការប្រាក់បន្ថែម ៤,៥% ក្នុង១ឆ្នាំ។ ការប្រាក់ត្រូវបង់ជារៀងរាល់ឆ្នាំ។ ការសងបំណុលទាំងដើមទាំងការប្រាក់ (អត្រា ១៥%) ត្រូវបានធានាដោយធនាគារវិនិយោគ និងអភិវឌ្ឍវៀតណាម - មជ្ឈមណ្ឌលប្រតិបត្តិការទី ២។ អាយុកាលមូលបត្របញ្ចប់ត្រឹមថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៣ ប៉ុន្តែក្រោយមកត្រូវបានអនុញ្ញាតិដោយក្រុមប្រឹក្សាភិបាលឲ្យពន្យាដល់ ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៤។ ប្រាក់ដើមនៃ សញ្ញាប័ណ្ណទាំងនោះ ត្រូវបានប្រមូលមកវិញអស់ទាំងស្រុងក្នុងខែមករា ឆ្នាំ២០១៥ ហើយ។

មូលបត្របំណុលរដ្ឋាភិបាល រួមមាន សញ្ញាប័ណ្ណរតនាគារដែលមានអាយុកាល ៣ឆ្នាំ និងមានការប្រាក់ប្រចាំឆ្នាំ ៥,៤%។ ការប្រាក់ត្រូវបង់ជារៀងរាល់ឆ្នាំ។

## កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ (តពីទំព័រមុន)

សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤

## ៧. ការវិនិយោគលើមូលបត្រ (តពីទំព័រមុន)

### *៧.២. ការវិនិយោគលើប័ណ្ណភាគហ៊ុន*

| | *២០១៤* | | | *២០១៣* | | |
|---|---|---|---|---|---|---|
| | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល (កំណត់សំគាល់ ២.១.៥)* | *% កាន់កាប់ដោយធនាគារ* | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល (កំណត់សំគាល់ ២.១.៥)* | *% កាន់កាប់ដោយធនាគារ* |
| ក្រុមហ៊ុនមូលបត្រកម្ពុជា-វៀតណាម | ១.៥០០.០០០ | ៦.១១២.៥០០ | ១៥ | ១.៥០០.០០០ | ៥.៩៩២.៥០០ | ១៥ |
| ការិយាល័យឥណទានកម្ពុជា | ២៥.០០០ | ១០១.៨៧៥ | ១ | ២៥.០០០ | ៩៩.៨៧៥ | ១ |
| | **១.៥២៥.០០០** | **៦.២១៤.៣៧៥** | | **១.៥២៥.០០០** | **៦.០៩២.៣៧៥** | |

## ៨. ទ្រព្យ និងបរិក្ខារ

ទ្រព្យ និងបរិក្ខាររួមមាន៖

| | *២០១៤ ដុល្លារអាមេរិក* | *២០១៤ សមមូលពាន់រៀល (កំណត់សំគាល់ ២.១.៥)* | *២០១៣ ដុល្លារអាមេរិក* | *២០១៣ សមមូលពាន់រៀល (កំណត់សំគាល់ ២.១.៥)* |
|---|---|---|---|---|
| ទ្រព្យ និងបរិក្ខារ (កំណត់សំគាល់៨.១) | ៤.១៥៨.៧៧៤ | ១៦.៩៤៧.០០៤ | ៣.៥៧៣.២៩៥ | ១៤.២៧៥.៣១២ |
| សំណង់កំពុងសាងសង់ (កំណត់សំគាល់៨.២) | ២៥៦.៥២២ | ១.០៤៥.៣២៧ | ៦១៧.៤៨៧ | ២.៤៦៦.៨៦២ |
| | **៤.៤១៥.២៩៦** | **១៧.៩៩២.៣៣១** | **៤.១៩០.៧៨២** | **១៦.៧៤២.១៧៤** |

**កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ** (តពីទំព័រមុន)
សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤

## ៨. ទ្រព្យ និងបរិក្ខារ (តពីទំព័រមុន)

### *៨.១. ទ្រព្យ និងបរិក្ខារ*

បម្រែបម្រួលនៃទ្រព្យ និងបរិក្ខារក្នុងការិយបរិច្ឆេទមានដូចខាងក្រោម៖

| | *ការកែលំអអគារ* *ដុល្លារអាមេរិក* | *គ្រឿងសង្ហារិម ឧបករណ៍បំពាក់ និងបរិក្ខារ* *ដុល្លារអាមេរិក* | *បរិក្ខារព័ត៌មានវិទ្យា* *ដុល្លារអាមេរិក* | *យានយន្ត* *ដុល្លារអាមេរិក* | *សរុប* *ដុល្លារអាមេរិក* |
|---|---|---|---|---|---|
| **ថ្លៃដើម** | | | | | |
| នៅថ្ងៃទី១ ខែមករា ឆ្នាំ២០១៤ | ២.១៦២.៣៤៥ | ៨៥៧.១៦៤ | ១.៩៤៣.៥៩៥ | ៨២២.៥១២ | ៥.៧៨៥.៦១៦ |
| ទិញបន្ថែម | - | ១៤.៣៥៥ | ៨៦.៥៦២ | ២៨៦.៣៨៩ | ៣៨៧.៣០៦ |
| ផ្ទេរពីសំណង់កំពុងសាងសង់ (កំណត់សំគាល់លេខ ៨.២) | ២៣៥.១៥៥ | ៥០៣.៥៥២ | ៨០.២៥៣ | ៩៥.០០០ | ៩១៣.៩៦០ |
| លំអៀងអត្រាការប្រាក់ | - | (៥៥២) | (៥.១២៦) | (៣.៥៤៤) | (៩.២២២) |
| **នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤** | **២.៣៩៧.៥០០** | **១.៣៧៤.៥១៩** | **២.១០៥.២៨៤** | **១.២០០.៣៥៧** | **៧.០៧៧.៦៦០** |
| **រំលស់បង្គរ** | | | | | |
| នៅថ្ងៃទី១ ខែមករា ឆ្នាំ២០១៤ | ២០៥.០៨២ | ២៩៤.៨១៣ | ១.៤២៨.៩០៥ | ២៨៣.៥២១ | ២.២១២.៣២១ |
| រំលស់ | ១០៩.៨៧២ | ២៣៥.០១៤ | ២៥៧.២៥១ | ១០៩.១៩១ | ៧១០.៨២៨ |
| លំអៀងអត្រាការប្រាក់ | - | (៣១០) | (២.៩៤៨) | (៦០៥) | (៣.៨៦៣) |
| **នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤** | **៣១៤.៩១៤** | **៥២៩.៥១៧** | **១.៦៨៣.២០៨** | **៣៩២.១០៧** | **២.៩១៩.៧៤៦** |

**កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ** (តពីទំព័រមុន)
សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤

## ៨. ទ្រព្យ និងបរិក្ខារ (តពីទំព័រមុន)

### ៨.១. *ទ្រព្យ និងបរិក្ខារ* (តពីទំព័រមុន)

| | *ការកែលំអអគារ* *ដុល្លារអាមេរិក* | *គ្រឿងសង្ហារឹម ឧបករណ៍បំពាក់ និងបរិក្ខារ* *ដុល្លារអាមេរិក* | *បរិក្ខារព័ត៌មានវិទ្យា* *ដុល្លារអាមេរិក* | *យានយន្ត* *ដុល្លារអាមេរិក* | *សរុប* *ដុល្លារអាមេរិក* |
|---|---|---|---|---|---|
| **តម្លៃចុះបញ្ជីសុទ្ធ** | | | | | |
| **នៅថ្ងៃទី១ ខែមករា ឆ្នាំ២០១៤** | ១.៩៥៧.២៦៣ | ៥៦២.៣៥១ | ៥១៤.៦៤០ | ៥៣៨.៩៩១ | ៣.៥៧៣.២៤៥ |
| **នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤** | ២.០៨៣.៨៨៦ | ៨៨៩.០០២ | ៨១៤.០៧៦ | ៨០៤.២៥០ | ៤.១៥៨.៧៧៤ |
| ***សមមូលជាគរៀល** (កំណត់សំគាល់២.១.៥)* | | | | | |
| **នៅថ្ងៃទី១ ខែមករា ឆ្នាំ២០១៤** | ៧.៨១៩.២៦៦ | ២.២៨៦.៥៨១ | ២.០៥៦.១៨៦ | ២.១៥៣.២៦៩ | ១៨.២៧៥.៣១២ |
| **នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤** | ៨.៨៥០.០៨២ | ៣.៨៨៩.៦៨៣ | ១.៧០៣.៦៦០ | ៣.២៨៣.៦១៩ | ១៦.៩៨៧.០០៨ |

## កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ (តពីទំព័រមុន)

សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤

### ៨. ទ្រព្យ និងបរិក្ខារ (តពីទំព័រមុន)

### *៨.២. សំណង់កំពុងសាងសង់*

| | *២០១៤ ដុល្លារអាមេរិក* | *២០១៤ សមមូលពាន់រៀល (កំណត់សំគាល់ ២.១.៥)* | *២០១៣ ដុល្លារអាមេរិក* | *២០១៣ សមមូលពាន់រៀល (កំណត់សំគាល់ ២.១.៥)* |
|---|---|---|---|---|
| **នៅថ្ងៃទី១ ខែមករា** | **៦១៧.៨៨៧** | **២.៨៦៦.៨៦២** | **៦១០.៥៧៧** | **២.៨៣៩.២៥៦** |
| **បន្ថែមក្នុងគ្រា** | ៨៧៤.៨៧១ | ៣.៥៦៥.០៩៩ | ១.៥៨៣.៩២៩ | ៦.៣២៧.៧៩៨ |
| ផ្ទេរទៅការិយាល័យអគារ *(កំណត់សំគាល់លេខ ៨.១)* | (២៣៥.១៥៥) | (៩៥៨.២៥៧) | (៥៥៣.៨៩៣) | (២.២១១.២០៨) |
| ផ្ទេរទៅយានយន្ត *(កំណត់សំគាល់លេខ ៨.១)* | (៩៥.០០០) | (៣៨៧.១២៥) | (១៨២.៨២២) | (៥៧០.៥៧២) |
| ផ្ទេរទៅបរិក្ខារព័ត៌មានវិទ្យា *(កំណត់សំគាល់លេខ ៨.១)* | (៤០.២៥៣) | (៣២៧.០៣១) | (៧២.៧៥៧) | (២៩០.៦៦៥) |
| ផ្ទេរទៅគ្រឿងសង្ហារឹម និងបរិក្ខា *(កំណត់សំគាល់លេខ ៨.១)* | (៥០៣.៥៥២) | (២.០៥១.៩៧៨) | (១៩១.២៨៦) | (៧៦៨.១៨៩) |
| ផ្ទេរទៅកម្មវិធីកុំព្យូទ័រ *(កំណត់សំគាល់លេខ ៩)* | (៧៩.៩៧៣) | (៣២៥.៨៩០) | (៨០៨.១៨៩) | (១.៦១៩.៧៣៥) |
| ផ្ទេរទៅឧបករណ៍និងសំភារៈ | (២៥១.៩០៣) | (៩៨៥.៧៥៥) | (២១២.៣៨៨) | (៨៨៨.៣១៦) |
| | **២៥៦.៥២២** | **៩៩៥.៩២៩** | **៦១៧.៦១៥** | **២.៨៦៧.៣៧៣** |
| លំអៀងអត្រាប្តូរប្រាក់ | - | ៥៩.៣៩៨ | (១២៨) | (៥១១) |
| **នៅថ្ងៃទី៣១ ខែធ្នូ** | **២៥៦.៥២២** | **១.០៥៥.៣២៧** | **៦១៧.៨៨៧** | **២.៨៦៦.៨៦២** |

## កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ (តពីទំព័រមុន)

សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤

### ៩. ទ្រព្យអរូបិយ

| | *កម្មវិធីកុំព្យូទ័រ ដុល្លារអាមេរិក* |
|---|---:|
| **ថ្លៃដើម** | |
| នៅថ្ងៃទី១ ខែមករា ឆ្នាំ២០១៤ | **៣.៥៧៧.៦៦២** |
| ផ្ទេរពីសំណង់កំពុងសាងសង់ (កំណត់សំគាល់លេខ៨.២) | ៧៩.៩៧៣ |
| លំអៀងការប្តូរប្រាក់ | (១០.៧៣៧) |
| **នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤** | **៣.៦៤៦.៨៩៨** |
| **រំលស់បង្គរ** | |
| **នៅថ្ងៃទី១ ខែមករា ឆ្នាំ២០១៤** | **១.១២៥.០៦៦** |
| រំលស់ | ៣៦៣.១២០ |
| លំអៀងអត្រាប្តូរប្រាក់ | (៣.៣៦៦) |
| **នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤** | **១.៤៨៤.៨២០** |
| **តម្លៃចុះបញ្ជីសុទ្ធ** | |
| នៅថ្ងៃទី១ ខែមករា ឆ្នាំ២០១៤ | **២.៤៥២.៥៩៦** |
| នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ | **២.១៦២.០៧៨** |
| **សមមូលពាន់រៀល (កំណត់សំគាល់២.១.៥)** | |
| **នៅថ្ងៃទី១ ខែមករា ឆ្នាំ២០១៤** | **៥.៧៩៩.១២១** |
| **នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤** | **៤.៨១០.៨៦៨** |

## កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ (តពីទំព័រមុន)

សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤

### ១០. ទ្រព្យសកម្មផ្សេងៗ

| | ២០១៤ ដុល្លារអាមេរិក | ២០១៤ សមមូលពាន់រៀល (កំណត់សំគាល់ ២.១.៥) | ២០១៣ ដុល្លារអាមេរិក | ២០១៣ សមមូលពាន់រៀល (កំណត់សំគាល់ ២.១.៥) |
|---|---|---|---|---|
| ប្រាក់តំកល់សំរាប់គតិសន្យា(*) | ១៥.១១២.៩៩៨ | ៦១.៥៨៥.៨៦៨ | ៧៦៧.២០៩ | ៣.០៦៥.៩៤០ |
| ការប្រាក់ត្រូវទទួល | ៥.៦២២.៩៨៨ | ១៨.៨៣៨.៩៩៧ | ៥.០៩៧.៨២៨ | ១៦.៣៦៩.២០៧ |
| គណនីត្រូវទទួលពី Tai Nguyen Construction – Manufacture – Trade Co.. Ltd (**) | ១.៨១២.៩៥៥ | ៧.៣៨៧.៧៩១ | - | - |
| បុរេប្រទាននិងការបង់ប្រាក់មុន | ១.០៥៨.២០៩ | ៥.៣១២.១៨១ | ២៥៥.៨១៩ | ១.០១៦.៨០៩ |
| ប្រាក់ត្រូវទទួលពីការលក់ទ្រព្យសកម្ម | - | - | ៣៥០.០០០ | ១.៣៩៥.២៥០ |
| ផ្សេងៗ | ៣០៦.៦០៥ | ១.២៩៩.៨១៥ | ៣៨៣.៨៧៨ | ១.៥៣៣.៥៩៣ |
| **សរុប** | **២២.៩១៣.៧០៦** | **៩៣.៣៧៣.៣៥២** | **៥.៨៥២.៩២៥** | **២៣.៣៨២.៩៣៩** |
| សំវិធានសំរាប់បំណុលសង្ស័យ | (២៣៣.៩៧២) | (៩៥៣.៨៣៦) | (១៦៨.៧៩១) | (៦៧៨.៣២០) |
| | **២២.៦៧៩.៧៣៤** | **៩២.៤១៩.៥១៦** | **៥.៦៨៤.១៣៤** | **២២.៧០៤.៦១៩** |

(*) នេះជាចំនួនប្រាក់តំកល់លើការជួលដីសំរាប់គោលដៅសាងសង់ផ្ទះរបស់បុគ្គលិក និង ការិយាល័យនានានៅរាជធានីភ្នំពេញ។

(**) គណនីត្រូវទទួលដែលនៅសល់នេះ គឺមកពីការទូទាត់លើសញ្ញាប័ណ្ណដែលចេញដោយ Tai Nguyen Construction – Manufacture – Trade Co.. Ltd. (កំណត់សំគាល់ ៧.១)

### ១១. ប្រាក់បញ្ញើរបស់ស្ថាប័នហិរញ្ញវត្ថុផ្សេងៗ

| | ២០១៤ ដុល្លារអាមេរិក | ២០១៤ សមមូលពាន់រៀល (កំណត់សំគាល់ ២.១.៥) | ២០១៣ ដុល្លារអាមេរិក | ២០១៣ សមមូលពាន់រៀល (កំណត់សំគាល់ ២.១.៥) |
|---|---|---|---|---|
| ប្រាក់បញ្ញើតាមតំរូវការ | ៨៣៥.៦៣៣ | ៣.៤០៥.២០៨ | ២០១.៨៦៣ | ៨០៩.៨៨៥ |
| ប្រាក់បញ្ញើមានកាលកំណត់ និងកម្ចី | ២៩៩.៩៥២.៩២៥ | ១.២២២.៣០៨.១៧០ | ២៦០.៧៣២.៥០៨ | ១.០៩១.៦២៦.៣៦៥ |
| **សរុប** | **៣០០.៧៨៨.៥៥៨** | **១.២២៥.៧១៣.៣៧៨** | **២៦០.៩៣៣.៩៧១** | **១.០៩២.៤៣១.២១៨** |

អត្រាការប្រាក់ប្រចាំឆ្នាំសំរាប់ប្រាក់បញ្ញើរបស់ស្ថាប័នហិរញ្ញវត្ថុផ្សេងៗ មានដូចតទៅ៖

| | ២០១៤ ដុល្លារអាមេរិក | ២០១៣ ដុល្លារអាមេរិក |
|---|---|---|
| ប្រាក់បញ្ញើតាមតំរូវការ | ០,០០% | ០,០០% |
| ប្រាក់បញ្ញើមានកាលកំណត់ | ១,៩០% - ៦,០០% | ១,០០% - ៦,០០% |

## កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ (តពីទំព័រមុន)

សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤

### ១២. ប្រាក់បញ្ញើរបស់អតិថិជន

| | *២០១៤ ដុល្លារអាមេរិក* | *២០១៤ សមមូលពាន់រៀល (កំណត់សំគាល់ ២.១.៥)* | *២០១៣ ដុល្លារអាមេរិក* | *២០១៣ សមមូលពាន់រៀល (កំណត់សំគាល់ ២.១.៥)* |
|---|---|---|---|---|
| គណនីចរន្ត | ៣០.៧៦០.១១៤ | ១២៥.៣៤៧.៥៤១ | ១៥.៨៣៣.៨២០ | ៦៣.២៥៦.១១១ |
| គណនីមានកាលកំណត់ | ១៦៣.១៤៤.១០២ | ៦៦៤.៤២៤.៥១៦ | ១២៥.២៥១.៣៥៧ | ៥១៦.៣៥៩.១៣១ |
| គណនីសំចៃ | ២.២៥៨.៩៩៨ | ៩.២០៥.៤១៧ | ១.៨៨៩.៥៨៤ | ៥.៧៤១.០៨៤ |
| ប្រាក់បញ្ញើកំរៃតទុក | ៤៣៣.៦៤០ | ១.៧៦៧.០៨២ | ១.៥៨៦.៨៩៤ | ៧.៧៧៦.២៨៤ |
| **សរុប** | **១៩៦.៥៩៦.៨៥៤** | **៨០១.១៣២.១៩៦** | **១៤៤.៨៨១.២៨៥** | **៥៨៣.១៨២.៥៧៤** |

*ការវិភាគពីប្រាក់បញ្ញើរបស់អតិថិជនមានដូចតទៅៈ*

(ក) ប្រភេទនៃអតិថិជន

| | *២០១៤ ដុល្លារអាមេរិក* | *២០១៤ សមមូលពាន់រៀល (កំណត់សំគាល់ ២.១.៥)* | *២០១៣ ដុល្លារអាមេរិក* | *២០១៣ សមមូលពាន់រៀល (កំណត់សំគាល់ ២.១.៥)* |
|---|---|---|---|---|
| ក្រុមហ៊ុនក្នុងស្រុក | ៣៦.០២៣.៥៧៩ | ១៤៦.៧៩៦.០៨៤ | ៣០.៥៥៧.០០០ | ១២៣.៦៧៣.២១៥ |
| ក្រុមហ៊ុនបរទេស | ៣៧.០២៣.៦៧៥ | ១៥០.៨៧១.៨៧៦ | ៣៦.០៧៨.៨១៤ | ១៤៤.១១៤.៨៥៨ |
| និវាសនជនជាបុគ្គល | ៤៨.៤៣០.៨៩៣ | ១៩៧.៨៥៥.៦៨៥ | ២៧.៥៨៩.០០១ | ១១០.០៥៨.២៥៩ |
| អនិវាសនជនជាបុគ្គល | ៧៥.១១៨.៧០៧ | ៣០៦.១០៨.៥៥១ | ៥៣.៤០០.៥២៦ | ២១៥.៣៣២.២០២ |
| **សរុប** | **១៩៦.៥៩៦.៨៥៤** | **៨០១.១៣២.១៩៦** | **១៤៤.៨៨១.២៨៥** | **៥៨៣.១៨២.៥៧៤** |

(ខ) ការវិភាគតាមកាលកំណត់មានបង្ហាញ នៅកំណត់សំគាល់២៦ នៃការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ។

(គ) ប្រាក់បញ្ញើពីសំណាក់សម្ព័ន្ធញាតិមានបង្ហាញនៅកំណត់សំគាល់២៤ នៃប្រតិបត្តិការ និង សមតុល្យជាមួយសម្ព័ន្ធញាតិ។

(ឃ) អត្រាការប្រាក់ប្រចាំឆ្នាំសំរាប់ប្រាក់បញ្ញើរបស់អតិថិជនមានដូចតទៅៈ

| | *២០១៤* | *២០១៣* |
|---|---|---|
| ប្រាក់បញ្ញើមានកាលកំណត់ | ០,២៥% - ១២,០០% | ០,២០% - ១២,០០% |

## កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ (តពីទំព័រមុន)

សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤

### ១៣. ពន្ធដារ

ធាតុចំបងៗនៃចំណាយពន្ធដារក្នុងឆ្នាំមានដូចតទៅ៖

| | ២០១៤<br>ដុល្លាអាមេរិក | ២០១៤<br>សមមូលពាន់រៀល<br>(កំណត់<br>សំគាល់ ២.១.៥) | ២០១៣<br>ដុល្លាអាមេរិក | ២០១៣<br>សមមូលពាន់រៀល<br>(កំណត់<br>សំគាល់ ២.១.៥) |
|---|---|---|---|---|
| **ពន្ធលើប្រាក់ចំណេញ** | | | | |
| ពន្ធបច្ចុប្បន្ន | ១.៨៦១.៨៧៩ | ៧.៥៤៧.១៥៧ | ១.៣៩៦.២៧១ | ៥.៥៧៨.១០៤ |
| ពន្ធពន្យារ | - | - | - | - |
| **ចំណាយពន្ធដារសរុបក្នុងឆ្នាំ** | **១.៨៦១.៨៧៩** | **៧.៥៤៧.១៥៧** | **១.៣៩៦.២៧១** | **៥.៥៧៨.១០៤** |

*ពន្ធលើប្រាក់ចំណេញបច្ចុប្បន្ន*

ប្រតិវេទន៍ប្រចាំឆ្នាំរបស់ធនាគារ នឹងត្រូវត្រួតពិនិត្យឡើងវិញដោយអាជ្ញាធរពន្ធដារ។ ចំនួនទឹកប្រាក់ពន្ធនៅក្នុង របាយការណ៍ហិរញ្ញវត្ថុអាចនឹងផ្លាស់ប្តូរនាការិយបរិច្ឆេទបន្ទាប់ក្រោយពីការ សំរេចចុងក្រោយដោយអជ្ញាធរពន្ធដារ ដោយសារការអនុវត្តច្បាប់ពន្ធដារ និងបទបញ្ញត្តិងាយ នឹងមានការប្រែប្រួលតាមការបកស្រាយ។
អនុលោមតាមបទបញ្ញត្តិពន្ធដារកម្ពុជា ពន្ធលើប្រាក់ចំណេញបច្ចុប្បន្នត្រូវបានគណនា ដោយយកតំលៃខ្ពស់បំផុតរវាងចំណូលជាប់ពន្ធក្នុងឆ្នាំគុណនឹងអត្រាពន្ធ២០% និង ១%នៃផលរបរ។

អនុលោមតាមបទបញ្ញត្តិពន្ធដារវៀតណាម ពន្ធលើប្រាក់ចំណេញត្រូវបានគណនាដោយយកអត្រាពន្ធ ២២% (២០១៣៖ ២៥%) លើចំណូលជាប់ពន្ធ។

ចំណាយពន្ធលើប្រាក់ចំណេញបច្ចុប្បន្នមានដូចតទៅ៖

| | ២០១៤<br>ដុល្លាអាមេរិក | ២០១៤<br>សមមូលពាន់រៀល<br>(កំណត់<br>សំគាល់ ២.១.៥) | ២០១៣<br>ដុល្លាអាមេរិក | ២០១៣<br>សមមូលពាន់រៀល<br>(កំណត់<br>សំគាល់ ២.១.៥) |
|---|---|---|---|---|
| ប្រតិបត្តិការនៅកម្ពុជា | ១.១៧០.៧៩១ | ៤.៧៧០.៧៧០ | ៤០៦.៥៤៨ | ១.៦២៤.១៥៩ |
| សាខាហាណូយ | ៤៣៩.៨៣៤ | ១.៧៨២.៣៦៤ | ៦០៧.៣៥៣ | ២.៤២៦.៣៧៥ |
| សាខាហូជីមិញ | ២៥១.២៥៤ | ១.០២៨.០២៣ | ៣៨២.៣៧០ | ១.៥២៧.៥៧០ |
| **ពន្ធលើប្រាក់ចំណេញសរុប** | **១.៨៦១.៨៧៩** | **៧.៥៤៧.១៥៧** | **១.៣៩៦.២៧១** | **៥.៥៧៨.១០៤** |

## កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ (តពីទំព័រមុន)

សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤

### ១៣. ពន្ធដារ (តពីទំព័រមុន)

ការផ្ទៀងផ្ទាត់រវាងចំណាយពន្ធ និងប្រាក់ចំណេញគណនេយ្យដែលគណនាតាមអត្រាពន្ធ ២០% មានដូចខាងក្រោម៖

| | ២០១៤<br>ដុល្លារអាមេរិក | ២០១៤<br>សមមូលពាន់រៀល<br>(កំណត់សំគាល់ ២.១.៥) | ២០១៣<br>ដុល្លារអាមេរិក | ២០១៣<br>សមមូលពាន់រៀល<br>(កំណត់សំគាល់ ២.១.៥) |
|---|---|---|---|---|
| **ប្រាក់ចំណេញគណនេយ្យ មុនកាត់ពន្ធ** | **៦.០៧៨.៣៧៥** | **២៤.៧៦៩.៣៧៨** | **៥.៤៩៧.៥០៩** | **២១.៧៦២.៧៩៧** |
| **ចំណាយពន្ធតាមច្បាប់ ក្នុងអត្រា ២០%** | **១.២១៥.៦៧៥** | **៤.៩៥៣.៨៧៦** | **១.០៩៩.៥០២** | **៤.៣៥២.៥៦០** |
| និយ័តកម្មពន្ធលើប្រាក់ចំណេញក្នុងការិយបរិច្ឆេទបច្ចុប្បន្ន | | | | |
| លំអៀងនៃអត្រាពន្ធនៅវៀតណាម និងកម្ពុជា | ៦០.៧៩៦ | ២៤៧.៧៤៤ | ១៨២.៣១០ | ៧៦៤.២៨០ |
| ចំណាយមិនអាចកាត់កងបាន | ២៩៧.៧១០ | ១.២១៣.១៦៨ | ២១.៩៨៦ | ៨៧.៨៣៨ |
| **ចំណាយពន្ធលើប្រាក់ចំណេញបច្ចុប្បន្ន** | **១.៥៧៤.១៨១** | **៦.៤១៤.៧៨៨** | **១.៣០៣.៧៩៨** | **៥.២០៤.៦៧៨** |
| ចំណាយពន្ធបន្ថែមសំរាប់ការិយបរិច្ឆេទមុន | ២៨៧.៦៩៤ | ១.១៧២.៣៦៩ | ៦២.៤៧៣ | ៣៦៩.៤៣០ |
| **ពន្ធលើប្រាក់ចំណេញបង្ហាញ ក្នុងរបាយការណ៍លទ្ធផល** | **១.៨៦១.៨៧៥** | **៧.៥៨៧.១៥៧** | **១.៣៦៦.២៧១** | **៥.៥៧៤.១០៨** |

បំរែបំរួលនៃពន្ធបច្ចុប្បន្នដែលត្រូវបង់កំឡុងការិយបរិច្ឆេទមានដូចតទៅ៖

| | ២០១៤<br>ដុល្លារអាមេរិក | ២០១៤<br>សមមូលពាន់រៀល<br>(កំណត់សំគាល់ ២.១.៥) | ២០១៣<br>ដុល្លារអាមេរិក | ២០១៣<br>សមមូលពាន់រៀល<br>(កំណត់សំគាល់ ២.១.៥) |
|---|---|---|---|---|
| សមតុល្យដើមឆ្នាំ | ៥១៤.៥២៦ | ២.០៧១.៥១២ | ១.៥០៤.១៩០ | ៦.០០៩.២៣៩ |
| ចំណាយពន្ធបច្ចុប្បន្ន | ១.៨៦១.៨៧៥ | ៧.២៨១.៨២៩ | ១.៣៦៦.២៧១ | ៥.៥៧៤.១០៨ |
| ការបង់ពន្ធក្នុងការិយបរិច្ឆេទ | (១.០១៣.៦៤៣) | (៤.១៣០.៧៥៤) | (២.១៩៧.៨៧២) | (៨.៧០៤.៥៤៩) |
| ការកាត់កងនឹងបុរេប្រទានពន្ធដារ | (២៣៦.០៩៨) | (៩៦១.៨៩៦) | (១៥៥.៦១៨) | (៧៩៧.០៧៩) |
| លំអៀងអត្រាប្តូរប្រាក់ | (១.៥៦០) | ៣៣.៤៥៥ | (២.៤៤៥) | (៩.៧៦៨) |
| **សមតុល្យពន្ធនៅចុងឆ្នាំ** | **១.១២៥.៧១៤** | **៤.៥៨៥.៥១០** | **៥១៤.៥២៦** | **២.០៧១.៥១២** |

## កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ (តពីទំព័រមុន)

សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤

### ១៤. ទ្រព្យសកម្មផ្សេងៗ

| | ២០១៤<br>ដុល្លារអាមេរិក | ២០១៤<br>សមមូលពាន់រៀល<br>(កំណត់សំគាល់ ២.១.៥) | ២០១៣<br>ដុល្លារអាមេរិក<br>(បង្ហាញឡើងវិញ) | ២០១៣<br>សមមូលពាន់រៀល<br>(កំណត់សំគាល់ ២.១.៥)<br>(បង្ហាញឡើងវិញ) |
|---|---|---|---|---|
| ការប្រាក់ត្រូវបង់ | ៤.២៩៣.៣៨៧ | ១៧.៤៥៥.៥៥២ | ៣.២៨៧.៦៣៩ | ១៣.១៣៨.១១៨ |
| ប្រាក់ខែ និងថ្លៃឈ្នួលត្រូវបង់ | ៧១៧.៣១៩ | ២.៩២៣.០៧៥ | ៣២៤.៤៦៥ | ១.២៦៦.២៣៤ |
| មូលនិធិប្រាក់រង្វាន់ និងសុខុមាលភាពបុគ្គលិក | ២៧.២១៦ | ១១០.៤០៥ | ២៥.១៧៩ | ១០០.៥៨០ |
| ផ្សេងៗ | ១៨៥.២២៤ | ៧៥៥.៧៨៩ | ៤៦៥.៨៤០ | ១.៨៦១.០៣០ |
| | **៥.២២៣.១៤៦** | **២១.២៤៤.៨២១** | **៤.១០៣.១២៣** | **១៦.៣៦១.៨៧៦** |

បំរែបំរួលនៃមូលនិធិប្រាក់រង្វាន់ និងសុខុមាលភាពបុគ្គលិកក្នុងកំឡុងឆ្នាំមានដូចតទៅ៖

| | ២០១៤<br>ដុល្លារអាមេរិក | ២០១៤<br>សមមូលពាន់រៀល<br>(កំណត់សំគាល់ ២.១.៥) | ២០១៣<br>ដុល្លារអាមេរិក | ២០១៣<br>សមមូលពាន់រៀល<br>(កំណត់សំគាល់ ២.១.៥) |
|---|---|---|---|---|
| សមតុល្យដើមឆ្នាំ | ២៥.១៧៩ | ១០០.៥៨០ | ១៧.៤៦៩ | ៦៩.៧៨៩ |
| ទឹកប្រាក់បំរុងសំរាប់មូលនិធិប្រាក់រង្វាន់ និងសុខុមាលភាពបុគ្គលិក | ២០០.០០០ | ៤១៥.០០០ | ៣២៦.៥៥៥ | ១.៣០៤.៥៨៧ |
| ការប្រើប្រាស់ | (១៩៧.៩៦៣) | (៤០៧.១៨៩) | (៣១៨.៨៤៥) | (១.២៧៣.៧៩៦) |
| លំអៀងអត្រាប្តូរប្រាក់ | - | ២.០១៤ | - | - |
| **សមតុល្យចុងឆ្នាំ** | **២៧.២១៦** | **១១០.៤០៥** | **២៥.១៧៩** | **១០០.៥៨០** |

## កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ (តពីទំព័រមុន)

សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤

### ១៥. ដើមទុនបានបង់ និងទុនបំរុង

ដើមទុនបានបង់ដែលមានចំនួន ៧០លានដុល្លារអាមេរិក ឬ ២៨៥,២៥ ពាន់លានរៀល ត្រូវបានបង់ទាំងស្រុងដោយភាគទុនិកម្នាក់ និងក្រុមហ៊ុនវិនិយោគនិងអភិវឌ្ឍន៍កម្ពុជាលីមីតធីត ("IDCC") ដែលជាក្រុមហ៊ុន មួយបានចុះបញ្ជីនៅកម្ពុជា និងដែលមានម្ចាស់ភាគហ៊ុនរួមគ្នា ២ គឺ ធនាគារវិនិយោគ និងអភិវឌ្ឍន៍ វៀតណាម ("BIDV") (កាន់កាប់ហ៊ុន ៨០%) និង Phuong Nam (កាន់កាប់ហ៊ុន ២០%)។

***ទុនបំរុងទូទៅ***

<u>ប្រតិបត្តិការនៅវៀតណាម</u>

អនុលោមតាមអនុក្រឹតលេខ ៥៧/២០១២/ND-CP មានប្រសិទ្ធិភាពចាប់ពីថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ ២០១២ សាខារបស់ធនាគារធនាគារត្រូវបានតំរូវអោយមានទុនបំរុងកាតព្វកិច្ចតាមអត្រានៃប្រាក់ចំណេញក្រោយ បង់ពន្ធដូចខាងក្រោម៖

| | *មូលដ្ឋាននៃការគណនា* | *សមតុល្យអតិបរមា* |
|---|---|---|
| ទុនបំរុងដើមទុនបន្ថែម | ៥%នៃប្រាក់ចំណេញក្រោយបង់ពន្ធ | ១០០%នៃដើមទុនទទួលស្គាល់ (charter capital) |
| ទុនបំរុងហិរញ្ញវត្ថុ | ១០%នៃប្រាក់ចំណេញក្រោយបង់ពន្ធ | ២៥%នៃដើមទុនទទួលស្គាល់ (charter capital) |

<u>ប្រតិបត្តិការនៅកម្ពុជា</u>

ធនាគាររៀបចំអោយមានទុនបំរុងដើមទុនបន្ថែម ទុនបំរុងហិរញ្ញវត្ថុ និងទុនបំរុងផ្សេងៗ តាមអត្រានៃប្រាក់ចំណេញក្រោយបង់ពន្ធដែលអនុម័តដោយភាគទុនិក។

| | *ទុនបំរុងដើមទុន បន្ថែម ដុល្លារអាមេរិក* | *ទុនបំរុងហិរញ្ញវត្ថុ ដុល្លារ អាមេរិក* | *សរុប ដុល្លារអាមេរិក* |
|---|---|---|---|
| **សមតុល្យនៅថ្ងៃទី១ ខែមករា ឆ្នាំ ២០១៤** | **៦៧៦.៧១៤** | **១.២៨៥.៥៧៦** | **១.៩៦២.២៩០** |
| ប្រាក់បំរុងសំរាប់ទុនបំរុង | ២០២.៥៦២ | ៣៨៤.៨៧១ | ៥៨៧.៤៣៣ |
| **សមតុល្យនៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ២០១៤** | **៨៧៩.២៧៦** | **១.៦៧០.៤៤៧** | **២.៥៤៩.៧២៣** |

## កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ (តពីទំព័រមុន)

សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤

### ១៦. ចំណូលការប្រាក់ និងចំណូលប្រហាក់ប្រហែល

